**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University Of Law and Economic

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីជំនុំជម្រះរឿងក្ដីព្រហ្មទណ្ឌនៅសាលាដំបូង

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧

រៀបរៀងដោយ

និស្សិតឈ្មោះ៖ **ក.ស៊ឹម សុវណ្ណារី**

សាស្ត្រាចារ្យណែនាំ៖

**លោក ជួន ប៊ុនធី**

ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ

ជំនាន់ទី១៧

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

## សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ **ស៊ឹម សុវណ្ណារី** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី១៧ ឆ្នាំសិក្សា ២០១៦-២០១៧ នៃសាកវិទ្យាល័យភូមុន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ជាបឋមនាងខ្ញុំ សូមគោរពលំអោនកាយវិចារចិត្តប្រកបដោយកត្តញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅបំផុតអស់ពីដួងចិត្តជូនចំពោះ **លោកអ្នកមានគុណទាំងពីរ** ដែលអ្នកមានគុណទាំងពីរ បានផ្តល់កំណើតដល់រូបកូន និងយកចិត្តទុកដាក់ចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅកូន ប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងបានទំនុកបំរុងកូនសព្វគ្រប់បែបយ៉ាងទាំងផ្នែកស្មារតី និង សម្ភារៈរហូតដល់កូនមានឱកាស សិក្សារៀនសូត្រចាប់ពីថ្នាក់បឋមសិក្សារហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះ។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅគោរពជូនចំពោះ៖**

- អ្នកម្តាយធំ **គុប ស៊ីថារ៉ា** ដែលលោកក៏បានចូលរួមជួយជ្រោមជ្រែងផ្គត់ផ្គង់ក្នុងការសិក្សារៀនសូត្រ និងអប់រំទូន្មានក្មួយតាំងពីតូចរហូតដល់ធំព្រមទាំងបានជួយបង្ហាត់បង្រៀនក្មួយទាំងភាសាជាតិ និងភាសាអន្តរជាតិ ជាពិសេសតែងតែផ្តល់ភាពកក់ក្តៅដល់ក្មួយប្រៀបដូចជាកូនបង្កើតជួយលើកទឹកចិត្តក្មួយឲ្យខិតខំប្រឹងប្រែងសង្វាតរៀនសូត្រ ហើយក្មួយក៏សូមអរគុណអ្នកម្តាយធំដែលតែងតែធ្វើជាទីប្រឹក្សារបស់ក្មួយកន្លងមកជាពិសេសបំផុតរយៈពេល៤ឆ្នាំនេះ។

- ឯកឧត្តម **លុយ ចន្ធា** សាកលវិទ្យាធិការនៃសាកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់នូវកម្រិតសិក្សាដ៏មានគុណភាព ព្រមទាំងបានផ្តល់នូវសាស្ត្រាចារ្យល្អៗក្នុងការបង្រៀនដល់រូបនាងខ្ញុំចាប់តាំងពីថ្នាក់ឆ្នាំមូលដ្ឋានមក រហូតដល់ឆ្នាំបញ្ចប់ការសិក្សាផ្នែកនីតិសាស្ត្រនេះ

-លោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលជាសាស្ត្រាចារ្យណែនាំបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំ ពន្យល់ និងកែលម្អនូវរាល់ចំណុចខ្វះខាតនៃសារណានេះតាំងពីដើមរហូតដល់នាងខ្ញុំទទួលបាននូវលទ្ធផលស្កាពរ។

-លោកចៅក្រម **ឌុច សុខសារិន** ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ ដែលលោកបានផ្តល់ឱកាសដល់នាងខ្ញុំស្រាវជ្រាវឯកសារ ព្រមទាំងផ្តល់ឯកសារក្នុងការសរសេរសារណារបស់នាងខ្ញុំ។

ជាទីបញ្ចប់ នាងខ្ញុំសូមគោរពជូនពរដល់លោកអ្នកដ៏មានគុណទាំងអស់ឲ្យទទួលបាននូវពុទ្ធិពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សាអស់រយៈពេល៤ឆ្នាំ ខាងជំនាញផ្នែកនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នាងខ្ញុំពិតជាមានសេចក្តីសោមនស្សដែលសាកលវិទ្យាល័យបានផ្តល់ឪកាសដល់រូបនាងខ្ញុំ បញ្ចេញនូវសមត្ថភាពខាងផ្នែកទ្រឹស្តីដែលបានសិក្សាអស់រយៈពេល៤ឆ្នាំកន្លងមកនេះមកសរសេរចងក្រងជាសារណាបញ្ចប់ការសិក្សាមួយនេះឡើង។ បន្ទាប់ពីបានខិតខំចំណាយពេលជាច្រើនក្នុងការក្រេបយកចំណេះវិជ្ជា ការសិក្សាស្រាវជ្រាវប្រមូលចងក្រងឯកសារ និងការទទួលបានបទពិសោធន៍ល្អៗ និងឯកសារមេរៀនដ៏មានអត្ថប្រយោជន៍ជាច្រើនបន្ថែមទៀតរបស់លោក-លោកស្រីសាស្ត្រាចារ្យដែលបានបង្ហាត់បង្រៀន ពន្យល់បកស្រាយនូវរាល់ចម្ងល់របស់មិត្តនិស្សិតទាំងអស់យ៉ាងក្បោះក្បាយបានផ្តល់ជាគោលគំនិតក្នុងការសរសេរសារណារបស់នាងខ្ញុំក៏ដូចជាការចុះទៅធ្វើការសិក្សាស្រាវជ្រាវដោយផ្ទាល់នៅសាលាដំបូងរាជធានីភ្នំពេញ បានផ្តល់ឲ្យនាងខ្ញុំនូវចំណេះដឹងកាន់តែច្បាស់បន្ថែមទៀត។

ចំពោះការសិក្សាជំនាញផ្នែកបរិញ្ញាបត្រនីតិសាស្ត្រនេះ នាងខ្ញុំបានទទួលចំណេះដឹងនានាជាច្រើនស្ទើរតែគ្រប់វិស័យ ប៉ុន្តែនាងខ្ញុំមានចំណាប់អារម្មណ៍យ៉ាងខ្លាំងទៅលើវិស័យយុត្តាធិការនៅព្រះរាជាណាចក្រកម្ពុជា។ ហេតុដូច្នោះហើយទើបនាងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទស្តីពី " នីតិវិធីជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូង" មកធ្វើការបកស្រាយឲ្យកាន់តែច្បាស់លាស់អំពីការអនុវត្តនីតិវិធីនីមួយៗតាមដំណាក់កាលដើម្បីដំណើរការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូង ឲ្យកាន់តែមានភាពស៊ីជម្រៅជាពិសេសនៅពេលដែលសំណុំរឿងព្រហ្មទណ្ឌមួយបានបញ្ជូនដល់តុលាការ តើតុលាការនឹងធ្វើការចាត់ចែងរឿងសំណុំទៅតាមនីតិវិធីយ៉ាងណាខ្លះ ព្រមទាំងអនុវត្តនីតិវិធីនៃការជំនុំជម្រះបែបណាខ្លះដើម្បីស្វែងរកភាពយុត្តិធម៌ដល់ជនរងគ្រោះ ដែលបានទទួលរងនូវព្យសនៈកម្មនៃអំពើរបស់ជនជាប់ចោទ ក៏ដូចជាការផ្តន្ទាទោសលើជនជាប់ចោទទៅតាមកម្រិតទោសដែលបានបង្កជាព្យសនៈកម្មដល់ជនរងគ្រោះ។

ដូចនេះ ក្នុងនាមនាងខ្ញុំជាអ្នកចងក្រងនូវសារណាមួយនេះឡើងដោយបានខិតខំអស់ពីកំលាំងកាយ និងកំលាំងចិត្តក្នុងស្រាវជ្រាវ និងស្វែងរកនូវឯកសារមួយចំនួនដែលពាក់ព័ន្ធ ក៏ដូចជាមានអត្ថបទច្បាប់មួយចំនួនដែលមានប្រយោជន៍ក្នុងការគាំទ្រដល់សារណារបស់នាងខ្ញុំផងដែរ។ នាងខ្ញុំចងក្រងសារណានេះឡើងក្នុងគោលបំណងដើម្បីទទួលបានចំណេះដឹងឲ្យកាន់តែច្បាស់លាស់ និងបទពិសោធន៍ល្អៗ ថ្មីៗ មុននឹងបញ្ចប់ការសិក្សាដោយជោគជ័យ ក៏ដូចជាចង់ចែករំលែកចំណេះដឹង និងបទពិសោធន៍ដែលទទួលបានដល់មិត្តនិស្សិតជំនាន់ក្រោយទាំងអស់សម្រាប់ធ្វើការសិក្សាស្រាវជ្រាវ និងដើម្បីបន្សល់ទុកជាស្នាដៃរបស់នាងខ្ញុំផងដែរ។ នាងខ្ញុំក៏សូមអភ័យទោសទុកជាមុនប្រសិនបើស្នាដៃនេះមានកំហុសឆ្គងនូវរាល់ពាក្យពេជន៏ត្រង់ណាមិនសមរម្យ និងចំណុចខ្វះខាត ឬការបកស្រាយមិនទាន់បានក្បោះក្បាយត្រង់ចំណុចណាមួយនោះ នាងខ្ញុំសូមស្វាគមន៍ទទួលនូវរាល់មតិរិះគន់ដើម្បីស្ថាបនាពី

សំណាក់លោក-លោកស្រីសាស្ត្រាចារ្យ មិត្តនិស្សិត និងមិត្តអ្នកអានទាំងអស់ដោយក្ដីសោមនស្សរីករាយ ដើម្បីផ្ដល់ជាឪកាសដល់នាងខ្ញុំធ្វើការកែតម្រូវឲ្យស្នាដៃមួយនេះកាន់តែមានភាពល្អប្រសើរជាងមុន។

# មាតិកា


**ទំព័រ**

**សេចក្តីផ្តើម** ..................... ១

## ជំពូកទី១៖ ស្ថានភាពទូទៅនៃសាលាដំបូង

**ផ្នែកទី១៖ ប្រវត្តិនៃការកកើតសាលាដំបូង** ..................... ៣

**ផ្នែកទី២៖ សមាសភាព និងតួនាទីភារកិច្ចនៅសាលាដំបូង** ..................... ៤

**កថាខណ្ឌទី១**.សមាសភាពនៃអង្គសវនាការសាលាដំបូង ..................... ៤

**កថាខណ្ឌទី២**.តួនាទីភារកិច្ចនៃអង្គសវនាការ ..................... ៤

**ផ្នែកទី៣៖ សមត្ថកិច្ចជំនុំជម្រះនៃសាលាដំបូង** ..................... ៧

**កថាខណ្ឌទី១**.តុលាការព្រហ្មទណ្ឌ ..................... ៧

**កថាខណ្ឌទី២**.តុលាការរដ្ឋប្បវេណី ..................... ៨

**កថាខណ្ឌទី៣**.តុលាការពាណិជ្ជកម្ម ..................... ៨

**កថាខណ្ឌទី៤**.តុលាការការងារ ..................... ៨

## ជំពូកទី២៖ នីតិវិធីមុនពេលសវនាការនៅសាលាដំបូង

**ផ្នែកទី១៖ ការទទួលបណ្តឹងរបស់សាលាដំបូង** ..................... ៩

**កថាខណ្ឌទី១**.ដីកាបញ្ជូនទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ ..................... ៩

**កថាខណ្ឌទី២**.ដីកាបញ្ជូនទៅតុលាការជំនុំជំម្រះផ្ទាល់របស់ព្រះរាជអាជ្ញា ..................... ១០

**កថាខណ្ឌទី៣**.កំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាមដែលធ្វើដោយព្រះរាជអាជ្ញា ...... ១០

**កថាខណ្ឌទី៤**.ការកំណត់កាលបរិច្ឆេទសវនាការ ..................... ១១

**ផ្នែកទី២៖ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់** ..................... ១១

**កថាខណ្ឌទី១**.ការប្រគល់ចុងដីកាកោះហៅទៅជំនុំជម្រះដោយព្រះរាជអាជ្ញា ..................... ១៣

**កថាខណ្ឌទី២**.ការប្រគល់ចុងដីកាកោះហៅទៅជំនុំជម្រះដោយអាជ្ញាសាលា ..................... ១៣

**កថាខណ្ឌទី៣**.ការប្រគល់ចុងដីកាកោះហៅទៅជំនុំជម្រះដោយអាជ្ញាសាលាដល់មេឃុំ.. ១៣

**កថាខណ្ឌទី៤**.របៀបផ្សេងទៀតក្នុងការប្រគល់ចុងដីកាកោះហៅទៅជំនុំជម្រះ ..................... ១៤

**ផ្នែកទី៣៖ ការបញ្ជូនដីកាកោះហៅឲ្យចូលសវនាការ** ..................... ១៤

**កថាខណ្ឌទី១**.ដីកាកោះហៅជនជាប់ចោទ ..................... ១៤

១.ដីកាកោះប្រគល់ដោយព្រះរាជអាជ្ញា ..................... ១៥

២.ដីកាកោះប្រគល់ដោយអាជ្ញាសាលា ..................... ១៥

៣.ដីកាកោះប្រគល់ដោយអាជ្ញាសាលាដល់មេឃុំ ឬ ចៅសង្កាត់ ..........................១៦
៤.របៀបផ្សេងទៀតក្នុងការប្រគល់ដីកាកោះ.......................................................១៦
**កថាខណ្ឌទី២**.ដីកាកោះហៅដើមបណ្ដឹងរដ្ឋប្បវេណី ...............................................១៦
១.ដីកាកោះប្រគល់ដោយព្រះរាជអាជ្ញា ........................................................... ១៧
២.ដីកាកោះប្រគល់ដោយអាជ្ញាសាលា............................................................. ១៧
៣.ដីកាកោះប្រគល់ដោយអាជ្ញាសាលាដល់មេឃុំ ឬ ចៅសង្កាត់ .......................... ១៧
៤.របៀបផ្សេងទៀតក្នុងការប្រគល់ដីកាកោះ.......................................................១៨
**កថាខណ្ឌទី៣**.ដីកាកោះហៅជនរងគ្រោះ.................................................................១៨
១.ដីកាកោះប្រគល់ដោយព្រះរាជអាជ្ញា ............................................................១៩
២.ដីកាកោះប្រគល់ដោយអាជ្ញាសាលា..............................................................១៩
៣.ដីកាកោះប្រគល់ដោយអាជ្ញាសាលាដល់មេឃុំ ឬ ចៅសង្កាត់ ...........................១៩
៤.របៀបផ្សេងទៀតក្នុងការប្រគល់ដីកាកោះ.......................................................១៩
**កថាខណ្ឌទី៤**.ដីកាកោះហៅសាក្សី ........................................................................២០
១.ដីកាកោះប្រគល់ដោយព្រះរាជអាជ្ញា ............................................................២០
២.ដីកាកោះប្រគល់ដោយអាជ្ញាសាលា..............................................................២០
៣.ដីកាកោះប្រគល់ដោយអាជ្ញាសាលាដល់មេឃុំ ឬ ចៅសង្កាត់ ..........................២១
៤.របៀបផ្សេងទៀតក្នុងការប្រគល់ដីកាកោះ.......................................................២១
**កថាខណ្ឌទី៥**.ដីកាកោះហៅអ្នកជំនាញ...................................................................២១
១.ដីកាកោះប្រគល់ដោយព្រះរាជអាជ្ញា ........................................................... ២២
២.ដីកាកោះប្រគល់ដោយអាជ្ញាសាលា............................................................. ២២
៣.ដីកាកោះប្រគល់ដោយអាជ្ញាសាលាដល់មេឃុំ ឬ ចៅសង្កាត់ ......................... ២២
៤.របៀបផ្សេងទៀតក្នុងការប្រគល់ដីកាកោះ.......................................................២៣
**កថាខណ្ឌទី៦**.ដីកាកោះហៅអ្នកបកប្រែ...................................................................២៣
១.ដីកាកោះប្រគល់ដោយព្រះរាជអាជ្ញា ............................................................២៤
២.ដីកាកោះប្រគល់ដោយអាជ្ញាសាលា..............................................................២៤
៣.ដីកាកោះប្រគល់ដោយអាជ្ញាសាលាដល់មេឃុំ ឬ ចៅសង្កាត់ ...........................២៤
៤.របៀបផ្សេងទៀតក្នុងការប្រគល់ដីកាកោះ.......................................................២៤
**ជំពូកទី៣៖ នីតិវិធីក្នុងពេលសវនាការ**
**ផ្នែកទី១៖ ការពិភាក្សាដេញដោលក្នុងសវនាការ**.......................................................២៦

**កថាខណ្ឌទី១**.ការសួរចម្លើយជនជាប់ចោទ ..................................................... ២៧
**កថាខណ្ឌទី២**.ការការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាក្សី......... ២៨
**កថាខណ្ឌទី៣**.កំណត់ហេតុក្នុងពេលសវនាការ ..................................................... ២៩
**ផ្នែកទី២៖ ការប្រកាសសាលក្រម**..................................................... ២៩
**កថាខណ្ឌទី១**.ការតាក់តែងសាលក្រម..................................................... ៣០
**កថាខណ្ឌទី២**.ការប្រកាសសាលក្រម ..................................................... ៣១
១.សាលក្រមចំពោះមុខ ..................................................... ៣១
២.សាលក្រមកំបាំងមុខ..................................................... ៣២
៣.សាលក្រមចាត់ទុកថាចំពោះមុខ..................................................... ៣៣
**ផ្នែកទី៣៖ ដីកាឲ្យដំណឹងពីសេចក្តីសម្រេចរបស់តុលាការ** ..................................................... ៣៣
**កថាខណ្ឌទី១**.ការជូនដំណឹងដល់ជនជាប់ចោទ ..................................................... ៣៤
**កថាខណ្ឌទី២**.ការជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណី ..................................................... ៣៥
**កថាខណ្ឌទី៣**.ការជូនដំណឹងដល់ជនរងគ្រោះ ..................................................... ៣៦
**កថាខណ្ឌទី៤**.បណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍ ..................................................... ៣៧
១.បណ្តឹងទាស់ ..................................................... ៣៧
២.បណ្តឹងឧទ្ធរណ៍ ..................................................... ៣៨
**សេចក្តីសន្និដ្ឋាន**..................................................... ៤០
**អនុសាសន៍**..................................................... ៤២
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

សព្វថ្ងៃយើងសង្កេតឃើញថា ព្រះរាជាណាចក្រកម្ពុជាកាន់តែមានការអភិវឌ្ឍន៍កាន់តែឿន លឿនពីមួយថ្ងៃទៅមួយថ្ងៃជាពិសេសគឺបច្ចេកវិទ្យាថ្មីៗ និងទំនើបៗជាច្រើនដើម្បីសម្រួលដល់ការរស់នៅរបស់ប្រជាពលរដ្ឋ។ ទន្ទឹមនឹងការអភិវឌ្ឍន៍ឥតឈប់ឈរនូវគ្រប់វិស័យនេះ យើងក៏ឃើញថា បទល្មើសព្រហ្មទណ្ឌក៏កើតមានឡើងឥតឈប់ឈរជារៀងរាល់ថ្ងៃ មិនថាជាបទលហុ បទមជ្ឈិម និងបទឧក្រិដ្ឋ។ ដោយឡែកនៅពេលដែលមានបទល្មើសណាមួយកើតឡើង គឺវាបានបង្កឲ្យមាននូវភាពអសន្តិសុខ សណ្តាប់ធ្នាប់ និងគំរាមកំហែងជាខ្លាំងដល់ការរស់នៅរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានក៏ដូចជាការបង្កនូវភាពចលាចលដល់សង្គមជាតិផងដែរ។ បទល្មើសតាមគ្រប់រូបភាពវាប្រៀបបាននឹងអាវុធមួយដ៏សាហាវក្នុងការបន្ទុចបង្អាក់ការអភិវឌ្ឍន៍របស់សង្គមជាតិ។ កាលណាក្នុងប្រទេសមួយពោរពេញទៅដោយបទល្មើសនោះវាក៏សបញ្ជាក់ឲ្យឃើញពីភាពអសកម្មផ្នែកសន្តិសុខ ភាពរឹករវ សណ្តាប់ធ្នាប់ អនាធិបតេយ្យ និងកំសោយខាងប្រព័ន្ធច្បាប់។ នៅពេលដែលមានបទល្មើសកើតមានឡើងគឺមានតែតុលាការទេ ដែលជាស្ថាប័នមានសមត្ថកិច្ចក្នុងការទទួលបន្ទុកដំណើរការរឿងក្តី ព្រមទាំងធ្វើការផ្តន្ទាទោសជនល្មើសតាមច្បាប់។ ដោយសារតែមូលហេតុទាំងអស់នេះ ហើយទើបប្រទេសកម្ពុជាយើងបង្កើតឲ្យមាន សាលាដំបូងនៅគ្រប់ខេត្ត-ក្រុងក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាឲ្យបាននូវភាពយុត្តិធម៌ សុខសន្តិភាព សុវត្ថិភាព សណ្តាប់ធ្នាប់ល្អក្នុងសង្គម ក៏ដូចជាចូលរួមក្នុងការស្តារ និងអភិវឌ្ឍន៍ប្រទេសឲ្យមានការរីកចម្រើនព្រមទាំងធានាដល់ការរស់នៅរបស់ប្រជាជនគ្រប់រូបផងដែរ។ សាលាដំបូងមានសមត្ថកិច្ចទទួលនូវរាល់បណ្តឹងជាច្រើនដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ នៅក្នុងការដំណើររឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូងធ្វើឡើងតាមដំណាក់កាលនីមួយៗ គឺចាប់ពីការទទួលបានដំណឹងពីបទល្មើសណាមួយដែលប្តឹងដោយបុគ្គលណាម្នាក់មកមន្ត្រីនគរបាលយុត្តិធម៌ ហើយមន្ត្រីនគរបាលយុត្តិធម៌ធ្វើបណ្តឹងទៅព្រះរាជអាជ្ញាដើម្បីបើកការស៊ើបអង្កេតស្វែងរកប្រមូលភស្តុតាង ឬតម្រុយផ្សេងៗ សាក្សី និងពត៌មានសំខាន់មួយចំនួនដែលមានផលប្រយោជន៍ក្នុងរឿងក្តី ដើម្បីអាចឈានដល់ការកំណត់ អត្តសញ្ញាណជនល្មើស និងឈានដល់ការឃាត់ខ្លួនជនល្មើស ហើយបន្តនីតិវិធីដល់ដំណាក់កាលចៅក្រមស៊ើបសួរ ដំណាក់កាលអយ្យការធ្វើការចោទប្រកាន់ និងដល់ដំណាក់កាលជំនុំជម្រះដោយគោរពតាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។ នៅក្នុងការសិក្សាជាក់ស្តែងនាងខ្ញុំសង្កេតឃើញថា ដំណាក់ជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌពុំទាន់ឃើញមានការចងក្រងជាអត្ថបទណាមួយឲ្យបានក្បោះក្បាយនៅឡើយទេ ហើយការសិក្សាផ្នែកទ្រឹស្តីទៀតសោត ក៏មានភាពស្រពិចស្រពិលច្រើនសម្រាប់និស្សិតផ្នែកច្បាប់ទាំងអស់ធ្វើការសិក្សាស្រាវជ្រាវឲ្យលម្អិតផងដែរ។ ដោយមើល

ឃើញពីបញ្ហាខាងលើ ទើបជំរុញឲ្យនាងខ្ញុំមានបំណងធ្វើការស្រាវជ្រាវអំពីប្រធានបទ "នីតិវិធីជំនុំជម្រះរឿងក្ដីព្រហ្មទណ្ឌនៅសាលាដំបូង" ថាតើនីតិវិធីនៃការអនុវត្តការជំនុំជម្រះរឿងក្ដីព្រហ្មទណ្ឌប្រព្រឹត្តទៅយ៉ាងដូចម្ដេចខ្លះ? តើនៅមុនពេលចាប់ផ្ដើមនីតិវិធីនៃការជំនុំជម្រះនៅក្នុងពេលសវនាការមាននីតិវិធីអ្វីខ្លះ? ដើម្បីឲ្យដំណើរការជំនុំជម្រះរឿងក្ដីព្រហ្មទណ្ឌអាចប្រព្រឹត្តទៅបានដោយរលូនមានភាពឆាប់រហ័ស និងគោរពតាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ?

ការសិក្សាលើប្រធានបទនេះ នាងខ្ញុំមានគោលបំណងចម្បងចង់សិក្សាស្រាវជ្រាវ និងធ្វើការបកស្រាយឲ្យបានលម្អិតអំពីនីតិវិធីដែលតុលាការប្រើប្រាស់ក្នុងការជំនុំជម្រះរឿងក្ដី ដោយឈរលើគោលការណ៍នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

តាមរយៈការសិក្សាស្រាវជ្រាវលើសារណាមួយនេះនាងខ្ញុំសង្ឃឹមថាខ្លឹមសារដែលត្រូវបានរំលេចឡើងក្នុងសារណានេះនឹងអាចឲ្យអ្នកសិក្សាក្នុងវិស័យច្បាប់ អាចយល់ដឹងកាន់តែច្បាស់អំពីនីតិវិធីនៃការជំនុំជម្រះរឿងក្ដីព្រហ្មទណ្ឌ។

ក្នុងការស្រាវជ្រាវដើម្បីចងក្រងសារណានេះឡើង នាងខ្ញុំផ្អែកសំខាន់លើក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ជាមូលដ្ឋានបន្ថែម ជាងនេះទៅទៀតនាងខ្ញុំបានប្រមូលពត៌មានដែលទាក់ទងតាមរយៈអត្ថបទច្បាប់ អត្ថបទមេរៀននានា សៀវភៅ ឯកសារផ្សេងៗ ការសាកសួរសាស្ត្រាចារ្យណែនាំជាពិសេសការប្រឹក្សាយោបល់ជាមួយលោកចៅក្រម និងក្រឡាបញ្ជីនៃសាលាដំបូង រាជធានីភ្នំពេញដែលបាន ផ្ដល់ឪកាសដល់នាងខ្ញុំបានចុះទៅធ្វើការសិក្សាស្រាវជ្រាវ។

ដើម្បីឆ្លុះបញ្ចាំពីខ្លឹមសារ ក៏ដូចជាការឆ្លើយតបនឹងចំណោទបញ្ហាដែលបានរៀបរាប់ខាងលើនៅក្នុងសារណានេះនាងខ្ញុំបែងចែកជា៣ជំពូកគឺៈ

**ជំពូកទី១ៈ ស្ថានភាពទូទៅនៃសាលាដំបូង**

**ជំពូកទី២ៈ នីតិវិធីមុនពេលសវនាការ**

**ជំពូកទី៣ៈ នីតិវិធីក្នុងពេលសវនាការ**

# ជំពូកទី១
# ស្ថានភាពទូទៅនៃសាលាដំបូង

សាលាដំបូង គឺជាសាលាជម្រះក្តីថ្នាក់ទីមួយដែលមានទីតាំងនៅរាជធានីភ្នំពេញ និងនៅតាម បណ្តាខេត្តនៃព្រះរាជាណាចក្រកម្ពុជា។ ការដាក់ឲ្យដំណើរការសាលាដំបូងនានា ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ។ សាលាដំបូងត្រូវបានបែងចែកជាតុលាការជំនាញ។ សាលាដំបូង គឺជាសាលាជម្រះក្តីទូទៅដែលមានសមត្ថកិច្ចជំនុំជម្រះលើគ្រប់រឿងក្តីទាំងអស់ លើកលែងតែរឿងក្តីដែលស្ថិតនៅក្រោមសមត្ថកិច្ចនៃសាលាជម្រះក្តីពិសេស ឬសាលាជម្រះក្តីវិសាមញ្ញដែលបង្កើតឡើងដោយច្បាប់ដោយឡែក[១]។

សាលាដំបូងបំពេញតួនាទីរបស់ខ្លួនលើសមត្ថកិច្ចដែនដី ដោយផ្អែកលើគោលការណ៍ឯករាជ្យមិនចំណុះឲ្យស្ថាប័នណាមួយឡើយ ក្នុងគោលបំណងរក្សានូវសន្តិសុខ សណ្តាប់ធ្នាប់រៀបរយនៅក្នុងសង្គម ជាពិសេសមានតួនាទីចម្បងក្នុងការស្វែងរកនូវភាពយុត្តិធម៌ជូនប្រជាពលរដ្ឋគ្រប់រូប ដោយមិនប្រកាន់នូវ ជាតិសាសន៍ សាសនា ពណ៌សម្បុរ ទំនៀមទំលាប់ ប្រពៃណី វប្បធម៌ ភេទ ភាសា ឋានៈសង្គម និន្នាការនយោបាយ ឬស្ថានភាពណាមួយឡើយ។ តុលាការនេះបានរៀបចំរចនាសម្ព័ន្ធផ្ទៃក្នុងដោយបង្កើតឲ្យមានស្ថាប័នតុលាការ និងអង្គការអយ្យការ ចៅក្រម តំណាងអយ្យការ និងក្រឡាបញ្ជី។

## ផ្នែកទី១៖ ប្រវត្តិនៃការកកើតសាលាដំបូង

នៅក្នុងប្រទេសកម្ពុជាប្រព័ន្ធតុលាការមានការផ្លាស់ប្តូរជាច្រើនសម័យកាល គឺចាប់តាំងពីឆ្នាំ១៩៧៩ រហូតមកដល់ឆ្នាំ១៩៨៥ នៅកម្ពុជាមានតុលាការតែមួយថ្នាក់ប៉ុណ្ណោះ គឺតុលាការខេត្ត-ក្រុងដែលដើរតួនាទីជាតុលាការដំបូងក្នុងការកាត់ក្តី ឬជំនុំជម្រះក្តីលើកទីមួយ និងចុងក្រោយបង្អស់ មានន័យថា គ្រប់សាលក្រមទាំងអស់ដែលចេញដោយតុលាការនេះ មានប្រសិទ្ធិភាពក្នុងការអនុវត្ត ហើយសាលក្រមទាំងនេះត្រូវមានការត្រួតពិនិត្យដោយក្រសួងយុត្តិធម៌ និងសម្រេចចុងក្រោយដោយក្រុមប្រឹក្សារដ្ឋ ប្រសិនបើមានការស្នើរបស់ក្រសួងយុត្តិធម៌ដោយរកឃើញថាមានកំហុស។ លុះមកដល់សម័យអ៊ុនតាក់ តុលាការនៅព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតឲ្យមានពីរថ្នាក់គឺ តុលាការជាន់ទាប ដែលមានតុលាការខេត្ត-ក្រុង និងតុលាការយោធា និងតុលាការជាន់ខ្ពស់ដែលមានសាលាឧទ្ធរណ៍ និងតុលាការកំពូល។ ប៉ុន្តែមកដល់ពេលបច្ចុប្បន្នយើងឃើញថាតុលាការនៅព្រះរាជាណាចក្រកម្ពុជាត្រូវបានបែងចែកជាបីថ្នាក់ គឺតុលាការថ្នាក់ទីមួយ (សាលាដំបូងរាជធានី-ខេត្ត) តុលាការថ្នាក់ទីពីរ (សាលាឧទ្ធរណ៍) និងតុលាការកំពូល។

---

[១]មាត្រា ១២ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៤

# ផ្នែកទី២៖ សមាសភាព និងតួនាទីភារកិច្ចនៅសាលាដំបូង

## កថាខណ្ឌទី១. សមាសភាពនៃអង្គសវនាការសាលាដំបូង

សាលាដំបូងមានសមាសសភាពដូចជា[២]៖

- ប្រធាន
- អនុប្រធាន
- ចៅក្រម
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅសាលាដំបូង។

## កថាខណ្ឌទី២. តួនាទីភារកិច្ចនៃអង្គសវនាការ

### ១. ប្រធានសាលាដំបូង

ប្រធានសាលាដំបូង គឺជាអ្នកមានអំណាចក្នុងការដឹកនាំ គ្រប់គ្រងនូវរាល់វិធានទាំងឡាយសម្រាប់ដំណើរការជំនុំជម្រះរបស់សាលាដំបូង។ ប្រធានសាលាដំបូងត្រូវចេញដីកាសម្រេចដើម្បី[២]៖

- ចាត់តាំងអនុប្រធានសាលាដំបូងម្នាក់ ឬចៅក្រមណាម្នាក់ឲ្យចាត់ចែងការងារជំនួសខ្លួនក្នុងករណីចាំបាច់
- ចាត់តាំងអនុប្រធានសាលាដំបូងឲ្យទទួលបន្ទុកធ្វើជាប្រធានតុលាការជំនាញនីមួយៗដោយផ្អែកតាមជំនាញ ឬបទពិសោធន៍ការងារ។ ក្នុងករណីខ្វះ ឬពុំមានអនុប្រធាន ប្រធានសាលាដំបូងអាចចាត់តាំងចៅក្រមណាម្នាក់ ដែលមានឋានន្តរស័ក្តិខ្ពស់ ឬមានបទពិសោធន៍ច្រើនឲ្យធ្វើជាប្រធានតុលាការជំនាញបាន
- កំណត់លំដាប់សម្រាប់ជំនួសចៅក្រមនៅក្នុងតុលាការជំនាញនីមួយៗ និងនៅក្នុងក្រុមប្រឹក្សាជំនុំជម្រះនៃតុលាការជំនាញទាំងនេះ ក្នុងករណីដែលចៅក្រមណាម្នាក់អវត្តមាន ឬមានធុរៈ
- ចាត់តាំង ឬផ្លាស់ប្តូរក្រឡាបញ្ជីនៅក្នុងតុលាការជំនាញនីមួយៗ តាមសេចក្តីត្រូវការចាំបាច់ជាក់ស្តែង។

ប្រធានសាលាដំបូងមានភារកិច្ចត្រួតពិនិត្យសំណុំរឿង កំណត់កាលបរិច្ឆេទបើកសវនាការ និងធ្វើការបែងចែកសំណុំរឿងទៅចៅក្រមទាំងអស់ដែលនៅក្នុងសាលាដំបូង។

### ២. អនុប្រធានសាលាដំបូង

អនុប្រធានសាលាដំបូង គឺជាអ្នកជួយសម្រួលការងារមួយផ្នែករបស់ប្រធានសាលាដំបូង ដោយស្ថិតនៅក្រោមការដឹកនាំរបស់ប្រធាន ហើយមានតួនាទី និងភារកិច្ចប្រហាក់ប្រហែលនិងប្រធានសាលាដំបូងដែរ។

---

[២] មាត្រា ១៧ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ ២០១៤

**៣. ចៅក្រម**

ចៅក្រម គឺជាអ្នកដែលមានសិទ្ធិក្នុងការជំនុំជម្រះក្តី និងមានសិទ្ធិក្នុងការចេញសេចក្តីសម្រេចរបស់តុលាការ។ ចៅក្រមត្រូវបំពេញភារកិច្ចដោយឯករាជ្យដោយគោរពច្បាប់យ៉ាងម៉ឹងម៉ាត់ ឲ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន[៣]។ ចៅក្រមមានភារកិច្ចទទួលខុសត្រូវចំពោះកិច្ចការដែលបានប្រគល់ឲ្យ និងត្រូវគោរពឲ្យបានម៉ត់ចត់នូវក្រមសីលធម៌របស់ខ្លួន។ ការជម្រះក្តីត្រូវធ្វើឡើងដោយយុត្តិធម៌ក្នុងនាមជាប្រជារាស្ត្រខ្មែរ។ ចៅក្រម ត្រូវសម្រេចសេចក្តីដោយមិនលំអៀង ដោយឈរលើគោលការណ៍សេរី និងយុត្តិធម៌តាមនីតិវិធីច្បាប់ជាធរមាន មិនទទួលការគាបសង្កត់ ការគំរាមកំហែង ឬការបំភិតបំភ័យ ការបង្គាប់បញ្ជាដោយផ្ទាល់ ឬដោយប្រយោលពីភាគីក្នុងរឿងក្តី ឬពីបុគ្គលណាមួយឡើយ[៤]។ ចៅក្រមត្រូវបានចាត់តាំងឲ្យបំពេញការងារនៅសាលាជម្រះក្តីណាមួយសម្រាប់រយៈពេល៤ឆ្នាំ។ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចផ្លាស់ប្តូរចៅក្រមឲ្យទៅបំពេញការងារកន្លែងណាមួយផ្សេងទៀតបាន ក្នុងករណីចៅក្រមនោះមានទោសវិន័យថ្នាក់ទី២ដូចមានចែងក្នុងមាត្រា៥៥ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឬទៅតាមតំរូវការចាំបាច់ដើម្បីដំណើរការល្អនៃយុត្តិធម៌[៥]។

**៤. ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង**

ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង ជាតំណាងអង្គការអយ្យការអមតុលាការនេះ[៦]។ ព្រះរាជអាជ្ញាមានភារកិច្ចទទួលខុសត្រូវចំពោះកិច្ចការដែលបានប្រគល់ឲ្យ និងត្រូវគោរពឲ្យបានម៉ត់ចត់នូវក្រមសីលធម៌របស់ខ្លួន។ អង្គការអយ្យការ គឺជាម្ចាស់បណ្តឹងអាជ្ញា ជាស្ថាប័នតំណាងឲ្យរដ្ឋជាស្ថាប័នការពារនូវសិទ្ធិសេរីភាពបុគ្គល ការពារផលប្រយោជន៍ជាសាធារណៈដែលស្ថាប័ននេះមានតួនាទីក្នុងការចោទប្រកាន់ដោយធ្វើឡើងតាមរយៈការធ្វើបណ្តឹងអាជ្ញា ចំពោះសិទ្ធិក្នុងការធ្វើបណ្តឹងអាជ្ញានេះដែរ គឺមានតែអង្គការអយ្យការតែមួយប៉ុណ្ណោះដែលមានសិទ្ធិ[៧]។

ព្រះរាជអាជ្ញា គឺជាអ្នកទទួលបណ្តឹងបរិហារ ឬបណ្តឹងទាមទារពីមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងពីជនដទៃទៀតដែលបានដឹង ឬបានឃើញពីបទល្មើសព្រហ្មទណ្ឌ។ ព្រះរាជអាជ្ញា ត្រូវចាត់វិធានការលើពាក្យបណ្តឹងព្រហ្មទណ្ឌដែលទទួលបានដោយផ្ទាល់ពីមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌តាមនីតិវិធីដែលបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដោយកំណត់ពីប្រភេទនៃបទល្មើសព្រមទាំងវត្ថុតាងដែលពាក់ព័ន្ធដើម្បីដាក់បន្ទុក។

---

[៣] មាត្រា ៦ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ ២០១៤

[៤] មាត្រា ៨ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

[៥] មាត្រា ៩ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

[៦] មាត្រា ៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៧] មាត្រា ១៣១ថ្មី នៃច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

ព្រះរាជអាជ្ញាមានសិទ្ធិក្នុងការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងមានសិទ្ធិស្នើសុំឲ្យតុលាការដាក់ទោសជនជាប់ចោទដោយអនុវត្តតាមច្បាប់ ទាំងនៅដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ។

តំណាងអយ្យការត្រូវមានវត្តមាននៅពេលសវនាការរឿងព្រហ្មទណ្ឌជានិច្ច និងធានាការអនុវត្តសេចក្តីសម្រេចរឿងព្រហ្មទណ្ឌ និងយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន។

ក្រៅពីសិទ្ធិទាំងអស់ខាងលើ ព្រះរាជអាជ្ញាអាចដឹកនាំ និងសម្របសម្រួលសកម្មភាពបំពេញការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ការអនុវត្តន៍ដីកាសម្រេចចាត់ឲ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ។ ព្រះរាជអាជ្ញាអាចប្រើប្រាស់អំណាចទាំងអស់ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានទទួលស្គាល់ឲ្យដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត។

ព្រះរាជអាជ្ញាអាចចុះទៅកាន់កន្លែងស៊ើបអង្កេត និងធ្វើគ្រប់ការណែនាំដែលមានប្រយោជន៍ដល់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌។ ក្នុងករណីចាំបាច់ពិសេស ព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបចំជំនួសមន្ត្រី និងភ្នាក់ងារនេះ។

ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលា នៅអង្គភាពនគរបាលយុត្តិធម៌ព្រះរាជអាជ្ញាអាចចូលរួមក្នុងការស្តាប់ចម្លើយអាចត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ជាពិសេសគឺការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន[៤]។

ព្រះរាជអាជ្ញារងដែលស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា ប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើស[៥]។

**៥. ក្រឡាបញ្ជី**

ក្រឡាបញ្ជី គឺជាមន្ត្រីរាជការក្របខណ្ឌក្រសួងយុត្តិធម៌ដែលមានតួនាទីជាជំនួយការរបស់ព្រះរាជអាជ្ញា និងចៅក្រមនៅគ្រប់ដំណាក់កាល។ ក្រឡាបញ្ជីមានភារកិច្ចទទួលខុសត្រូវចំពោះកិច្ចការដែលបានប្រគល់ឲ្យ និងត្រូវគោរពឲ្យបានម៉ត់ចត់នូវក្រមសីលធម៌របស់ខ្លួន។ ក្រមនីតិវិធីព្រហ្មទណ្ឌ បានប្រគល់តួនាទីចម្បងដល់ក្រឡាបញ្ជីជាអ្នកធ្វើកំណត់ហេតុស្តាប់ចម្លើយនៅដំណាក់កាលអយ្យការ កំណត់ហេតុស្តាប់ ឬ សួរចម្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ និងជាអ្នកធ្វើកំណត់ហេតុសវនាការនៅដំណាក់កាលជំនុំជម្រះ និងការប្រកាសសាលក្រម។

ក្រឡាបញ្ជី ជាអ្នកកត់ត្រារាល់ពតិមានតាមរយៈការសាកសួរ ឬស្តាប់ចម្លើយរបស់ជនជាប់ចោទ ឬដើមបណ្តឹង ឬសាក្សី ក្នុងកំណត់ហេតុដែលមានការដឹកនាំធ្វើកំណត់ហេតុដោយព្រះរាជអាជ្ញា។ នៅលើកំណត់ហេតុត្រូវមានចុះហត្ថលេខារបស់ក្រឡាបញ្ជីអមតំណាងអយ្យការ។

[៤]មាត្រា ៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៥]មាត្រា ៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

ក្រឡាបញ្ជី ជាអ្នកអមចៅក្រមស៊ើបសួរជានិច្ច ដើម្បីសម្រួលការងារចៅក្រមស៊ើបសួរ។ ប៉ុន្តែក្នុងករណីណាក៏ដោយ ក្រឡាបញ្ជីមិនអាចបំពេញកិច្ចដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរបានទេ[10]។ ក្រឡាបញ្ជីជាអ្នករក្សាទុកសំណុំរឿងស៊ើបសួរ ដែលចៅក្រមស៊ើបសួររបស់ខ្លួនបានធ្វើចំណាត់ការ។ កាលណាសំណុំរឿងបាត់ ក្រឡាបញ្ជីជាអ្នកទទួលខុសត្រូវដោយអាចប្រឈមនឹងវិន័យរដ្ឋបាលពីក្រសួងយុត្តិធម៌។ សំណុំរឿងស៊ើបសួរត្រូវរក្សាទុកដោយក្រឡាបញ្ជី។ ក្រឡាបញ្ជីចម្លងលិខិតនីមួយៗនៃសំណុំរឿងតាមលទ្ធភាពដែលអាចធ្វើបាន។

សំណុំរឿង និងសំណុំលិខិតដែលបង្ការទុកត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៅមន្ទីរចៅក្រមស៊ើបសួរ ឬនៅក្នុងបន្ទប់ណាមួយនៃតុលាការដែលមានសន្តិសុខគ្រប់គ្រាន់។

គ្រប់លិខិតនៃសំណុំរឿង ត្រូវតែបង់លេខដោយក្រឡាបញ្ជីតាមលំដាប់នៃកាលប្បវត្តិ[11]។

ក្រឡាបញ្ជី ក៏ជាអ្នកថតសំណុំរឿងឲ្យទៅមេធាវី ដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ហើយមេធាវីជាអ្នកបង់សោហ៊ុយថតចម្លង។

ក្រឡាបញ្ជី ជាអ្នកកត់ត្រានូវកំណត់ហេតុសវនាការនូវរាល់សំនួរ-ចម្លើយចាប់តាំងពីពេលសវនាការរហូតដល់បញ្ចប់។ ក្រឡាបញ្ជីត្រូតពិនិត្យមើលវត្តមានភាគីពាក់ព័ន្ធនៅពេលមុនសវនាការ អានកំណត់ហេតុនានា ដើម្បីអាចឲ្យសាធារណជនបានដឹងពីអង្គហេតុ។

## ផ្នែកទី៣៖ សមត្ថកិច្ចជំនុំជំរះនៃសាលាដំបូង

សាលាដំបូងមានសមត្ថកិច្ចជំនុំជម្រះរឿងក្តី ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែរឿងក្តីទាំងឡាយណាដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឲ្យសាលាជម្រះក្តីផ្សេងទៀត។

ក្នុងករណីចាំបាច់ ដើម្បីធានាប្រយោជន៍សាធារណៈ សុវត្ថិភាព សន្តិសុខសង្គម និងដំណើរការល្អនៃយុត្តិធម៌តុលាការ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចសម្រេចផ្ទេរសមត្ថកិច្ចក្នុងការចាត់ការរឿងក្តីពីសាលាដំបូងមួយទៅសាលាដំបូងមួយទៀតបាន[12]។

### កថាខណ្ឌទី១. តុលាការព្រហ្មទណ្ឌ

តុលាការព្រហ្មទណ្ឌនៃសាលាដំបូងជម្រះរឿងក្តីព្រហ្មទណ្ឌ ដោយចៅក្រមទោល ឬដោយក្រុមប្រឹក្សាជំនុំជម្រះ ដោយអនុលោមតាមបទបញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ។

មន្ទីរស៊ើបសួរនៃសាលាដំបូង គឺជាផ្នែកមួយនៃតុលាការព្រហ្មទណ្ឌ និងមានសមត្ថកិច្ចស៊ើបសួររឿងព្រហ្មទណ្ឌ ដោយអនុលោមតាមបទបញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ប្រធានសាលាដំបូងត្រូវចាត់តាំងចៅក្រមយ៉ាងតិច២រូប តាមដីកាសម្រេចឲ្យបំពេញតួនាទីជាចៅក្រមស៊ើបសួរនៅមន្ទីរស៊ើបសួរនៃតុលាការព្រហ្មទណ្ឌនៃសាលាដំបូង។ ដីកាសម្រេចនេះ ត្រូវកំណត់អំពីលំដាប់លេខរៀងសម្រាប់ការទទួលបំពេញការងារ។ ក្នុងករណីដែលពុំមានចៅក្រមស៊ើប ឬខ្វះចៅក្រមស៊ើបសួរ ប្រធានសាលាដំបូងអាចចាត់តាំងចៅក្រមនៃតុលាការជំនាញផ្សេង ដើម្បីបំពេញមុខងារស៊ើបសួរ។

---

[10]មាត្រា ១២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[11]មាត្រា ១២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[12]មាត្រា ១៩ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ ២០១៤

ករណីចាំបាច់ ចៅក្រមស៊ើបសួរអាចបំពេញការងារជាចៅក្រមនៅតុលាការជំនាញផ្សេងទៀត បានតាមការចាត់តាំងរបស់ប្រធានសាលាដំបូង [១៣]។

**កថាខណ្ឌទី២. តុលាការរដ្ឋប្បវេណី**

តុលាការរដ្ឋប្បវេណីនៃសាលាដំបូងជម្រះរឿងក្តីរដ្ឋប្បវេណីដោយចៅក្រមទោល ឬដោយក្រុមប្រឹក្សាជំនុំជម្រះ ដោយអនុលោមតាមបទបញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី[១៤] ។

**កថាខណ្ឌទី៣. តុលាការពាណិជ្ជកម្ម**

តុលាការពាណិជ្ជកម្មជំនុំជម្រះដោយចៅក្រម៣រូប និងអមដោយទីប្រឹក្សា២រូបជាពាណិជ្ជករ ឬអ្នកដែលមានចំណេះដឹងផ្នែកច្បាប់ពាណិជ្ជកម្ម ក្នុងករណីរឿងក្តីពាណិជ្ជកម្មដែលមានកម្មវត្ថុបណ្តឹងមានតម្លៃចាប់ពី ១.០០០.០០០.០០០ (មួយពាន់លាន)រៀលឡើងទៅ។

តុលាការពាណិជ្ជកម្មជំនុំជម្រះដោយចៅក្រម១រូប និងអមដោយទីប្រឹក្សា២រូបជាពាណិជ្ជករ ឬអ្នកដែលមានចំណេះដឹងផ្នែកច្បាប់ពាណិជ្ជកម្ម ក្នុងករណីរឿងក្តីពាណិជ្ជកម្មដែលមានកម្មវត្ថុបណ្តឹងមានតម្លៃចាប់ពី ១០០.០០០.០០០ (មួយរយលាន)រៀល ដល់ក្រោម ១.០០០.០០០.០០០ (មួយពាន់លាន)រៀល។

តុលាការពាណិជ្ជកម្មជំនុំជម្រះដោយចៅក្រម១រូបដោយមិនបាច់អមទីប្រឹក្សាពាណិជ្ជកម្មក្នុងករណីកម្មវត្ថុនៃតម្លៃក្រោម ១០០.០០០.០០០ (មួយរយលាន)រៀល។

សាលក្រមរបស់តុលាការពាណិជ្ជកម្មត្រូវសម្រេចដោយចៅក្រម១រូប ឬ ចៅក្រម៣រូប ក្រោយពីបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាពាណិជ្ជកម្ម [១៥]។

**កថាខណ្ឌទី៤. តុលាការការងារ**

តុលាការការងារនៃសាលាដំបូងត្រូវជំនុំជម្រះដោយចៅក្រម១រូប អមដោយទីប្រឹក្សាការងារ២រូប ដែល១រូបជាកម្មករនយោជិត និង១រូបទៀតជានិយោជក។

សាលក្រមរបស់តុលាការការងារត្រូវសម្រេចដោយចៅក្រម១រូប ឬ ចៅក្រម៣រូប ក្រោយពីបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាការងារ[១៦]។

[១៣]មាត្រា ២០ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ ២០១៤

[១៤]មាត្រា ២១ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ ២០១៤

[១៥]មាត្រា ២៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ ២០១៤

[១៦]មាត្រា ២៦ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ ២០១៤

# ជំពូកទី២
# នីតិវិធីមុនពេលសវនាការ

នៅក្នុងនីតិវិធីមុនពេលសវនាការគឺជា នីតិវិធីនៃការទទួលបណ្តឹងដែលបញ្ជូនមកដោយចៅក្រមស៊ើបសួរនៃសាលាដំបូង ឬតំណាងអយ្យការអមសាលាដំបូងដើម្បីចាប់ផ្តើមនីតិវិធីនៃការជំនុំជម្រះ។ នីតិវិធីលំអិតនៃការទទួលបណ្តឹងមានខ្លឹមសារដូចខាងក្រោមនេះ៖

## ផ្នែកទី១៖ ការទទួលបណ្តឹងរបស់សាលាដំបូង

ចំពោះរឿងព្រហ្មទណ្ឌតុលាការជាន់ដំបូងទទួលបណ្តឹងតាមរយៈ៖

- ដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ
- ដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ដោយព្រះរាជអាជ្ញា
- កំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាម ធ្វើឡើងដោយព្រះរាជអាជ្ញា។

ដូចនេះនៅក្នុងរឿងព្រហ្មទណ្ឌការបញ្ជូនសំណុំរឿងទៅតុលាការដើម្បីធ្វើការជំនុំជម្រះជាសមត្ថកិច្ចរបស់ ចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរ និងព្រះរាជាអាជ្ញាដែលធ្វើឡើងតានរយៈដីកាខាងលើ។

នៅពេលដែលតុលាការទទួលបានបណ្តឹងដោយការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដោយដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ និងដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ដោយព្រះរាជអាជ្ញា ដោយប្រធានតុលាការត្រូវគិតគូរតាមរយៈពេលដែលមានចែងនៅក្នុងមាត្រា ៤៥៧ និងមាត្រា៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។ លើកលែងតែក្នុងករណីនីតិវិធីនៃការចូលបង្ហាញខ្លួនភ្លាម ប្រធានតុលាការជាអ្នកកំណត់កាលបរិច្ឆេទសវនាការ។ ប្រធានតុលាការជាអ្នកត្រួតពិនិត្យលើរឿងក្តីទាំងអស់ដែលតុលាការទទួលបាន ព្រមទាំងធ្វើការចាត់តាំងចៅក្រមជំនុំជម្រះ ឬក្រុមប្រឹក្សាជំនុំជម្រះ ដើម្បីទទួលបន្ទុកក្នុងការជំនុំជម្រះ។

ក្នុងករណីដែលចៅក្រមទទួលបន្ទុករឿងក្តីមានធុរៈ ឬស្ថិតនៅក្នុងស្ថានភាពដែលមិនអាចបំពេញមុខងារបាន ចៅក្រមលំដាប់បន្ទាប់អាចទទួលរឿងក្តីជំនួសបាន។ ចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះមានមុខងារបែងចែកដាច់ពីគ្នា មានន័យថាចៅក្រមស៊ើបសួរមិនអាចបំពេញមុខងារជាចៅក្រមជំនុំជម្រះលើរឿងក្តីដែលខ្លួនបានស៊ើបសួរឡើយ បើមិនដូច្នោះទេសាលក្រមនឹងត្រូវចាត់ទុកជាមោឃៈ។

### កថាខណ្ឌទី១. ដីកាបញ្ជូនទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរ សម្រេចបញ្ជូនដីកាទៅជំនុំជម្រះនៅតុលាការជាន់ដំបូងបន្ទាប់ពីការបើកការស៊ើបអង្កេត និងស៊ើបសួរត្រូវបានបិទបញ្ចប់ដោយចៅក្រមស៊ើបបានកំណត់ពីបទល្មើស អត្តសញ្ញាណជនជាប់ចោទ និងប្រមូលបានវត្ថុតាងគ្រប់គ្រាន់ដើម្បីកសាងសំណុំរឿងបញ្ជូនឡើងទៅតុលាការចាត់ការតាមនីតិវិធី។ ការបញ្ជូនដីកាទៅជំនុំជម្រះចៅក្រមស៊ើបសួរដាក់ភ្ជាប់មកនូវឯកសារសំខាន់ៗក្នុងការដំណើរការជំនុំជម្រះដូចជា៖

- ពាក្យបណ្តឹង
- លិខិតប្រគល់សិទ្ធិជាមេធាវីតំណាងអាណត្តិ

- ដីកាបញ្ជូនរឿងឲ្យស៊ើបសួរ
- ដីកាបញ្ជូនសំណុំរឿងឲ្យពិនិត្យ
- ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ
- ដីការសន្និដ្ឋានស្ថាពរ
- ដីកាកោះហៅជនជាប់ចោទ
- លិខិតជូនដំណឹងដល់មេធាវីតំណាងដោយអាណត្តិ
- ដីកាបង្គាប់ឲ្យចូលខ្លួន
- ដីកាបង្គាប់ឲ្យនាំខ្លួន
- ដីកាបង្គាប់ឲ្យឃុំខ្លួន
- កំណត់ហេតុសួរចម្លើយជនជាប់ចោទ
- កំណត់ហេតុស្តីពីការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី
- ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

**កថាខណ្ឌទី២ ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់របស់ព្រះរាជអាជ្ញា**

ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់របស់ព្រះរាជអាជ្ញា គឺជាដីកាដែលព្រះរាជាអាជ្ញាចោទប្រកាន់បញ្ជូនសំណុំរឿងទៅជំនុំជម្រះផ្ទាល់ចំពោះបទល្មើសជាក់ស្តែង ដែលទណ្ឌកម្មកំណត់ក្នុងច្បាប់មិនលើសពី១ឆ្នាំ ឬមិនលើសពី៥ឆ្នាំ ហើយមានភស្តុតាង និងធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់។

ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ គឺជានីតិវិធីមួយដែលតុលាការទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាអាចយកមកអនុវត្តបានចំពោះ បទមជ្ឈឹមតូចតាច និងបទលហុហើយសំណុំរឿងវាមានលក្ខណៈគ្រប់គ្រាន់អាចជំនុំជម្រះបានទោះបីជាជនជាប់ចោទជានីតិជន ឬ អនីតិជនក៏អាចអនុវត្តតាមនីតិវិធីនេះបានដែរ។ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមាននិទ្ទេសដូចជា៖

- លេខសំណុំរឿង និងកាលបរិច្ឆេទ
- អត្តសញ្ញាណនៃជនជាប់ចោទ
- សេចក្តីសង្ខេបនៃអង្គហេតុ
- បទល្មើសដែលត្រូវបានចោទប្រកាន់
- អត្ថបទច្បាប់ដែលបានកំណត់ និងបង្ក្រាបបទល្មើស
- តុលាការដែលមានសមត្ថកិច្ចជំនុំជម្រះ
- ហត្ថលេខារបស់ព្រះរាជអាជ្ញា
- ការបញ្ជាក់សិទ្ធិរបស់ជនជាប់ចោទអាចពឹងមេធាវីឲ្យអមខ្លួនបាន

**កថាខណ្ឌទី៣. កំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាមដែលធ្វើដោយព្រះរាជអាជ្ញា**

កំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាមដែលធ្វើដោយព្រះរាជអាជ្ញា គឺព្រះរាជអាជ្ញាអាចបង្គាប់ឲ្យជាប់ចោទចូលមកបង្ហាញខ្លួនភ្លាមនៅចំពោះមុខតុលាការជាន់ដំបូង ប្រសិនបើបទល្មើសជាបទល្មើសជាក់ស្តែង ដែលការផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច១ឆ្នាំ និងយ៉ាងច្រើន៥ឆ្នាំ ជនជាប់

ចោទជានីតិជន និងរឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមអាចជំនុំជម្រះបាន។ និទ្ទេសនៃទម្រង់ការនេះ ត្រូវចុះនៅក្នុងកំណត់ហេតុ បើពុំដូច្នោះទេ នីតិវិធីត្រូវចាត់ទុកថាមោឃៈ។

ព្រះរាជអាជ្ញាជ្រើសរើសនីតិវិធីនេះ គឺដើម្បីពន្លឿនដំណើរការរឿងក្តីឲ្យមានភាពឆាប់រហ័ស និងសម្រួលដល់ការកកស្ទះរឿងក្តី។ នីតិវិធីនៃការបង្ហាញខ្លួនភ្លាមនេះ ជនជាប់ចោទស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នដែលមានអមដោយកងកម្លាំងការពារ រហូតដល់ជនជាប់ចោទចូលបង្ហាញខ្លួននៅចំពោះមុខតុលាការដែលបើកសវនាការនាថ្ងៃនោះតែម្តង។

នៅក្នុងកំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាមមាននិទ្ទេសដូចជាៈ

- លេខសំណុំរឿង និងកាលបរិច្ឆេទ
- អត្តសញ្ញាណនៃជនជាប់ចោទ
- កាលបរិច្ឆេទ និងទីន្លែងកំណើតរបស់ជនជាប់ចោទ
- ទីលំនៅរបស់ជនជាប់ចោទ
- បទល្មើសដែលត្រូវបានចោទប្រកាន់
- កាលបរិច្ឆេទ ម៉ោងដែលត្រូវបង្ហាញខ្លួន
- ទីកន្លែងដែលត្រូវចូលបង្ហាញខ្លួន
- ស្នាមមេដៃរបស់ជនជាប់ចោទ
- ហត្ថលេខារបស់ព្រះរាជអាជ្ញា

នៅក្នុងកំណត់ហេតុនេះមានបញ្ជាក់ថាជនជាប់ចោទមានសិទ្ធិសុំពឹងមេធាវីតាមការជ្រើសរើសរបស់ជនជាប់ចោទ ឬស្នើសុំឲ្យមានការចាត់តាំងមេធាវីដោយអនុលោមតាមបញ្ញត្តិច្បាប់។

**កថាខណ្ឌទី៤. ការកំណត់កាលបរិច្ឆេទសវនាការ**

កាលបរិច្ឆេទនៃសវនាការត្រូវកំណត់ដោយប្រធានតុលាការ លើកលែងតែករណីនៃនីតិវិធីចូលបង្ហាញខ្លួនភ្លាម។ នៅក្នុងករណីដែលតុលាការបានទទួលបណ្តឹងដោយការបញ្ជូនទៅជំនុំជម្រះផ្ទាល់ដោយដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ប្រធានតុលាការត្រូវតែគិតគូរតាមរយៈពេលដែលមានចែងក្នុងមាត្រា ៤៥៧ (រយៈពេលដែលត្រូវគោរពរវាងការប្រគល់ដីកាកោះហៅ បញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឲ្យចូលបង្ហាញខ្លួន) និងមាត្រា ៤៦៦ (រយៈពេលដែលត្រូវគោរពរវាងដីកាកោះហៅ និងការបង្គាប់ឲ្យចូលបង្ហាញខ្លួន) នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ដើម្បីកំណត់កាលបរិច្ឆេទសវនាការ។ កាលបរិច្ឆេទនេះត្រូវជូនដំណឹងដោយផ្ទាល់មាត់ដល់ព្រះរាជអាជ្ញា[១៧]។

## ផ្នែកទី២ៈ ការបញ្ជូនដីកាកោះហៅទៅជំនុំជម្រះផ្ទាល់

នៅក្នុងច្បាប់ព្រហ្មទណ្ឌបទល្មើសត្រូវបានបែងចែកជាបីគឺបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ។ ដោយឡែកដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺយកមកអនុវត្តតែទៅលើបទល្មើសៈ

❖ បទលហុគឺជា បទល្មើសដែលមានស្ថានទម្ងន់ទោសដាក់ពន្ធនាគារក្រោម ឬស្មើ៦ថ្ងៃ ឬត្រឹមមានទោសពិន័យជាប្រាក់ប៉ុណ្ណោះ។

[១៧]មាត្រា២៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

❖ បទមជ្ឈឹមគឺជា បទល្មើសដែលមានស្ថានទម្ងន់ដាក់ពន្ធនាគារលើសពី៦ថ្ងៃ និងក្រោម ឬស្មើនឹង៥ឆ្នាំ និងមានបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។

❖ ដើមដីកាដែលមានចុះកាលបរិច្ឆេទ ទីកន្លែងកំណើត និងលំនៅឋានរបស់ជនជាប់ចោទ ត្រូវតែមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា។

**សំគាល់៖** បទមជ្ឈឹមទាំងអស់មិនមែនសុទ្ធតែត្រូវអនុវត្តតាមនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ទាំងអស់នោះទេ។ ព្រះរាជអាជ្ញាជ្រើសរើសយកការបញ្ជូនទៅជំនុំជម្រះផ្ទាល់គឺ ព្រះរាជអាជ្ញាបានកំណត់យ៉ាងច្បាស់លាស់នូវអត្តសញ្ញាណជនជាប់ចោទ ប្រមូលបានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ និងជាបទល្មើសជាក់ស្តែង។

បទល្មើសដែលអាចចាត់ទុកថាជាបទល្មើសជាក់ស្តែងគឺ៖

- បទល្មើសដែលកំពុងតែប្រព្រឹត្ត
- បទល្មើសដែលទើបតែប្រព្រឹត្តរួចភ្លាមៗ
- ជនដែលគេសង្ស័យ ត្រូវបានសាធារណជនកំពុងតែស្រែកដេញចាប់ប្រភាប់ចាប់ប្រភឹង
- ជនដែលត្រូវបានគេរកឃើញថាមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ហើយមានភាពស៊ីសង្វាក់ទៅនឹងរឿងក្តី ដែលអាចឲ្យគេសន្និដ្ឋានថា ជននោះបានប្រព្រឹត្ត ឬបានចូលរួមក្នុងការប្រព្រឹត្តបទល្មើស[18]។

**ឧទាហរណ៍៖** បុគ្គល "ក" ជាមុខសញ្ញាជួញដូរគ្រឿងញៀនដែលសមត្ថកិច្ចកំពុងធ្វើការតាមដាន។ ថ្ងៃមួយបុគ្គល "**ក**" កំពុងតែធ្វើការលក់គ្រឿងញៀនទៅឲ្យបុគ្គល "**ខ**" ដែលជាអ្នកប្រើប្រាស់គ្រឿងញៀន ស្របពេលនោះក៏ត្រូវបានសមត្ថកិច្ចចុះទៅបង្ក្រាបបាននៅនឹងកន្លែង រួចសមត្ថកិច្ចក៏ធ្វើកំណត់ហេតុបញ្ជូនជននោះទៅព្រះរាជអាជ្ញាដើម្បីធ្វើការចោទប្រកាន់បញ្ជូនដីកាទៅតុលាការធ្វើការជំនុំជម្រះផ្ទាល់។ ព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់បុគ្គល "**ក**" និងបុគ្គល "**ខ**" ពីបទជួញដូរ និងប្រើប្រាស់គ្រឿងញៀន ដោយយោងតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់មាននិទ្ទេសដូចជា៖

- អត្តសញ្ញាណនៃជនជាប់ចោទ
- សេចក្តីសង្ខេបនៃអង្គហេតុ
- ឈ្មោះបទល្មើស
- អត្ថបទច្បាប់ដែលកំណត់ នឹងបង្ក្រាបបទល្មើស។
- តុលាការជំនុំជម្រះ
- កាលបរិច្ឆេទ និងម៉ោងពេលសវនាការ

ដីកានេះត្រូវបញ្ជាក់ថា ជនជាប់ចោទអាចពឹងពាក់មេធាវីឲ្យអមខ្លួនបាន[19]។

---

[18]មាត្រា៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[19]មាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

សម្រាប់រយៈពេលដែលត្រូវគោរពក្នុងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដល់ជនជាប់ចោទឲ្យបង្ហាញខ្លួននៅចំពោះមុខតុលាការត្រូវកំណត់ដូចតទៅ[២០]៖

- ១៥ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់សាលាដំបូង
- ២០ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ
- ២ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជា។
- ៣ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងផ្សេងទៀត។

នីតិវិធីនៃការបញ្ជូនដីកាកោះហៅទៅជំនុំជម្រះផ្ទាល់ទៅ ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី អ្នកបកប្រែ និងអ្នកជំនាញ៖

**កថាខណ្ឌទី១. ការប្រគល់ចុងដីកាកោះហៅទៅជំនុំជម្រះដោយព្រះរាជអាជ្ញា**

ព្រះរាជអាជ្ញា គឺជាអ្នកធ្វើបណ្ដឹងអាជ្ញា និងធ្វើការចោទប្រកាន់ដាក់បន្ទុក ឬដោះបន្ទុកដើម្បីការពារផលប្រយោជន៍សង្គម។ ព្រះរាជអាជ្ញាអាចប្រគល់ចុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដល់ជនជាប់ចោទដោយផ្ទាល់ដៃ។ ព្រះរាជអាជ្ញាចុះនិទ្ទេសស្ដីពីកាលបរិច្ឆេទនឹងទីកន្លែងប្រគល់ដីកានៅដើមដីកា។ ជនជាប់ចោទត្រូវចុះហត្ថលេខានៅដើមដីកានោះ[២១]។

**កថាខណ្ឌទី២. ការប្រគល់ចុងដីកាកោះហៅទៅជំនុំជម្រះដោយអាជ្ញាសាលា**

អាជ្ញាសាលាត្រូវប្រគល់ចុងដីកាកោះហៅទៅដល់លំនៅឋានរបស់ជនជាប់ចោទដែលកំពុងស្នាក់នៅ ឬនៅកន្លែងផ្សេងទៀតដែលអាជ្ញាសាលាបានជួបប្រទះជនជាប់ចោទ។ អាជ្ញាសាលាចារនៅដើមដីកាកោះហៅថា ចុងដីកានេះត្រូវបានប្រគល់ដល់ជនជាប់ចោទដោយផ្ទាល់ដៃ។ អាជ្ញាសាលាចុះនិទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់ដីកាកោះហៅ។ ជនជាប់ចោទត្រូវចុះហត្ថលេខានៅលើដើមដីកា។

ដើមដីកាកោះហៅនេះត្រូវបង្វិលជូនមកព្រះរាជអាជ្ញាវិញភ្លាម[២២]។ ករណីដែលជនជាប់ចោទ អវត្តមានពីលំនៅឋាន អាជ្ញាសាលាអាចប្រគល់ចុងដីកាកោះទៅដល់បុគ្គលណាជានីតិជនមានវត្តមាននៅក្នុងលំនៅឋាន។ អាជ្ញាសាលាចុះនិទ្ទេសអំពីអត្តសញ្ញាណនៃបុគ្គលនេះ និងអំពីកាលបរិច្ឆេទនៃការប្រគល់ដីកាកោះ។ បុគ្គលដែលទទួលចុងដីកាកោះត្រូវចុះហត្ថលេខានៅលើដើមដីកា។ ដើមដីកាកោះហៅនេះត្រូវបង្វិលជូនមកព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលទទួលដីកាកោះត្រូវសន្យាថានឹងប្រគល់ដីកានេះដល់ជនជាប់ចោទក្នុងរយៈពេលខ្លីបំផុត[២៣]។

**កថាខណ្ឌទី៣. ការប្រគល់ចុងដីកាកោះហៅទៅជំនុំជម្រះដោយអាជ្ញាសាលាដល់មេឃុំ**

អាជ្ញាសាលាអាចប្រគល់ចុងដីកាឲ្យមេឃុំ ឬចៅសង្កាត់ ឬជំទប់ក្នុងករណី៖

- ជនជាប់ចោទមិនព្រមទទួលដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។
- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទ។

---

[២០]មាត្រា ៤៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[២១]មាត្រា ៤៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[២២]មាត្រា ៤៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[២៣]មាត្រា ៤៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

• គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទយល់ព្រមទទួលដីកាកោះទេ។

អាជ្ញាសាលាចុះនិទ្ទេសនៅលើដើមដីកាអំពីអត្តសញ្ញាណ និងឋានៈបុគ្គលដែលបានទទួលចុងដីកាព្រមទាំងកាលបរិច្ឆេទនៃការប្រគល់ដីកា។ បុគ្គលដែលទទួលដីកាត្រូវចុះហត្ថលេខានៅលើដើមដីកា។ ដើមដីកាត្រូវបង្វិលត្រឡប់ជូនព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលបានទទួលដីកាត្រូវសន្យាថា នឹងប្រគល់ដីកានេះក្នុងរយៈពេលដ៏ខ្លីបំផុតឲ្យដល់ជនជាប់ចោទ[២៤]។

**កថាខណ្ឌទី៤. របៀបផ្សេងទៀតក្នុងការប្រគល់ចុងដីកាកោះហៅទៅជំនុំជម្រះ**

ដីកាកោះហៅក៏អាចត្រូវប្រគល់តាមរយៈ

• ដោយក្រឡាបញ្ជី

• តាមអាជ្ញាធររដ្ឋបាល

• ដោយប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវជាប់ឃុំខ្លួនពីបទផ្សេងទៀត

• តាមរយៈអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ

ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល ប្រធានពន្ធនាគារ មន្ត្រីនគរបាលជាតិ ឬ អាវុធហត្ថត្រូវគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញាក្នុងការប្រគល់ដីកាកោះនោះ។ ចុងដីកាកោះហៅត្រូវភ្ជាប់ជាមួយនូវលិខិតថតចម្លងមួយច្បាប់នៃដីកាបញ្ជូនរឿងទៅតុលាការជំនុំជម្រះ[២៥]។

ក្នុងករណីដែលនីតិវិធីនៃការបញ្ជូនជនជាប់ចោទទៅជំនុំជម្រះ ដោយដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់របស់ព្រះរាជអាជ្ញាវាមានលក្ខណៈគ្រប់គ្រាន់ មិនចាំបាច់ចេញដីកាកោះហៅឲ្យចូលសវនាការទៀតទេព្រោះនៅក្នុងដីកាបញ្ជូនទៅជំនុំជម្រះមានបញ្ជាក់ពីកាលបរិច្ឆេទសវនាការ និងតុលាការដែលមានសមត្ថកិច្ចរួចហើយ។ ប៉ុន្តែប្រសិនបើនីតិវិធីនៃការបញ្ជូនជនជាប់ចោទទៅជំនុំជម្រះដោយដីកាបញ្ជូនទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ គឺត្រូវចេញដីកាកោះហៅឲ្យចូលសវនាការនូវភាគីដែលពាក់ព័ន្ធ។

**ផ្នែកទី៣៖ ដីកាកោះហៅឲ្យចូលសវនាការ**

ដីកាកោះហៅឲ្យចូលសវនាការ គឺជាដីការបស់ព្រះរាជអាជ្ញាបញ្ជាឲ្យជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី អ្នកជំនាញ អ្នកបកប្រែឲ្យចូលសវនាការដើម្បីធ្វើការជំនុំជម្រះ។

**កថាខណ្ឌទី១. ដីកាកោះហៅជនជាប់ចោទឲ្យចូលសវនាការ**

ដីកាកោះហៅជនជាប់ចោទឲ្យចូលសវនាការត្រូវមាននិទ្ទេសដូចតទៅ ៖

• អត្តសញ្ញាណនៃជនជាប់ចោទ

• កាលបរិច្ឆេទ និងទីកន្លែងកំណើតនៃជនជាប់ចោទ

• លំនៅឋានរបស់ជនជាប់ចោទ

• ការយោងដីកា

[២៤]មាត្រា៤៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[២៥]មាត្រា៤៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

- តុលាការដែលទទួលបណ្តឹងដើម្បីជំនុំជម្រះ
- ទីកន្លែង កាលបរិច្ឆេទ និងម៉ោងនៃសវនាការ
- កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា

ដីកានេះត្រូវបញ្ជាក់ថា ជនជាប់ចោទអាចមានមេធាវីអម[២៦]។ សម្រាប់រយៈពេលដែលត្រូវគោរពក្នុងការប្រគល់ដីកាកោះហៅឲ្យចូលសវនាការ ដល់ជនជាប់ចោទចូលបង្ហាញខ្លួននៅមុខតុលាការត្រូវកំណត់ដូចតទៅ[២៧]៖

- ១៥ថ្ងៃប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់សាលាដំបូង
- ២០ថ្ងៃប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ
- ២ខែប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជា។
- ៣ខែប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងផ្សេងទៀត។

### ១. ដីកាកោះប្រគល់ដោយព្រះរាជអាជ្ញា

ដីកាកោះហៅអាចប្រគល់ឲ្យជនជាប់ចោទដោយផ្ទាល់ដៃរបស់ព្រះរាជអាជ្ញា។ ករណីនេះព្រះរាជអាជ្ញាប្រគល់ចុងដីកាកោះហៅដល់ជនជាប់ចោទ ដោយចុះនិទ្ទេសលើដើមដីកាអំពីកាលបរិច្ឆេទ និងទីកន្លែងប្រគល់ ហើយជនជាប់ចោទត្រូវចុះហត្ថលេខានៅលើដីកាកោះនោះ[២៨]។

### ២. ដីកាកោះប្រគល់ដោយអាជ្ញាសាលា

ដីកាកោះហៅអាចប្រគល់ដោយអាជ្ញាសាលាទៅដល់លំនៅឋានរបស់ជនជាប់ចោទដែលកំពុងស្នាក់នៅ ឬ នៅកន្លែងផ្សេងទៀតដែលអាជ្ញាសាលាបានជួបប្រទះជនជាប់ចោទ។ អាជ្ញាសាលាចារនៅដើមដីកាកោះហៅថា ចុងដីកានេះត្រូវបានប្រគល់ដល់ជនជាប់ចោទដោយផ្ទាល់ដៃ។ អាជ្ញាសាលាចុះនិទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់ដីកាកោះហៅ។ ជនជាប់ចោទត្រូវចុះហត្ថលេខានៅលើដើមដីកា។ ដើមដីកាកោះហៅនេះត្រូវបង្វិលជូនមកព្រះរាជអាជ្ញាវិញភ្លាម[២៩]។ ករណីដែលជនជាប់ចោទអវត្តមានពីលំនៅឋាន អាជ្ញាសាលាអាចប្រគល់ចុងដីកាកោះទៅដល់បុគ្គលណាជានីតិជន មានវត្តមាននៅក្នុងលំនៅឋាន។ អាជ្ញាសាលាចុះនិទ្ទេសអំពីអត្តសញ្ញាណនៃបុគ្គលនេះ និងអំពីកាលបរិច្ឆេទនៃការប្រគល់ដីកាកោះ។ បុគ្គលដែលទទួលចុងដីកាកោះត្រូវចុះហត្ថលេខានៅលើដើមដីកា។ ដើមដីកាកោះហៅនេះត្រូវបង្វិលជូនមកព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលទទួលដីកាកោះត្រូវសន្យាថា នឹងប្រគល់ដីកានេះដល់ជនជាប់ចោទក្នុងរយៈពេលខ្លីបំផុត[៣០]។

---

[២៦]មាត្រា៤៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[២៧]មាត្រា ៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[២៨]មាត្រា ៤៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[២៩]មាត្រា ៤៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៣០]មាត្រា ៤៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

**៣. ដីកាកោះប្រគល់ដោយអាជ្ញាសាលាដល់មេឃុំ ឬ ចៅសង្កាត់**

អាជ្ញាសាលាអាចប្រគល់ចុងដីកាឲ្យមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រងក្នុងករណី៖

- ជនជាប់ចោទមិនព្រមទទួលដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។
- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទ។
- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទយល់ព្រមទទួលដីកាកោះទេ។

អាជ្ញាសាលាចុះនិទ្ទេសនៅលើដើមដីកាអំពីអត្តសញ្ញាណ និងឋានៈបុគ្គលដែលបានទទួលចុងដីកាព្រមទាំងកាលបរិច្ឆេទនៃការប្រគល់ដីកា។ បុគ្គលដែលទទួលដីកាត្រូវចុះហត្ថលេខានៅលើដើមដីកា។ ដើមដីកាត្រូវបង្វិលត្រឡប់ជូនព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលបានទទួលដីកាត្រូវសន្យាថា នឹងប្រគល់ដីកានេះក្នុងរយៈពេលដ៏ខ្លីបំផុតឲ្យដល់ជនជាប់ចោទ[៣១]។

**៤. របៀបផ្សេងទៀតក្នុងការប្រគល់ដីកាកោះ**

ដីកាកោះហៅក៏អាចត្រូវប្រគល់តាមរយៈ ៖

- ក្រឡាបញ្ជី
- អាជ្ញាធររដ្ឋបាល
- ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនប្រសិនបើជនជាប់ចោទត្រូវជាប់ឃុំខ្លួនពីបទល្មើសផ្សេងទៀត
- តាមរយៈអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ

ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល ប្រធានពន្ធនាគារ មន្ត្រីនគរបាលជាតិ ឬអាវុធហត្ថត្រូវគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញាក្នុងការប្រគល់ដីកាកោះនោះ។ ចុងដីកាកោះហៅត្រូវភ្ជាប់ជាមួយនូវលិខិតថតចម្លងមួយច្បាប់នៃដីកាបញ្ជូនរឿងទៅតុលាការជំនុំជម្រះ[៣២]។

**កថាខណ្ឌទី២. ដីកាកោះហៅដើមបណ្តឹងរដ្ឋប្បវេណីឲ្យចូលសវនាការ**

ដីកាកោះហៅដើមបណ្តឹងរដ្ឋប្បវេណីឲ្យចូលសវនាការត្រូវមាននិទ្ទេសដូចតទៅ[៣៣]៖

- អត្តសញ្ញាណនៃដើមបណ្តឹងរដ្ឋប្បវេណី
- លំនៅឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ឈ្មោះជនជាប់ចោទ និងបទល្មើសដែលចោទប្រកាន់
- តុលាការដែលជំនុំជម្រះ
- ទីកន្លែង កាលបរិច្ឆេទ និងម៉ោងនៃសវនាការ
- កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា

ក្នុងដីកាកោះហៅត្រូវមានបញ្ជាក់ថាត្រូវបានកោះហៅក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី។

[៣១]មាត្រា ៤៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧
[៣២]មាត្រា ៤៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧
[៣៣]មាត្រា៤៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

សម្រាប់រយៈពេលដែលត្រូវគោរពក្នុងការប្រគល់ដីកាកោះហៅ ឲ្យចូលសវនាការដល់ដើមបណ្ដឹងរដ្ឋប្បវេណីឲ្យចូលបង្ហាញមុខនៅតុលាការត្រូវកំណត់ដូចតទៅៈ

- ១៥ថ្ងៃប្រសិនបើ ដើមបណ្ដឹងរដ្ឋប្បវេណីរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់សាលាដំបូង
- ២០ថ្ងៃប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណី រស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ
- ២ខែប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណី រស់នៅក្នុងរដ្ឋមួយជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជា។
- ៣ខែប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណី រស់នៅក្នុងទីកន្លែងផ្សេងទៀត[៣៤]។

### ១. ដីកាកោះប្រគល់ដោយព្រះរាជអាជ្ញា

ដីកាកោះហៅអាចប្រគល់ឲ្យដើមបណ្ដឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃរបស់ព្រះរាជអាជ្ញា។ ករណីនេះព្រះរាជអាជ្ញាប្រគល់ចុងដីកាកោះហៅដល់ដើមបណ្ដឹងរដ្ឋប្បវេណី ដោយចុះនិទ្ទេសលើដើមដីកា អំពីកាលបរិច្ឆេទ និងទីកន្លែងប្រគល់ ហើយដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវចុះហត្ថលេខានៅលើដីកាកោះនោះ[៣៥]។

### ២. ដីកាកោះប្រគល់ដោយអាជ្ញាសាលា

ដីកាកោះហៅអាចប្រគល់ដោយអាជ្ញាសាលាទៅដល់លំនៅឋានរបស់ ដើមបណ្ដឹងរដ្ឋប្បវេណីដែលកំពុងស្នាក់នៅ ឬនៅកន្លែងផ្សេងទៀតដែលអាជ្ញាសាលាបានជួបប្រទះដើមបណ្ដឹងរដ្ឋប្បវេណី អាជ្ញាសាលាចារនៅដើមដីកាកោះហៅថា ចុងដីកានេះត្រូវបានប្រគល់ដល់ដើមបណ្ដឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃ។ អាជ្ញាសាលាចុះនិទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់ដីកាកោះហៅ។ ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវចុះហត្ថលេខានៅលើដើមដីកា។ ដើមដីកាកោះហៅនេះត្រូវបង្វិលជូនមកព្រះរាជអាជ្ញាវិញភ្លាម[៣៦]។ ករណីដែលដើមបណ្ដឹងរដ្ឋប្បវេណីអវត្តមានពីលំនៅឋាន អាជ្ញាសាលាអាចប្រគល់ចុងដីកាកោះទៅដល់បុគ្គលណាជានីតិជនមានវត្តមាននៅក្នុងលំនៅឋាន។អាជ្ញាសាលាចុះនិទ្ទេសអំពីអត្តសញ្ញាណនៃបុគ្គលនេះ និងអំពីកាលបរិច្ឆេទនៃការប្រគល់ដីកាកោះ។ បុគ្គលដែលទទួលចុងដីកាកោះត្រូវចុះហត្ថលេខានៅលើដើមដីកា។ ដើមដីកាកោះហៅនេះត្រូវបង្វិលជូនមកព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលទទួលដីកាកោះត្រូវសន្យាថានឹងប្រគល់ដីកានេះដល់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរយៈពេលខ្លីបំផុត[៣៧]។

### ៣. ដីកាកោះប្រគល់ដោយអាជ្ញាសាលាដល់មេឃុំ ឬ ចៅសង្កាត់

អាជ្ញាសាលាអាចប្រគល់ចុងដីកាឲ្យមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រងក្នុងករណីៈ

- ដើមបណ្ដឹងរដ្ឋប្បវេណីមិនព្រមទទួលដីកាកោះហៅ។
- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

---

[៣៤]មាត្រា៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៣៥]មាត្រា៤៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៣៦]មាត្រា៤៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៣៧]មាត្រា៤៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

• គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី យល់ព្រមទទួលដីកាកោះទេ។

អាជ្ញាសាលាចុះនិទ្ទេសនៅលើដើមដីកាអំពីអត្តសញ្ញាណ និងឋានៈបុគ្គលដែលបានទទួលចុងដីកាព្រមទាំងកាលបរិច្ឆេទនៃការប្រគល់ដីកា។ បុគ្គលដែលទទួលដីកាត្រូវចុះហត្ថលេខានៅលើដើមដីកា។ ដើមដីកាត្រូវបង្វិលត្រឡប់ជូនព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលបានទទួលដីកាត្រូវសន្យាថានឹងប្រគល់ដីកានេះក្នុងរយៈពេលដ៏ខ្លីបំផុតឲ្យដល់ដើមបណ្ដឹងរដ្ឋប្បវេណី[៣៨]។

**៤. របៀបផ្សេងទៀតក្នុងការប្រគល់ដីកាកោះ**

ដីកាកោះហៅក៏អាចត្រូវប្រគល់តាមរយៈ ៖

• ក្រឡាបញ្ជី

• អាជ្ញាធររដ្ឋបាល

• អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ

ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល ប្រធានពន្ធនាគារ មន្ត្រីនគរបាលជាតិ ឬ អាវុធហត្ថត្រូវគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញាក្នុងការប្រគល់ដីកាកោះនោះ។ ចុងដីកាកោះហៅត្រូវភ្ជាប់ជាមួយនូវលិខិតថតចម្លងមួយច្បាប់នៃដីកាបញ្ជូនរឿងទៅតុលាការជំនុំជម្រះ[៣៩]។

**កថាខណ្ឌទី៣ ដីកាកោះហៅជនរងគ្រោះឲ្យចូលសវនាការ**

ដីកាកោះហៅជនរងគ្រោះ ឲ្យចូលសវនាការត្រូវមាននិទ្ទេសដូចតទៅ[៤០]៖

• អត្តសញ្ញាណនៃជនរងគ្រោះ

• លំនៅឋានរបស់ជនរងគ្រោះ

• ឈ្មោះជនជាប់ចោទ និងបទល្មើសដែលចោទប្រកាន់

• តុលាការដែលជំនុំជម្រះ

• ទីកន្លែង កាលបរិច្ឆេទ និងម៉ោងនៃសវនាការ

• កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា

ក្នុងដីកាកោះហៅត្រូវមានបញ្ជាក់ថាត្រូវបានកោះហៅក្នុងឋានៈជាជនរងគ្រោះ ។ សម្រាប់រយៈពេលដែលត្រូវគោរពក្នុងការប្រគល់ដីកាកោះហៅឲ្យចូលសវនាការ ដល់ជនរងគ្រោះ ចូលបង្ហាញមុខនៅតុលាការត្រូវកំណត់ដូចតទៅ[៤១]៖

• ១៥ថ្ងៃប្រសិនបើ ជនរងគ្រោះរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់សាលាដំបូង

• ២០ថ្ងៃប្រសិនបើ ជនរងគ្រោះរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ

• ២ខែប្រសិនបើ ជនរងគ្រោះរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជា។

• ៣ខែប្រសិនបើ ជនរងគ្រោះរស់នៅក្នុងទីកន្លែងផ្សេងទៀត។

[៣៨]មាត្រា៤៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៣៩]មាត្រា៤៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៤០]មាត្រា៤៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៤១]មាត្រា៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

**១. ដីកាកោះប្រគល់ដោយព្រះរាជអាជ្ញា**

ដីកាកោះហៅអាចប្រគល់ឲ្យជនរងគ្រោះដោយផ្ទាល់ដៃរបស់ព្រះរាជអាជ្ញា។ ករណីនេះព្រះរាជអាជ្ញាប្រគល់ចុងដីកាកោះហៅដល់ជនរងគ្រោះ ដោយចុះនិទ្ទេសលើដើមដីកាអំពីកាលបរិច្ឆេទនិងទីកន្លែងប្រគល់ហើយជនរងគ្រោះ ត្រូវចុះហត្ថលេខានៅលើដីកាកោះនោះ[៤២]។

**២. ដីកាកោះប្រគល់ដោយអាជ្ញាសាលា**

ដីកាកោះហៅអាចប្រគល់ដោយអាជ្ញាសាលាទៅដល់លំនៅឋានរបស់ជនរងគ្រោះ ដែលកំពុងស្នាក់នៅ ឬ នៅកន្លែងផ្សេងទៀតដែលអាជ្ញាសាលាបានជួបប្រទះជនរងគ្រោះ ។ អាជ្ញាសាលាចារនៅដើមដីកាកោះហៅថា ចុងដីកានេះត្រូវបានប្រគល់ដល់ជនរងគ្រោះដោយផ្ទាល់ដៃ។ អាជ្ញាសាលាចុះនិទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់ដីកាកោះហៅ។ ជនរងគ្រោះត្រូវចុះហត្ថលេខានៅលើដើមដីកា។ ដើមដីកាកោះហៅនេះត្រូវបង្វិលជូនមកព្រះរាជអាជ្ញាវិញភ្លាម[៤៣]។

ករណីដែលជនរងគ្រោះអវត្តមានពីលំនៅឋាន អាជ្ញាសាលាអាចប្រគល់ចុងដីកាកោះទៅដល់បុគ្គលណាជានីតិជន មានវត្តមាននៅក្នុងលំនៅឋាន។ អាជ្ញាសាលាចុះនិទ្ទេសអំពីអត្តសញ្ញាណនៃបុគ្គលនេះ និងអំពីកាលបរិច្ឆេទនៃការប្រគល់ដីកាកោះ។ បុគ្គលដែលទទួលចុងដីកាកោះត្រូវចុះហត្ថលេខានៅលើដើមដីកា។ ដើមដីកាកោះហៅនេះត្រូវបង្វិលជូនមកព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលទទួលដីកាកោះនេះត្រូវសន្យាថានឹងប្រគល់ដីកានេះ ឲ្យដល់ជនរងគ្រោះក្នុងរយៈពេលដ៏ខ្លីបំផុត[៤៤] ។

**៣. ដីកាកោះប្រគល់ដោយអាជ្ញាសាលាដល់មេឃុំ ឬ ចៅសង្កាត់**

អាជ្ញាសាលាអាចប្រគល់ចុងដីកាឲ្យមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រងក្នុងករណី៖

- ជនរងគ្រោះមិនព្រមទទួលដីកាកោះហៅ។
- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ជនរងគ្រោះ ។
- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ជនរងគ្រោះ យល់ព្រមទទួលដីកាកោះទេ។

អាជ្ញាសាលាចុះនិទ្ទេសនៅលើដើមដីកាអំពីអត្តសញ្ញាណ និងឋានៈបុគ្គលដែលបានទទួលចុងដីកាព្រមទាំងកាលបរិច្ឆេទនៃការប្រគល់ដីកា។ បុគ្គលដែលទទួលដីកាត្រូវចុះហត្ថលេខានៅលើដើមដីកា។ ដើមដីកាត្រូវបង្វិលត្រឡប់ជូនព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលបានទទួលដីកាត្រូវសន្យាថា នឹងប្រគល់ដីកានេះក្នុងរយៈពេលដ៏ខ្លីបំផុតឲ្យដល់ជនរងគ្រោះ[៤៥]។

**៤. របៀបផ្សេងទៀតក្នុងការប្រគល់ដីកាកោះ**

ដីកាកោះហៅក៏អាចត្រូវប្រគល់តាមរយៈ ៖

- ក្រឡាបញ្ជី

[៤២]មាត្រា៤៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៤៣]មាត្រា៤៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៤៤]មាត្រា៤៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៤៥]មាត្រា៤៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

- អាជ្ញាធររដ្ឋបាល
- អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ

ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល ប្រធានពន្ធនាគារ មន្ត្រីនគរបាលជាតិ ឬ អាវុធហត្ថត្រូវគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញាក្នុងការប្រគល់ដីកាកោះនោះ។ ចុងដីកាកោះហៅត្រូវភ្ជាប់ជាមួយនូវលិខិតថតចម្លងមួយច្បាប់នៃដីកាបញ្ជូនរឿងទៅតុលាការជំនុំជម្រះ[៥៦]។

**កថាខណ្ឌទី៤. ដីកាកោះហៅសាក្សី**

ដីកាកោះហៅសាក្សីឲ្យចូលសវនាការ ត្រូវមាននិទ្ទេសដូចតទៅ[៥៧]៖

- អត្តសញ្ញាណនៃសាក្សី
- លំនៅឋានរបស់សាក្សី
- ឈ្មោះជនជាប់ចោទ និងបទល្មើសដែលចោទប្រកាន់
- តុលាការដែលជំនុំជម្រះ
- ទីកន្លែង កាលបរិច្ឆេទ និងម៉ោងនៃសវនាការ
- កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា

ក្នុងដីកាកោះហៅត្រូវមានបញ្ជាក់ថាត្រូវបានកោះហៅក្នុងឋានៈជាសាក្សី។ សម្រាប់រយៈពេលដែលត្រូវគោរពក្នុងការប្រគល់ដីកាកោះហៅឲ្យចូលសវនាការ ដល់សាក្សីចូលបង្ហាញមុខនៅតុលាការត្រូវកំណត់ដូចតទៅ[៥៨]៖

- ១៥ថ្ងៃប្រសិនបើសាក្សី រស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់សាលាដំបូង
- ២០ថ្ងៃប្រសិនបើ សាក្សីរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ
- ២ខែប្រសិនបើ សាក្សីរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជា។
- ៣ខែប្រសិនបើ សាក្សីរស់នៅក្នុងទីកន្លែងផ្សេងទៀត។

**១.ដីកាកោះប្រគល់ដោយព្រះរាជអាជ្ញា**

ដីកាកោះហៅអាចប្រគល់ឲ្យសាក្សី ដោយផ្ទាល់ដៃរបស់ព្រះរាជអាជ្ញា។ ករណីនេះព្រះរាជអាជ្ញាប្រគល់ចុងដីកាកោះហៅដល់សាក្សីដោយចុះនិទ្ទេសលើដើមដីកាអំពីកាលបរិច្ឆេទ និងទីកន្លែងប្រគល់ហើយសាក្សីត្រូវចុះហត្ថលេខានៅលើដីកាកោះនោះ[៥៩]។

**២.ដីកាកោះប្រគល់ដោយអាជ្ញាសាលា**

ដីកាកោះហៅអាចប្រគល់ដោយអាជ្ញាសាលាទៅដល់លំនៅឋានរបស់សាក្សី ដែលកំពុងស្នាក់នៅ ឬនៅកន្លែងផ្សេងទៀតដែលអាជ្ញាសាលាបានជួបប្រទះសាក្សី។ អាជ្ញាសាលាចារនៅដើមដីកាកោះហៅថា ចុងដីកានេះត្រូវបានប្រគល់ដល់សាក្សីដោយផ្ទាល់ដៃ។ អាជ្ញាសាលាចុះនិទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់ដីកាកោះហៅ។ សាក្សីត្រូវចុះហត្ថលេខានៅលើដើមដី

[៥៦] មាត្រា៤៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧
[៥៧] មាត្រា៤៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧
[៥៨] មាត្រា៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧
[៥៩] មាត្រា៤៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

កា។ដើមដីកាកោះហៅនេះត្រូវបង្វិលជូនមកព្រះរាជអាជ្ញាវិញភ្លាម[៥០]។ករណីដែលសាក្សីអវត្តមានពីលំនៅឋាន អាជ្ញាសាលាអាចប្រគល់ចុងដីកាកោះទៅដល់បុគ្គលណាជានីតិជន មានវត្តមាននៅក្នុងលំនៅឋាន។ អាជ្ញាសាលាចុះនិទ្ទេសអំពីអត្តសញ្ញាណនៃបុគ្គលនោះ និងអំពីកាលបរិច្ឆេទនៃការប្រគល់ដីកាកោះ។ បុគ្គលដែលទទួលចុងដីកាកោះត្រូវចុះហត្ថលេខានៅលើដើមដីកា។ ដើមដីកាកោះហៅនេះត្រូវបង្វិលជូនមកព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលទទួលដីកាកោះត្រូវសន្យាថានឹងប្រគល់ដីកានេះឲ្យដល់សាក្សីក្នុងរយៈពេលដ៏ខ្លីបំផុត[៥១]។

**៣.ដីកាកោះប្រគល់ដោយអាជ្ញាសាលាដល់មេឃុំ ឬ ចៅសង្កាត់**

អាជ្ញាសាលាអាចប្រគល់ចុងដីកាឲ្យមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រងក្នុងករណី៖

- សាក្សីមិនព្រមទទួលដីកាកោះហៅ។
- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់សាក្សី ។
- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់សាក្សី យល់ព្រមទទួលដីកាកោះទេ។

អាជ្ញាសាលាចុះនិទ្ទេសនៅលើដើមដីកាអំពីអត្តសញ្ញាណ និងឋានៈបុគ្គលដែលបានទទួលចុងដីកាព្រមទាំងកាលបរិច្ឆេទនៃការប្រគល់ដីកា។ បុគ្គលដែលទទួលដីកាត្រូវចុះហត្ថលេខានៅលើដើមដីកា។ ដើមដីកាត្រូវបង្វិលត្រឡប់ជូនព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលបានទទួលដីកាត្រូវសន្យាថា នឹងប្រគល់ដីកានេះក្នុងរយៈពេលដ៏ខ្លីបំផុតឲ្យដល់សាក្សី [៥២] ។

**៤.របៀបផ្សេងទៀតក្នុងការប្រគល់ដីកាកោះ**

ដីកាកោះហៅក៏អាចត្រូវប្រគល់តាមរយៈ:

- ក្រឡាបញ្ជី
- អាជ្ញាធររដ្ឋបាល
- អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ

ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល ប្រធានពន្ធនាគារ មន្ត្រីនគរបាលជាតិ ឬ អាវុធហត្ថត្រូវគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញាក្នុងការប្រគល់ដីកាកោះនោះ។ ចុងដីកាកោះហៅត្រូវភ្ជាប់ជាមួយនូវលិខិតថតចម្លងមួយច្បាប់នៃដីកាបញ្ជូនរឿងទៅតុលាការជំនុំជម្រះ[៥៣]។

**កថាខណ្ឌទី៥. ដីកាកោះហៅអ្នកជំនាញ**

ដីកាកោះហៅអ្នកជំនាញឲ្យចូលសវនាការ ត្រូវមាននិទ្ទេសដូចតទៅ[៥៤]៖

- អត្តសញ្ញាណនៃអ្នកជំនាញ
- លំនៅឋានរបស់អ្នកជំនាញ
- ឈ្មោះជនជាប់ចោទ និងបទល្មើសដែលចោទប្រកាន់

[៥០]មាត្រា៤៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧
[៥១]មាត្រា៤៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧
[៥២]មាត្រា៤៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧
[៥៣]មាត្រា៤៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧
[៥៤]មាត្រា៤៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

- តុលាការដែលជំនុំជម្រះ
- ទីកន្លែង កាលបរិច្ឆេទ និងម៉ោងនៃសវនាការ
- កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា

ក្នុងដីកាកោះហៅត្រូវមានបញ្ជាក់ថាត្រូវបានកោះហៅក្នុងឋានៈជាអ្នកជំនាញ។ សម្រាប់រយៈពេលដែលត្រូវគោរពក្នុងការប្រគល់ដីកាកោះហៅឲ្យចូលសវនាការ ដល់អ្នកជំនាញចូលបង្ហាញមុខនៅតុលាការត្រូវកំណត់ដូចតទៅ[៥៥]៖

- ១៥ថ្ងៃប្រសិនបើ អ្នកជំនាញ រស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់សាលាដំបូង
- ២០ថ្ងៃប្រសិនបើ អ្នកជំនាញរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ
- ២ខែប្រសិនបើ អ្នកជំនាញរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជា
- ៣ខែប្រសិនបើ អ្នកជំនាញរស់នៅក្នុងទីកន្លែងផ្សេងទៀត។

**១.ដីកាកោះប្រគល់ដោយព្រះរាជអាជ្ញា**

ដីកាកោះហៅអាចប្រគល់ឲ្យអ្នកជំនាញដោយផ្ទាល់ដៃរបស់ព្រះរាជអាជ្ញា។ ករណីនេះព្រះរាជអាជ្ញាប្រគល់ចុងដីកាកោះហៅដល់អ្នកជំនាញ ដោយចុះនិទ្ទេសលើដើមដីកាអំពីកាលបរិច្ឆេទនិងទីកន្លែងប្រគល់ហើយអ្នកជំនាញត្រូវចុះហត្ថលេខានៅលើដីកាកោះនោះ[៥៦]។

**២.ដីកាកោះប្រគល់ដោយអាជ្ញាសាលា**

ដីកាកោះហៅអាចប្រគល់ដោយអាជ្ញាសាលាទៅដល់លំនៅឋានរបស់អ្នកជំនាញ ដែលកំពុងស្នាក់នៅ ឬ នៅកន្លែងផ្សេងទៀតដែលអាជ្ញាសាលាបានជួបប្រទះអ្នកជំនាញ។ អាជ្ញាសាលាចារនៅដើមដីកាកោះហៅថា ចុងដីកានេះត្រូវបានប្រគល់ដល់អ្នកជំនាញដោយផ្ទាល់ដៃ។ អាជ្ញាសាលាចុះនិទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់ដីកាកោះហៅ។ អ្នកជំនាញត្រូវចុះហត្ថលេខានៅលើដើមដីកា។ ដើមដីកាកោះហៅនេះត្រូវបង្វិលជូនមកព្រះរាជអាជ្ញាវិញភ្លាម[៥៧]។ ករណីដែលអ្នកជំនាញអវត្តមានពីលំនៅឋាន អាជ្ញាសាលាអាចប្រគល់ចុងដីកាកោះទៅដល់បុគ្គលណាជានីតិជន មានវត្តមាននៅក្នុងលំនៅឋាន។ អាជ្ញាសាលាចុះនិទ្ទេសអំពីអត្តសញ្ញាណនៃបុគ្គលនេះ និងអំពីកាលបរិច្ឆេទនៃការប្រគល់ដីកាកោះ។ បុគ្គលដែលទទួលចុងដីកាកោះត្រូវចុះហត្ថលេខានៅលើដើមដីកា។ ដើមដីកាកោះហៅនេះត្រូវបង្វិលជូនមកព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលទទួលដីកាកោះត្រូវសន្យាថានឹងប្រគល់ដីកានេះដល់អ្នកជំនាញក្នុងរយៈពេលខ្លីបំផុត [៥៨]។

**៣.ដីកាកោះប្រគល់ដោយអាជ្ញាសាលាដល់មេឃុំ ឬ ចៅសង្កាត់**

អាជ្ញាសាលាអាចប្រគល់ចុងដីកាឲ្យមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រងក្នុងករណី៖

- អ្នកជំនាញមិនព្រមទទួលដីកាកោះហៅ។
- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់អ្នកជំនាញ ។

[៥៥] មាត្រា៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧
[៥៦] មាត្រា៤៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧
[៥៧] មាត្រា៤៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧
[៥៨] មាត្រា៤៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

• គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់អ្នកជំនាញយល់ព្រម ទទួលដីកាកោះទេ។

អាជ្ញាសាលាចុះនិទ្ទេសនៅលើដើមដីកាអំពីអត្តសញ្ញាណ និងឋានៈបុគ្គលដែលបានទទួលចុងដីកាព្រមទាំងកាលបរិច្ឆេទនៃការប្រគល់ដីកា។ បុគ្គលដែលទទួលដីកាត្រូវចុះហត្ថលេខានៅលើដើមដីកា។ ដើមដីកាត្រូវបង្វិលត្រឡប់ជូនព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលបានទទួលដីកាត្រូវសន្យាថានឹងប្រគល់ដីកានេះក្នុងរយៈពេលដ៏ខ្លីបំផុតឲ្យដល់អ្នកជំនាញ[៥៩]។

**៤.របៀបផ្សេងទៀតក្នុងការប្រគល់ដីកាកោះ**

ដីកាកោះហៅក៏អាចត្រូវប្រគល់តាមរយៈ ៖

• ក្រឡាបញ្ជី

• អាជ្ញាធររដ្ឋបាល

• អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ

ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល ប្រធានពន្ធនាគារ មន្ត្រីនគរបាលជាតិ ឬ អាវុធហត្ថត្រូវគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញាក្នុងការប្រគល់ដីកាកោះនោះ។ ចុងដីកាកោះហៅត្រូវភ្ជាប់ជាមួយនូវលិខិតចតចម្លងមួយច្បាប់នៃដីកាបញ្ជូនរឿងទៅតុលាការជំនុំជម្រះ[៦០]។

**កថាខណ្ឌទី៦. ដីកាកោះហៅអ្នកបកប្រែ**

ដីកាកោះហៅអ្នកបកប្រែឲ្យចូលសវនាការត្រូវមាននិទ្ទេសដូចតទៅ៖

• អត្តសញ្ញាណនៃអ្នកបកប្រែ

• លំនៅឋានរបស់អ្នកបកប្រែ

• ឈ្មោះជនជាប់ចោទ និងបទល្មើសដែលចោទប្រកាន់

• តុលាការដែលជំនុំជម្រះ

• ទីកន្លែង កាលបរិច្ឆេទ និងម៉ោងនៃសវនាការ

• កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា

ក្នុងដីកាកោះហៅត្រូវមានបញ្ជាក់ថាត្រូវបានកោះហៅក្នុងឋានៈជាអ្នកបកប្រែ[៦១] ។ សម្រាប់រយៈពេលដែលត្រូវគោរពក្នុងការប្រគល់ដីកាកោះហៅឲ្យចូលសវនាការ ដល់អ្នកបកប្រែចូលបង្ហាញមុខនៅតុលាការត្រូវកំណត់ដូចតទៅ[៦២]៖

• ១៥ថ្ងៃប្រសិនបើ អ្នកបកប្រែរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់សាលាដំបូង

• ២០ថ្ងៃប្រសិនបើ អ្នកបកប្រែរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ

• ២ខែប្រសិនបើ អ្នកបកប្រែរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជា

• ៣ខែប្រសិនបើ អ្នកបកប្រែរស់នៅក្នុងទីកន្លែងផ្សេងទៀត។

---

[៥៩]មាត្រា៤៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៦០]មាត្រា៤៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៦១]មាត្រា៤៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៦២]មាត្រា៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

**១.ដីកាកោះប្រគល់ដោយព្រះរាជអាជ្ញា**

ដីកាកោះហៅអាចប្រគល់ឲ្យសាក្សី ដោយផ្ទាល់ដៃរបស់ព្រះរាជអាជ្ញា។ ករណីនេះព្រះរាជអាជ្ញាប្រគល់ចុងដីកាកោះហៅដល់អ្នកបកប្រែដោយចុះនិទ្ទេសលើដើមដីកាអំពីកាលបរិច្ឆេទ និងទីកន្លែងប្រគល់ហើយអ្នកបកប្រែត្រូវចុះហត្ថលេខានៅលើដីកាកោះនោះ[៦៣]។

**២.ដីកាកោះប្រគល់ដោយអាជ្ញាសាលា**

ដីកាកោះហៅអាចប្រគល់ដោយអាជ្ញាសាលាទៅដល់លំនៅឋានរបស់អ្នកបកប្រែ ដែលកំពុងស្នាក់នៅ ឬនៅកន្លែងផ្សេងទៀតដែលអាជ្ញាសាលាបានជួបប្រទះអ្នកបកប្រែ។ អាជ្ញាសាលាចារនៅដើមដីកាកោះហៅថា ចុងដីកានេះត្រូវបានប្រគល់ដល់អ្នកបកប្រែដោយផ្ទាល់ដៃ។

អាជ្ញាសាលាចុះនិទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់ដីកាកោះហៅ។ អ្នកបកប្រែត្រូវចុះហត្ថលេខានៅលើដើមដីកា។ ដើមដីកាកោះហៅនេះត្រូវបង្វិលជូនមកព្រះរាជអាជ្ញាវិញភ្លាម[៦៤]។ ករណីដែលអ្នកប្រែអវត្តមានពីលំនៅឋាន អាជ្ញាសាលាអាចប្រគល់ចុងដីកាកោះទៅដល់បុគ្គលណាជានីតិជន មានវត្តមាននៅក្នុងលំនៅឋាន។ អាជ្ញាសាលាចុះនិទ្ទេសអំពីអត្តសញ្ញាណនៃបុគ្គលនេះ និងអំពីកាលបរិច្ឆេទនៃការប្រគល់ដីកាកោះ។ បុគ្គលដែលទទួលចុងដីកាកោះត្រូវចុះហត្ថលេខានៅលើដើមដីកា។ដើមដីកាកោះហៅនេះត្រូវបង្វិលជូនមកព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលទទួលដីកាកោះត្រូវសន្យាថានឹងប្រគល់ដីកានេះដល់អ្នកបកប្រែក្នុងរយៈពេលខ្លីបំផុត[៦៥]។

**៣.ដីកាកោះប្រគល់ដោយអាជ្ញាសាលាដល់មេឃុំ ឬ ចៅសង្កាត់**

អាជ្ញាសាលាអាចប្រគល់ចុងដីកាឲ្យមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រងក្នុងករណី៖

- អ្នកបកប្រែមិនព្រមទទួលដីកាកោះហៅ។
- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់អ្នកបកប្រែ ។
- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់អ្នកបកប្រែ យល់ព្រមទទួលដីកាកោះទេ។

អាជ្ញាសាលាចុះនិទ្ទេសនៅលើដើមដីកាអំពីអត្តសញ្ញាណ និងឋានៈបុគ្គលដែលបានទទួលចុងដីកាព្រមទាំងកាលបរិច្ឆេទនៃការប្រគល់ដីកា។ បុគ្គលដែលទទួលដីកាត្រូវចុះហត្ថលេខានៅលើដើមដីកា។ ដើមដីកាត្រូវបង្វិលត្រឡប់ជូនព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលបានទទួលដីកាត្រូវសន្យាថានឹងប្រគល់ដីកានេះក្នុងរយៈពេលដ៏ខ្លីបំផុតឲ្យដល់អ្នកបកប្រែ[៦៦] ។

**៤.របៀបផ្សេងទៀតក្នុងការប្រគល់ដីកាកោះ**

ដីកាកោះហៅក៏អាចត្រូវប្រគល់តាមរយៈ

- ក្រឡាបញ្ជី
- អាជ្ញាធររដ្ឋបាល

[៦៣]មាត្រា៤៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៦៤]មាត្រា៤៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៦៥]មាត្រា៤៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៦៦]មាត្រា៤៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

- អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ

ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល ប្រធានពន្ធនាគារ មន្ត្រីនគរបាលជាតិ ឬកងរាជអាវុធហត្ថត្រូវគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញាក្នុងការប្រគល់ដីកាកោះនោះ។ចុងដីកាកោះហៅត្រូវភ្ជាប់ជាមួយនូវលិខិតថតចម្លងមួយច្បាប់នៃដីកាបញ្ជូនរឿងទៅតុលាការជំនុំជម្រះ[៦៧]។

[៦៧] មាត្រា៤៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

# ជំពូកទី៣
## នីតិវិធីក្នុងពេលសវនាការ

ជាទូទៅទិដ្ឋភាពក្នុងដំណើរការជំនុំជម្រះនៅសាលាដំបូងយើងសង្កេតឃើញមាន ចៅក្រម ១រូប ចំពោះបទមជ្ឈិម និងបទលហុ ឬ ចៅក្រម៣រូប ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ តំណាងអយ្យការ១រូប ក្រឡាបញ្ជី១រូប មេធាវីការពារជនជាប់ចោទ១រូប មេធាវីដើមបណ្តឹង១រូប ជនរងគ្រោះ ជនជាប់ចោទ សាក្សី អ្នកបកប្រែ(ករណីជនរងគ្រោះ ឬ ជនជាប់ចោទជាជនជាតិបរទេស) និងមន្ត្រីនគរបាលយុត្តិធម៌អមជនជាប់ចោទ។

នៅមុនពេលបើកសវនាការជាសាធារណៈ ចៅក្រមមានភារៈកិច្ចក្នុងការរៀបចំសំណុំរឿងសំរាប់បើកសវនាការដែលជាទូទៅ ក្នុងពេលសវនាការម្តងចៅក្រមជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌចាប់ពីបីសំណុំរឿងឡើងទាំងព្រមទាំងកំណត់ពីកាលបរិច្ឆេទសវនាការ និងកំណត់ពីសាលដែលត្រូវជំនុំជម្រះ។ ចៅក្រមត្រូវធ្វើលិខិតស្នើមកព្រះរាជអាជ្ញាដើម្បីចាត់តាំងតំណាងអយ្យការក្នុងការចូលរួមជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ។

នៅមុនពេលចាប់ផ្តើមសវនាការក្រឡាបញ្ជីមានភារៈកិច្ចៈ

- រៀបចំបន្ទប់សវនាការដោយពិនិត្យមើលពីសណ្តាប់ធ្នាប់ក្នុងបន្ទប់សវនាការ
- រៀបចំឯកសារទាំងអស់ដែលពាក់ព័ន្ធនឹងការជំនុំជម្រះរបស់ចៅក្រម
- ត្រូវធ្វើការផ្ទៀងផ្ទាត់បញ្ជីឈ្មោះជនជាប់ចោទដែលពន្ធធនាគារបានបញ្ជូនមក
- ក្រឡាបញ្ជីធ្វើការអានពីបទបញ្ជាផ្ទៃក្នុងរបស់សវនាការដល់សាធារណជនស្តាប់

### ផ្នែកទី១ ៖ ការពិភាក្សាដេញដោលក្នុងសវនាការ

នៅក្នុងពេលចាប់ផ្តើមសវនាការ គឺក្រឡាបញ្ជីធ្វើការអញ្ជើញចៅក្រម ឬ ក្រុមប្រឹក្សាជំនុំជម្រះចូលក្នុងបន្ទប់សវនាការ។ នៅពេលចៅក្រម ឬ ក្រុមប្រឹក្សាចូលមកដល់សវនាការសាធារណជនដែលចូលរួមទាំងអស់ត្រូវតែងើបឈរឡើងជាសញ្ញាគោរពអង្គតុលាការ បន្ទាប់មកចៅក្រមជំនុំជម្រះ ឬ ក្រុមប្រឹក្សាជំនុំជម្រះនឹងអនុញ្ញាតឲ្យអង្គុយដើម្បីសម្រួលឥរិយាបថ។ ក្រឡាបញ្ជីមានរយៈពេលប្រាំនាទីក្នុងការប្រកាសនូវវត្តមានរបស់ភាគីទាំងអស់ដូចជាមេធាវីការពារជនជាប់ចោទ មេធាវីការពារជនរងគ្រោះ ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាក្សី។ សាធារណៈជនដែលចូលរួមស្តាប់សវនាការទាំងអស់ជានីតិជន។

ជាគោលការណ៍នៅពេលដែលចៅក្រមជំនុំជម្រះ ឬ ក្រុមប្រឹក្សាជំនុំជម្រះធ្វើការប្រកាសបើកសវនាការដោយមានការរៀបរាប់ដូចជាៈ

- តាងនាមប្រជារាស្ត្រខ្មែរ
- ប្រកាសពីលេខសំណុំរឿង និងកាលបរិច្ឆេទ
- ឈ្មោះជនជាប់ចោទនៅក្នុងសំណុំរឿង
- កាលបរិច្ឆេទនៃថ្ងៃប្រព្រឹត្តបទល្មើស
- កាលបរិច្ឆេទនៃថ្ងៃចាប់ខ្លួន
- ទីកន្លែងដែលជនជាប់ចោទបានប្រព្រឹត្តបទល្មើស

• បទល្មើសដែលចោទប្រកាន់ជនជាប់ចោទ

ក្រោយពីចៅក្រមជំនុំជម្រះ ឬ ក្រុមប្រឹក្សាជំនុំជម្រះប្រកាសបើកសវនាការរួច ចៅក្រមជំនុំជម្រះ ឬ ក្រុមប្រឹក្សាជំនុំជម្រះចាប់ផ្ដើមបើកការពិភាក្សាដេញដោលដោយធ្វើការកោះហៅជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីឲ្យចូលសវនាការដើម្បីសួរចម្លើយ និងស្ដាប់ចម្លើយ។

**កថាខណ្ឌទី១. ការសួរចម្លើយជនជាប់ចោទ**

នៅមុនពេលដែលជនជាប់ចោទបានចូលសវនាការតាមរយៈដីកាកោះហៅ គឺជនជាប់ចោទត្រូវធ្វើសម្បថតាមប្រពៃណីសាសនាដោយមានអមដោយមន្ត្រីនគរបាល។ ពេលដែលជនជាប់ចោទបានចូលមកដល់សវនាការរួចរាល់ហើយ ចៅក្រមប្រកាសពីសិទ្ធិរបស់ជនជាប់ចោទមានក្នុងពេលសវនាការ ព្រមទាំងសិទ្ធិមានមេធាវីការពារខ្លួនផងដែរ។ ចៅក្រមសួរបញ្ជាក់អំពីអត្តសញ្ញាណជនជាប់ចោទនូវ ឈ្មោះ ឈ្មោះហៅក្រៅ អាយុ ទីកន្លែងកំណើត លំនៅឋាន មុខរបប ឈ្មោះសហព័ន្ធ ចំនួនកូន ឈ្មោះឪពុកម្ដាយ បទល្មើសដែលធ្លាប់បានប្រព្រឹត្តពីមុន។ ចៅក្រមសួរទៅតំណាងអយ្យការថាតើមានការផ្លាស់ប្ដូរបទចោទប្រកាន់ដែរឬទេ? បើគ្មានការផ្លាស់ប្ដូរទេចៅក្រមសុំឲ្យតំណាងអយ្យការអានបទចោទប្រកាន់។ ក្រោយពីចៅក្រមស្ដាប់បទចោទប្រកាន់របស់តំណាងអយ្យការ។ ចៅក្រមជំនុំជម្រះចោទសួរទៅជនជាប់ចោទថាតើជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់របស់តំណាងអយ្យការមែនឬទេ? ជនជាប់ចោទអាចឆ្លើយទទួលស្គាល់ការចោទប្រកាន់ ឬមិនព្រមទទួលស្គាល់បទចោទប្រកាន់។ បើជនជាប់ចោទឆ្លើយទទួលស្គាល់ នោះចៅក្រមបញ្ជាឲ្យជនជាប់ចោទនិយាយរៀបរាប់ពីដំណើរដើមទងទាំងអស់នៃការប្រព្រឹត្តបទល្មើស។ ប៉ុន្តែប្រសិនបើជនជាប់ចោទឆ្លើយមិនព្រមទទួលស្គាល់ការចោទប្រកាន់ទេ ចៅក្រមជំនុំជម្រះស្នើសុំឲ្យក្រឡាបញ្ជីអានពីបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ឲ្យលឺៗ ដើម្បីជាភស្តុតាងដាក់បន្ទុកទៅលើជនជាប់ចោទដែលឆ្លើយបដិសេធមិនព្រមទទួលយកការចោទប្រកាន់។ បន្ទាប់ពីស្ដាប់របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ដែលអានដោយក្រឡាបញ្ជី ចៅក្រមនឹងសួរគ្រប់សំណួរទាំងអស់ទាំងសំណួរដាក់បន្ទុក និងសំណួរដោះបន្ទុកទៅជនជាប់ចោទដែលចៅក្រមយល់ឃើញថាមានប្រយោជន៍ដល់ការសម្ដែងឲ្យឃើញការពិត។ បន្ទាប់ពីចៅក្រមជំនុំជម្រះធ្វើការសួរចម្លើយជនជាប់ចោទរួចចៅក្រមអនុញ្ញាតឲ្យតំណាងអយ្យការ មេធាវីការពារជនរងគ្រោះ និងភាគីអាចលើកជាសំណួរសួរដល់ជនជាប់ចោទ។ រាល់សំណួរដែលចៅក្រមលើកឡើងទោះបីជាបានសាកសួរម្ដងរួចហើយក្ដីក៏តំណាងអយ្យការ ឬមេធាវីការពារជនជាប់ចោទ ឬភាគីគ្មានសិទ្ធិកាត់សំណួររបស់ចៅក្រមបានដែរ។ ប៉ុន្តែចៅក្រមមានសិទ្ធិក្នុងការកាត់សំណួរដែលចោទសួរដោយតំណាងអយ្យការ ឬ មេធាវី ឬ ភាគីចំពោះរាល់សំណួរណាដែលពុំមានប្រយោជន៍ក្នុងរឿងក្ដី ឬរំលោភលើសិទ្ធិរបស់ជនជាប់ចោទហួសហេតុពេក។ ជនជាប់ចោទដែលជានីតិជនតុលាការធ្វើការជំនុំជម្រះជាសាធារណៈ លើកលែងតែជនជាប់ចោទជាអនីតិជនតុលាការសម្រេចធ្វើការជំនុំជម្រះជាអសាធារណៈ។ ក្នុងសវនាការអសាធារណៈបុគ្គលដែលតុលាការអនុញ្ញាតឲ្យចូលរួមស្ដាប់បានលុះត្រាតែជា៖

• ភ្នាក់ងារសង្គមកិច្ច

- សាច់ញាតិរបស់ជនជាប់ចោទ
- សាច់ញាតិរបស់ជនរងគ្រោះ
- ដើមបណ្ដឹងរដ្ឋប្បវេណី
- ជនរងគ្រោះ
- សាក្សី

**កថាខណ្ឌទី២. ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាក្សី**

មុនពេលដែលចៅក្រមស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាក្សីចៅក្រមជំនុំជម្រះសួរបញ្ជាក់អំពីអត្តសញ្ញាណដើមបណ្ដឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាក្សី នូវ ឈ្មោះ ឈ្មោះហៅក្រៅ អាយុ ទីកន្លែងកំណើត លំនៅឋាន មុខរបប ឈ្មោះសហព័ន្ធ ចំនួនកូន ឈ្មោះឪពុកម្ដាយ បទល្មើសដែលធ្លាប់បានប្រព្រឹត្តពីមុនដូចគ្នានឹងជនជាប់ចោទដែរ។ ចៅក្រមជំនុំជម្រះស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាក្សីតាមលំដាប់លំដោយដែលខ្លួនយល់ថាមានប្រយោជន៍។ ចៅក្រមជំនុំជម្រះក៏អាចសួរដើមបណ្ដឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាក្សីគ្រប់សំណួរដើម្បីបង្ហាញឲ្យឃើញការពិត។ បន្ទាប់ពីចៅក្រមជំនុំជម្រះបានស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាក្សី រួចចៅក្រមជំនុំជម្រះអនុញ្ញាតឲ្យតំណាងអយ្យការ និងភាគីអាចលើកជាសំណួរសួរដល់ដើមបណ្ដឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាក្សី។

ក្នុងករណីដែលជនរងគ្រោះជាអនីតិជនក៏តុលាការធ្វើការជំនុំជម្រះជាអសាធារណៈដូចជនជាប់ចោទជាអនីតិជនដែរ ហើយបុគ្គលដែលតុលាការអនុញ្ញាតឲ្យចូលរួមស្ដាប់បានលុះត្រាតែជា៖

- ភ្នាក់ងារសង្គមកិច្ច
- សាច់ញាតិរបស់ជនជាប់ចោទ
- សាច់ញាតិរបស់ជនរងគ្រោះ
- ដើមបណ្ដឹងរដ្ឋប្បវេណី
- ជនរងគ្រោះ
- សាក្សី

ក្នុងការសាកសួរដើម្បីស្ដាប់ចម្លើយជនរងគ្រោះជាអនីតិជន គឺតុលាការបង្កើតឲ្យមានការសាកសួរជាលក្ខណៈ កុមារមេត្រីដោយឲ្យអនីតិជននៅក្នុងបន្ទប់មួយក្រៅពីបន្ទប់សវនាការដើម្បីលួងលោម ឬលើកទឹកចិត្តអនីតិជនកុំឲ្យមានការភិតភ័យក្នុងការចូលរួមសវនាការ។ នៅក្នុងបន្ទប់នោះមានបំពាក់ឧបករណ៍ស្រូបសំលេង ឬ កាមេរ៉ា ដែលអាចឲ្យតុលាការសាកសួរ ឬ ស្ដាប់ចម្លើយក៏ដូចជាបានឃើញពីសកម្មភាពរបស់កុមារផងដែរ។ ការសម្រេចឲ្យកុមារនៅក្នុងបន្ទប់មួយក្រៅពីបន្ទប់សវនាការនេះ គឺដើម្បីជៀសវាងកុំឲ្យកុមារមានភាពភ័យតក់ស្លុតនៅពេលបានឃើញជនជាប់ចោទផ្ទាល់។

**បញ្ជាក់៖** នីតិវិធីកុមារមេត្រី សំដៅដល់ដំណើរការ និងនីតិវិធីដែលពាក់ព័ន្ធមឹងការលើកទឹកចិត្តឲ្យអនីតិជនចូលរួមក្នុងរឿងក្ដី តាមរយៈការប្រើប្រាស់ភាសា និងអាកប្បកិរិយាក្នុងកម្រិតដែលអនីតិជន

អាចយល់បាន និងក្នុងបរិយាកាសដែលផ្តល់ឲ្យអនីតិជននូវសុវត្ថិភាព សន្តិសុខ សិទ្ធិ និងតម្រូវការជាមូលដ្ឋាន។

ភ្នាក់ងារសង្គមកិច្ច សំដៅដល់មន្ត្រីក្រសួង មន្ទីរ ការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬបុគ្គលផ្សេងទៀតដែលទទួលបានការបណ្តុះបណ្តាលជំនាញផ្នែកកុមារ និងច្បាប់ពាក់ព័ន្ធនឹងអនីតិជន ហើយត្រូវទទួលបានការតែងតាំង ឬទទួលស្គាល់ពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។

**កថាខណ្ឌទី៣. កំណត់ហេតុក្នុងពេលសវនាការ**

នៅក្នុងអំឡុងពេលសវនាការក្រឡាបញ្ជីសរសេរកំណត់ហេតុសវនាការ ដែលមានគោលដៅផ្តល់មធ្យោបាយដល់សាលាឧទ្ធរណ៍ធ្វើការត្រួតពិនិត្យនីត្យានុកូលភាពនៃនីតិវិធី និងបានយល់ដឹងអំពីការពិភាក្សាដេញដោល។

ក្រឡាបញ្ជីត្រូវខិតខំរៀបរាប់ដោយយកចិត្តទុកដាក់អំពីការប្រព្រឹត្តទៅនៃសវនាការ និងកត់ត្រាឲ្យបានត្រឹមត្រូវតាមសំណួរដែលសួរព្រមទាំងចម្លើយរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ។

កំណត់ហេតុសវនាការត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងចុះទិដ្ឋការក្រោយពីការផ្ទៀងផ្ទាត់ដោយប្រធានសវនាការក្នុងរយៈពេល១០ថ្ងៃ ក្រោយថ្ងៃប្រកាសសាលក្រម[៦៨]។

**ផ្នែកទី២៖ ការប្រកាសសាលក្រម**

បន្ទាប់ពីកិច្ចពិភាក្សាដេញដោល ប្រធានសវនាការបើកឲ្យភាគីទាំងអស់ធ្វើសេចក្តីថ្លែងការណ៍ដូចតទៅ៖

- ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនជាប់ចោទដើម្បីធ្វើការកត់សម្គាល់ខ្លីៗ
- មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានការពារ
- តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានស្នើសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទ
- មេធាវីរបស់ជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានការពារ[៦៩]។

នៅក្នុងដំណាក់កាលនេះ ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ ឬ មេធាវីតំណាងដោយអាណត្តិរបស់ភាគីទាំងសងខាង អាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងបង្ហាញភស្តុតាង ឬលិខិតស្នាមផ្សេងៗដែលមានប្រយោជន៍សំរាប់សំដែងឲ្យឃើញការពិត។

សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរត្រូវចុះទិដ្ឋការដោយប្រធានសវនាការ និងក្រឡាបញ្ជីហើយភ្ជាប់ទៅក្នុងសំណុំរឿង [៧០]។

---

[៦៨]មាត្រា៣៨១ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៦៩]មាត្រា៣៣៥ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៧០]មាត្រា៣៣៨ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

ក្រោយពីបិទកិច្ចពិភាក្សាដេញដោល ចៅក្រមជំនុំជម្រះ ឬ ក្រុមប្រឹក្សាជំនុំជម្រះនឹងថយខ្លួនចូលទៅក្នុងបន្ទប់ពិភាក្សាប្រមាណជា ១៥ ទៅ ៣០នាទីដើម្បីធ្វើការពិភាក្សាសម្រេច។ ដំណាក់កាលនេះបណ្តឹងស្នើសុំ ឬ ការបង្ហាញភស្តុតាងបន្ថែមមិនអាចដាក់ជូនតុលាការបានទៀតទេ។ តំណាងអយ្យការ និងក្រឡាបញ្ជីមិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងការពិភាក្សាសម្រេចឡើយ។ ចំណែកសាធារណជនទាំងអស់ត្រូវនៅក្នុងបន្ទប់សវនាការដដែល ដើម្បីរងចាំស្តាប់ការប្រកាសសាលក្រមរបស់តុលាការ។

ការប្រកាសសាលក្រមត្រូវប្រកាសជាសាធារណៈ នៅថ្ងៃដែលពិភាក្សាដេញដោល ឬនៅក្រោយពេលសវនាការ។ នៅក្នុងសេចក្តីសម្រេចរបស់តុលាការមានបញ្ជាក់ពីការកំណត់នូវពិរុទ្ធភាព ព្រមទាំងប្រកាសអំពីទោសដែលត្រូវបានកំណត់ដោយច្បាប់។ ក្នុងករណីដែលតុលាការយល់ឃើញថាមិនមែនជាបទល្មើស ឬជនជាប់ចោទមិនមាននូវពិរុទ្ធភាពតុលាការអាចប្រកាសសាលក្រមដោយសម្រេចឲ្យជនជាប់ចោទរួចផុតពីការចោទប្រកាន់។

ប្រសិនបើតុលាការសម្រេចថាមានទោសដោយត្រូវដាក់ពន្ធនាគារនោះតុលាការអាចចេញដីកាបង្គាប់ឲ្យឃុំខ្លួន បើជនជាប់ចោទមានវត្តមាននៅក្នុងសវនាការ ឬចេញដីកាបង្គាប់ឲ្យចាប់ខ្លួនបើជនជាប់ចោទអវត្តមាននៅក្នុងពេលសវនាការ។

**កថាខណ្ឌទី១. ការតាក់តែងសាលក្រម**

នៅគ្រប់សាលក្រមទាំងអស់ការតាក់តែងតម្រូវជាដាច់ខាតមានពីរផ្នែកគឺ [៧១] ៖

- ផ្នែកសំអាងហេតុពោលគឺទឡ្ហីករណ៍នៃអង្គហេតុ និងអង្គច្បាប់ដែលនាំឲ្យតុលាការចេញសេចក្តីសម្រេច។
- ផ្នែកសម្រេចពោលគឺសេចក្តីសម្រេចរបស់តុលាការ។

អង្គហេតុត្រូវតែច្បាស់លាស់ និងគ្មានការសង្ស័យ។ តុលាការត្រូវត្រួតពិនិត្យបទចោទនីមួយៗ និងទឡ្ហីករណ៍ដែលបានលើកឡើងនៅពេលសវនាការ។

នៅក្នុងសំអាងហេតុ តុលាការត្រូវឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់គូភាគី។ ផ្នែកសេចក្តីសម្រេចត្រូវចុះនិទ្ទេស អំពីបទល្មើសដែលជនជាប់ចោទបានប្រព្រឹត្តខុសអត្តបទច្បាប់ដែលបានអនុវត្តទោស និងទណ្ឌកម្មរដ្ឋប្បវេណី។

និទ្ទេសដែលត្រូវចុះលើសាលក្រម ៖

- កាលបរិច្ឆេទនៃសវនាការ
- កាលបរិច្ឆេទនៃការប្រកាសសាលក្រម
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលជំនុំជម្រះ
- ឈ្មោះ និងឋានៈរបស់តំណាងអយ្យការ
- ឈ្មោះ និងឋានៈរបស់ក្រឡាបញ្ជី
- ឈ្មោះ ទីលំនៅ កាលបរិច្ឆេទ និងទីកន្លែងកំណើត មុខរបររបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

[៧១] មាត្រា៣៥៧ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

- ឈ្មោះរបស់មេធាវី។
- ហត្ថលេខា និងត្រារបស់ចៅក្រម និងក្រឡាបញ្ជី

សាលក្រមត្រូវចុះហត្ថលេខាដោយប្រធាន និងក្រឡាបញ្ជី។ ក្រោយពីបានចុះហត្ថលេខាដោយប្រធាន និងក្រឡាបញ្ជីរួច សាលក្រមដើមត្រូវតំកល់ទុកនៅការិយាល័យក្រឡាបញ្ជីយ៉ាងយូរបំផុត៨ថ្ងៃក្រោយការប្រកាសសាលក្រម។ ការិយាល័យក្រឡាបញ្ជីត្រូវរក្សាទុកសាលក្រមដើមជានិច្ច។ ក្រឡាបញ្ជីអាចផ្តល់ច្បាប់ចម្លងនៃសាលក្រមជាអាទិ៍ ក្នុងករណីមានបណ្តឹងឧទ្ធរណ៍ [៧២]។

**កថាខណ្ឌទី២. ការប្រកាសសាលក្រម**

បន្ទាប់ពីធ្វើការពិភាក្សាសម្រេចរបស់តុលាការ យល់ឃើញថាមានភស្តុតាងគ្រប់គ្រាន់ មានពិរុទ្ធភាពអាចដាក់បន្ទុកបានទៅលើជនជាប់ចោទហើយនោះចៅក្រមជំនុំជម្រះចេញមកប្រកាសសាលក្រមភ្លាមៗជាសាធារណៈ។ គ្រប់សាលក្រមត្រូវតែប្រកាសនៅពេលសវនាការសាធារណៈ។ ផ្នែកនៃសេចក្តីសម្រេចត្រូវអានដោយសម្លេងខ្លាំងៗដោយប្រធានសវនាការ [៧៣]។ ការប្រកាសសាលក្រមរបស់តុលាការជាទូទៅគឺ៖

- តាងនាមប្រជារាស្ត្រខ្មែរ
- ខ្លឹមសារនៃសេចក្តីសម្រេច
- តុលាការសម្រេចប្រកាសសាលក្រមជាសាធារណៈចំពោះមុខគូភាគី ឬកំបាំងមុខគូភាគីណាម្ខាង ឬសាលក្រមចាត់ថាចំពោះមុខ
- ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងជនជាប់ចោទមានសិទ្ធិក្នុងការប្តឹងទាស់ដែលមានរយៈពេល១៥ថ្ងៃ ឬ ប្តឹងឧទ្ធរណ៍ដែលមានរយៈពេលកំណត់ ១ខែដោយចាប់គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ផុតរយៈពេលកំណត់ខាងលើគ្មានការប្តឹងទាស់ ឬ ប្តឹងឧទ្ធរណ៍សាលក្រមនឹងចូលជាស្ថាពរ។

ការប្រកាសសាលក្រម គឺតុលាការអាចលើកទៅប្រកាសនៅសវនាការលើកក្រោយបាន ប្រសិនបើរឿងក្តីមានលក្ខណៈស្មុគស្មាញ ប្រធានសវនាការជូនដំណឹងដល់គូភាគីដែលមានវត្តមាន និងអវត្តមានអំពីថ្ងៃដែលត្រូវប្រកាសសាលក្រម ។

ក្រោយពីបញ្ចប់ការជំនុំជម្រះជនជាប់ចោទត្រូវផ្តិតមេដៃលើកំណត់ហេតុសវនាការនៅកន្លែងក្រឡាបញ្ជី។

**១. សាលក្រមចំពោះមុខ**

សាលក្រមចំពោះមុខ គឺជាសាលក្រមដែលតុលាការចេញចំពោះមុខ ជនជាប់ចោទ ជនរងគ្រោះដើមបណ្តឹងរដ្ឋប្បវេណី និងបុគ្គលដែលពាក់ព័ន្ធនិងរឿងក្តីទាំងអស់ដែលមានវត្តមាននៅក្នុងពេលសវនាការ។ សាលក្រមចំពោះនេះក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានឲ្យនិយមន័យឲ្យបានច្បាស់លាស់នោះទេ។ ប៉ុន្តែយើងអាចកំណត់សម្គាល់ចំពោះសាលក្រមនេះបានដោយពិនិត្យលើស្ថានភាពជាក់ស្តែងដែលជាហេតុនាំឲ្យតុលាការចេញសាលក្រមចំពោះមុខ។

[៧២] មាត្រា៣៥៨ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៧៣] មាត្រា៣៥៩ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

ប្រសិនបើជនជាប់ចោទចូលបង្ហាញខ្លួន នៅក្នុងពេលសវនាការតុលាការនឹងចេញសាលក្រមចំពោះមុខជនជាប់ចោទ។ សាលក្រមចំពោះមុខជនជាប់ចោទមិនត្រូវឲ្យដំណឹងដល់ជនជាប់ចោទទេ។ សាលក្រមនៅតែជាសាលក្រមចំពោះមុខដដែល ទោះបីជាជនជាប់ចោទចាកចេញពីបន្ទប់សវនាការក៏ដោយ។ សាលក្រមចំពោះមុខអាចប្ដឹងឧទ្ធរណ៍បាន[៧៤]។

ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីចូលបង្ហាញខ្លួននៅក្នុងពេលសវនាការ នោះតុលាការនឹងចេញសាលក្រមចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី។ សាលក្រមចំពោះមុខមិនត្រូវជូនដំណឹងដល់ដើមបណ្ដឹងរដ្ឋប្បវេណីទេ។ សាលក្រមចំពោះមុខអាចប្ដឹងឧទ្ធរណ៍បាន [៧៥]។

ប្រសិនបើអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ចូលបង្ហាញខ្លួននៅក្នុងពេលសវនាការនោះតុលាការនឹងចេញសាលក្រមចំពោះមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ សាលក្រមចំពោះមុខមិនត្រូវជូនដំណឹងដល់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីទេ។ សាលក្រមចំពោះមុខអាចប្ដឹងឧទ្ធរណ៍បាន [៧៦]។

### ២. សាលក្រមកំបាំងមុខ

សាលក្រមកំបាំងមុខ គឺជាសាលក្រមដែលតុលាការប្រកាសកំបាំងមុខជនជាប់ចោទ ជនរងគ្រោះ ដើមបណ្ដឹរដ្ឋប្បវេណី និងបុគ្គលដែលពាក់ព័ន្ធនឹងរឿងក្ដីទាំងអស់ដែលអវត្តមាននៅក្នុងពេលសវនាការ។ ប្រសិនបើជនជាប់ចោទមិនបានចូលបង្ហាញខ្លួននៅក្នុងពេលសវនាការទេ ហើយប្រសិនបើគ្មានភស្តុតាងបញ្ជាក់ថាសាមីខ្លួនបានដឹងពីដីកាបញ្ជូនទៅជំនុំជម្រះ ឬ បានដឹងអំពីការកោះហៅនោះទេ តុលាការនឹងប្រកាសសាលក្រមកំបាំងមុខជនជាប់ចោទ។ សាលក្រមកំបាំងមុខត្រូវឲ្យដំណឹងដល់ជនជាប់ចោទ។ សាលក្រមកំបាំងមុខនេះអាចប្ដឹងទាស់បាន [៧៧]។

ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីមិនបានចូលបង្ហាញខ្លួននៅក្នុងពេលសវនាការទេ និងគ្មានអ្នកតំណាងត្រឹមត្រូវទេ នោះតុលាការនឹងចេញសាលក្រមកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី។ សាលក្រមកំបាំងមុខត្រូវជូនដំណឹងដល់ដើមបណ្ដឹងរដ្ឋប្បវេណី។ សាលក្រមកំបាំងមុខនេះអាចប្ដឹងទាស់បាន [៧៨]។

ប្រសិនបើអ្នកទទួលខុសត្រូវរដ្ឋប្បវេណីមិនបានចូលបង្ហាញខ្លួននៅក្នុងពេលសវនាការទេហើយគ្មានអ្នកតំណាងត្រឹមត្រូវទេ តុលាការនឹងចេញសាលក្រមកំបាំងមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ សាលក្រមកំបាំងមុខត្រូវជូនដំណឹងដល់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ សាលក្រមកំបាំងមុខនេះអាចប្ដឹងទាស់បាន [៧៩]។

---

[៧៤] មាត្រា៣៦០ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៧៥] មាត្រា៣៦៣ វាក្យខ័ណ្ឌទី១ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៧៦] មាត្រា៣៦៤ វាក្យខ័ណ្ឌទី១ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៧៧] មាត្រា៣៦២ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៧៨] មាត្រា៣៦៣ វាក្យខ័ណ្ឌទី២ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៧៩] មាត្រា៣៦៤ វាក្យខ័ណ្ឌទី២ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

### ៣.សាលក្រមចាត់ទុកថាចំពោះមុខ

សាលក្រមចាត់ថាចំពោះមុខ គឺជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះមិនបានចូលបង្ហាញខ្លួនក្នុងសវនាការទេ ប៉ុន្តែសាមីខ្លួនបានដឹងពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងពីដីកាកោះហៅ នោះសាលក្រមដែលតុលាការប្រកាសចាត់ទុកថាជាសាលក្រមចំពោះមុខ។

ប្រសិនបើជនជាប់ចោទមិនបានចូលបង្ហាញខ្លួននៅក្នុងពេលសវនាការទេ ហើយសាមីខ្លួនបានដឹងពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងអំពីការកោះហៅនោះតុលាការនឹងប្រកាសសាលក្រមចាត់ថាចំពោះមុខជនជាប់ចោទ។ សាលក្រមចាត់ថាចំពោះមុខត្រូវឲ្យដំណឹងដល់ជនជាប់ចោទ។ សាលក្រមចាត់ថាចំពោះមុខនេះអាចប្តឹងឧទ្ធរណ៍បាន[៨០]។ប៉ុន្តែក្នុងករណីដែលជនជាប់ចោទវត្តមានដោយមានផ្តល់ដំណឹងជាមុនដល់តុលាការ ព្រមទាំងបង្ហាញពីមូលហេតុនៃការអវត្តមានរបស់ខ្លួន ហើយមូលហេតុនោះតុលាការអាចទទួលយកបាននោះ តុលាការអាចសម្រេចលើករឿងទៅជំនុំជម្រះនៅសវនាការលើកក្រោយបាន។

ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីមិនបានចូលបង្ហាញខ្លួននៅក្នុងពេលសវនាការទេហើយសាមីខ្លួនបានដឹងពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងអំពីការកោះហៅនោះតុលាការនឹងប្រកាសសាលក្រមចាត់ថាចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី។ សាលក្រមចាត់ថាចំពោះមុខត្រូវឲ្យដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណី។ សាលក្រមចាត់ថាចំពោះមុខនេះអាចប្តឹងឧទ្ធរណ៍បាន។ ប៉ុន្តែក្នុងករណីដែលដើមបណ្តឹងរដ្ឋប្បវេណីអវត្តមានដោយមានការផ្តល់ដំណឹងជាមុនដល់តុលាការ ព្រមទាំងមានបង្ហាញពីមូលហេតុនៃការអវត្តមានរបស់ខ្លួន ហើយមូលហេតុនោះតុលាការអាចទទួលយកបាន នោះតុលាការអាចសម្រេចលើករឿងទៅជំនុំជម្រះនៅសវនាការលើកក្រោយបាន។

ប្រសិនបើអ្នកទទួលខុសត្រូវរដ្ឋប្បវេណីមិនបានចូលបង្ហាញខ្លួននៅក្នុងពេលសវនាការទេហើយសាមីខ្លួនបានដឹងពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងអំពីការកោះហៅនោះតុលាការនឹងប្រកាសសាលក្រមចាត់ថាចំពោះមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។ សាលក្រមចាត់ថាចំពោះមុខត្រូវឲ្យដំណឹងដល់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ សាលក្រមចាត់ថាចំពោះមុខនេះអាចប្តឹងឧទ្ធរណ៍បាន។ ប៉ុន្តែក្នុងករណីដែលអ្នកទទួលខុសត្រូវរដ្ឋប្បវេណីអវត្តមានដោយមានផ្តល់ដំណឹងជាមុនដល់តុលាការ ព្រមទាំងបង្ហាញពីមូលហេតុនៃការអវត្តមានរបស់ខ្លួនហើយមូលហេតុនោះតុលាការអាចទទួលយកបាន នោះតុលាការអាចសម្រេចលើករឿងទៅជំនុំជម្រះនៅសវនាការលើកក្រោយបាន។

## ផ្នែកទី៣៖ ដីកាឲ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ

ដីកាឲ្យដំណឹង គឺជាលិខិតដែលឲ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការដែលបញ្ញត្តិច្បាប់តម្រូវឲ្យជូនដំណឹងដល់ភាគីពាក់ព័ន្ធ ដើម្បីឲ្យភាគីពាក់ព័ន្ធទទួលបានដំណឹងអំពីសេចក្តីសម្រេចនោះ[៨១]។ ដីកាឲ្យដំណឹងចេញដោយព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញា។

ដីកាឲ្យដំណឹងមានចុះនិទ្ទេសដូចជា៖

- ប្រភេទ និងការយោងសេចក្តីសម្រេចដែលត្រូវជូនដំណឹង។

[៨០]មាត្រា៣៦១ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៨១]មាត្រា៤៨២ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

- អត្តសញ្ញាណ និងលំនៅឋាននៃភាគីដែលត្រូវទទួលដំណឹងអំពីសេចក្តីសម្រេច។
- កាលបរិច្ឆេទ និងហត្ថលេខារបស់អ្នកដែលត្រូវជូនដំណឹង។

ដីកានេះត្រូវបញ្ជាក់ប្រាប់អំពីផ្លូវតវ៉ាដែលអាចធ្វើបាន ដើម្បីប្រឆាំងទៅនឹងសេចក្តីសម្រេចដែលត្រូវបានជូនដំណឹង។ លិខិតចម្លងនៃសេចក្តីសម្រេចជូនដំណឹងត្រូវភ្ជាប់ជាមួយនឹងដីកាឲ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ[៨២]។

**កថាខណ្ឌទី១. ការជូនដំណឹងដល់ជាប់ចោទ**

ការជូនដំណឹងអាចប្រគល់ឲ្យជនជាប់ចោទដោយផ្ទាល់ដៃរបស់ព្រះរាជអាជ្ញា។ ករណីនេះព្រះរាជអាជ្ញាប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចរបស់តុលាការដល់ជនជាប់ចោទ ដោយចុះនិទ្ទេសលើសេចក្តីសម្រេចដើមអំពីកាលបរិច្ឆេទ និងទីកន្លែងនៃការប្រគល់លិខិតចម្លង ហើយជនជាប់ចោទត្រូវចុះហត្ថលេខានៅលើសេចក្តីសម្រេចដើមនោះ[៨៣]។

លិខិតចម្លងនៃសេចក្តីសម្រេចអាចប្រគល់ដោយអាជ្ញាសាលាទៅដល់លំនៅឋានរបស់ជនជាប់ចោទដែលកំពុងស្នាក់នៅ ឬ នៅកន្លែងផ្សេងទៀតដែលអាជ្ញាសាលាបានជួបប្រទះជនជាប់ចោទ។ អាជ្ញាសាលាចារនៅលើសេចក្តីសម្រេចដើមថា លិខិតចតចម្លងត្រូវបានប្រគល់ដល់ជនជាប់ចោទដោយផ្ទាល់ដៃ។ អាជ្ញាសាលាចុះនិទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់លិខិតចម្លង។ ជនជាប់ចោទត្រូវចុះហត្ថលេខានៅលើសេចក្តីសម្រេចដើម។ សេចក្តីសម្រេចដើមត្រូវបង្វិលជូនមកព្រះរាជអាជ្ញាវិញជាបន្ទាន់[៨៤]។ ករណីដែលជនជាប់ចោទអវត្តមានពីលំនៅឋាន អាជ្ញាសាលាអាចប្រគល់លិខិតចម្លងនៃសេចក្តីសម្រេច ទៅដល់បុគ្គលណាជានីតិជនមានវត្តមាននៅក្នុងលំនៅឋាន។ អាជ្ញាសាលាចុះនិទ្ទេសអំពីអត្តសញ្ញាណនៃបុគ្គលនេះ និងអំពីកាលបរិច្ឆេទនៃការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេច។ បុគ្គលដែលទទួលចុងដីកាកោះត្រូវចុះហត្ថលេខានៅលើសេចក្តីសម្រេចដើម។ សេចក្តីសម្រេចដើមត្រូវបង្វិលជូនមកព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលទទួលលិខិតចតចម្លងនៃសេចក្តីសម្រេច ត្រូវសន្យាថានឹងប្រគល់ដីកានេះដល់ជនជាប់ចោទក្នុងរយៈពេលដ៏ខ្លីបំផុត[៨៥]។

អាជ្ញាសាលាអាចប្រគល់លិខិតចតចម្លងនៃសេចក្តីសម្រេចឲ្យមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រងក្នុងករណី៖

- ជនជាប់ចោទមិនព្រមទទួលសេចក្តីសម្រេច ។
- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទ។
- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទ យល់ព្រមទទួលសេចក្តីសម្រេចទេ។

---

[៨២]មាត្រា៤៨៣ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៨៣]មាត្រា៤៨៤ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៨៤]មាត្រា៤៨៦ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៨៥]មាត្រា៤៨៧ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

អាជ្ញាសាលាចុះនិទ្ទេសនៅលើសេចក្តីសម្រេចដើម អំពីអត្តសញ្ញាណ និងឋានៈបុគ្គលដែលបានទទួលលិខិតចម្លងនៃសេចក្តីសម្រេចព្រមទាំងកាលបរិច្ឆេទនៃការប្រគល់។ បុគ្គលដែលទទួលលិខិតថតចម្លង ត្រូវចុះហត្ថលេខានៅលើសេចក្តីសម្រេចដើម។ សេចក្តីសម្រេចដើមត្រូវបង្វិលត្រឡប់ជូនព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលបានទទួលលិខិតថតចម្លងនៃសេចក្តីសម្រេចត្រូវសន្យាថានឹងប្រគល់ដីកានេះក្នុងរយៈពេលដ៏ខ្លីបំផុតឲ្យដល់ជនជាប់ចោទ[៨៦]។

ការជូនដំណឹងក៏អាចត្រូវប្រគល់តាមរយៈ ៖

- ក្រឡាបញ្ជី
- អាជ្ញាធររដ្ឋបាល
- ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវជាប់ឃុំខ្លួនពីបទផ្សេងទៀត
- អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ

ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល ប្រធានពន្ធនាគារ មន្ត្រីនគរបាលជាតិ ឬកងរាជអាវុធហត្ថត្រូវគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញា ក្នុងការប្រគល់លិខិតជូនដំណឹងស្តីពីសេចក្តីសម្រេចរបស់តុលាការ[៨៧]។

**កថាខណ្ឌទី២. ការជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណី**

ការជូនដំណឹងអាចប្រគល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្ទាល់ដៃរបស់ព្រះរាជអាជ្ញា។ ករណីនេះព្រះរាជអាជ្ញាប្រគល់លិខិតថតចម្លងនៃសេចក្តីសម្រេចរបស់តុលាការដល់ ដើមបណ្តឹងរដ្ឋប្បវេណី ដោយចុះនិទ្ទេសនៅលើសេចក្តីសម្រេចដើមអំពីកាលបរិច្ឆេទ និងទីកន្លែងនៃការប្រគល់លិខិតថតហើយដើមបណ្តឹងរដ្ឋប្បវេណី ត្រូវចុះហត្ថលេខានៅលើសេចក្តីសម្រេចដើមនោះ។

លិខិតថតចម្លងនៃសេចក្តីសម្រេចអាចប្រគល់ដោយអាជ្ញាសាលាទៅដល់លំនៅឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលកំពុងស្នាក់នៅ ឬនៅកន្លែងផ្សេងទៀតដែលអាជ្ញាសាលាបានជួបប្រទះដើមបណ្តឹងរដ្ឋប្បវេណី។ អាជ្ញាសាលាចារនៅលើសេចក្តីសម្រេចដើមថាលិខិតថតចម្លងត្រូវបានប្រគល់ដល់ដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃ។ អាជ្ញាសាលាចុះនិទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់លិខិតថតចម្លង។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវចុះហត្ថលេខានៅលើសេចក្តីសម្រេចដើម។ សេចក្តីសម្រេចដើមត្រូវបង្វិលជូនមកព្រះរាជអាជ្ញាវិញជាបន្ទាន់។ ករណីដែលដើមបណ្តឹងរដ្ឋប្បវេណីអវត្តមានពីលំនៅឋានអាជ្ញាសាលាអាចប្រគល់លិខិតថតចម្លងនៃសេចក្តីសម្រេច ទៅដល់បុគ្គលណាជានីតិជនមានវត្តមាននៅក្នុងលំនៅឋាន។ អាជ្ញាសាលាចុះនិទ្ទេសអំពីអត្តសញ្ញាណនៃបុគ្គលនេះ និងអំពីកាលបរិច្ឆេទនៃការប្រគល់លិខិតថតចម្លងនៃសេចក្តីសម្រេច។

បុគ្គលដែលទទួលចុងដីកាកោះត្រូវចុះហត្ថលេខានៅលើសេចក្តីសម្រេចដើម។ សេចក្តីសម្រេចដើមត្រូវបង្វិលជូនមកព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលទទួលលិខិតថតចម្លងនៃសេចក្តីសម្រេចត្រូវសន្យាថានឹងប្រគល់ដីកានេះដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរយៈពេលដ៏ខ្លីបំផុត។

---

[៨៦]មាត្រា៤៨៨ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៨៧]មាត្រា៤៨៩ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

អាជ្ញាសាលាអាចប្រគល់លិខិតថតចម្លងនៃសេចក្តីសម្រេចឲ្យមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រងក្នុងករណី៖

- ដើមបណ្តឹងរដ្ឋប្បវេណីមិនព្រមទទួលសេចក្តីសម្រេច ។
- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។
- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី យល់ព្រមទទួលសេចក្តីសម្រេចទេ។

អាជ្ញាសាលាចុះនិទ្ទេសនៅលើសេចក្តីសម្រេចដើមអំពីអត្តសញ្ញាណ និងឋានៈបុគ្គលដែលបានទទួលលិខិតថតចម្លងនៃសេចក្តីសម្រេច ព្រមទាំងកាលបរិច្ឆេទនៃការប្រគល់។ បុគ្គលដែលទទួលលិខិតថតចម្លងត្រូវចុះហត្ថលេខានៅលើសេចក្តីសម្រេចដើម។ សេចក្តីសម្រេចដើមត្រូវបង្វិលត្រឡប់ជូនព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលបានទទួលលិខិតថតចម្លងនៃសេចក្តីសម្រេចត្រូវសន្យាថានឹងប្រគល់ដីកានេះក្នុងរយៈពេលដ៏ខ្លីបំផុតឲ្យដល់ដើមបណ្តឹងរដ្ឋប្បវេណី។

ការជូនដំណឹងក៏អាចត្រូវប្រគល់តាមរយៈ ៖

- ក្រឡាបញ្ជី
- អាជ្ញាធររដ្ឋបាល
- អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ

ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល មន្ត្រីនគរបាលជាតិ ឬកងរាជអាវុធហត្ថត្រូវគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញាក្នុងការប្រគល់លិខិតជូនដំណឹងស្តីពីសេចក្តីសម្រេចរបស់តុលាការ។

**កថាខណ្ឌទី៣. ការជូនដំណឹងដល់ជនរងគ្រោះ**

ការជូនដំណឹងអាចប្រគល់ឲ្យជនរងគ្រោះ ដោយផ្ទាល់ដៃរបស់ព្រះរាជអាជ្ញា។ ករណីនេះព្រះរាជអាជ្ញាប្រគល់លិខិតថតចម្លងនៃសេចក្តីសម្រេចរបស់តុលាការដល់ជនរងគ្រោះ ដោយចុះនិទ្ទេសនៅលើសេចក្តីសម្រេចដើមអំពីកាលបរិច្ឆេទ និងទីកន្លែងនៃការប្រគល់លិខិតថតចម្លងហើយជនរងគ្រោះត្រូវចុះហត្ថលេខានៅលើសេចក្តីសម្រេចដើមនោះ។

លិខិតថតចម្លងនៃសេចក្តីសម្រេចអាចប្រគល់ដោយអាជ្ញាសាលាទៅដល់លំនៅឋានរបស់ជនរងគ្រោះដែលកំពុងស្នាក់នៅ ឬនៅកន្លែងផ្សេងទៀតដែលអាជ្ញាសាលាបានជួបប្រទះជនរងគ្រោះ។ អាជ្ញាសាលាចារនៅលើសេចក្តីសម្រេចដើមថាលិខិតថតចម្លងត្រូវបានប្រគល់ដល់ជនរងគ្រោះដោយផ្ទាល់ដៃ។ អាជ្ញាសាលាចុះនិទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់លិខិតថតចម្លង។ ជនរងគ្រោះត្រូវចុះហត្ថលេខានៅលើសេចក្តីសម្រេចដើម។ សេចក្តីសម្រេចដើមត្រូវបង្វិលត្រឡប់ជូនមកព្រះរាជអាជ្ញាវិញជាបន្ទាន់។ ករណីដែលជនរងគ្រោះអវត្តមានពីលំនៅឋាន អាជ្ញាសាលាអាចប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចទៅដល់ បុគ្គលណាជានីតិជនមានវត្តមាននៅក្នុងលំនៅឋាន។ អាជ្ញាសាលាចុះនិទ្ទេសអំពីអត្តសញ្ញាណនៃបុគ្គលនេះ និងអំពីកាលបរិច្ឆេទនៃការប្រគល់លិខិតថតចម្លងនៃសេចក្តីសម្រេច។ បុគ្គលដែលទទួលចុងដីកាកោះត្រូវចុះហត្ថលេខានៅលើសេចក្តីសម្រេចដើម។ សេចក្តីសម្រេចដើមត្រូវបង្វិលជូនមកព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គល

ដែលទទួលលិខិតថតចម្លងនៃសេចក្តីសម្រេចត្រូវសន្យាថានឹងប្រគល់ដីកានេះដល់ជនរងគ្រោះក្នុងរយៈពេលដ៏ខ្លីបំផុត។

អាជ្ញាសាលាអាចប្រគល់លិខិតថតចម្លងនៃសេចក្តីសម្រេចឲ្យមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រងក្នុងករណី៖

- ជនរងគ្រោះមិនព្រមទទួលសេចក្តីសម្រេច ។
- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ជនរងគ្រោះ ។
- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ជនរងគ្រោះ យល់ព្រមទទួលសេចក្តីសម្រេចទេ។

អាជ្ញាសាលាចុះនិទ្ទេសនៅលើសេចក្តីសម្រេចដើម អំពីអត្តសញ្ញាណ និងឋានៈបុគ្គលដែលបានទទួលលិខិតថតចម្លងនៃសេចក្តីសម្រេចព្រមទាំងកាលបរិច្ឆេទនៃការប្រគល់។ បុគ្គលដែលទទួលលិខិតថតចម្លងត្រូវចុះហត្ថលេខានៅលើសេចក្តីសម្រេចដើម។ សេចក្តីសម្រេចដើមត្រូវបង្វិលត្រឡប់ជូនព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលបានទទួលលិខិតថតចម្លងនៃសេចក្តីសម្រេចត្រូវសន្យាថានឹងប្រគល់ដីកានេះក្នុងរយៈពេលដ៏ខ្លីបំផុតឲ្យដល់ជនរងគ្រោះ។

ការជូនដំណឹងក៏អាចត្រូវប្រគល់តាមរយៈ

- ក្រឡាបញ្ជី
- អាជ្ញាធររដ្ឋបាល
- អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ

ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល មន្ត្រីនគរបាលជាតិ ឬកងរាជអាវុធហត្ថត្រូវគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញាក្នុងការប្រគល់លិខិតជូនដំណឹងស្តីពីសេចក្តីសម្រេចរបស់តុលាការ។

**កថាខណ្ឌទី៤. បណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍**

**១. បណ្តឹងទាស់**

ពិរុទ្ធជនអាចធ្វើបណ្តឹងទាស់ប្រឆាំងនឹងសាលក្រមដែលប្រកាសកំបាំងមុខខ្លួនបាន[៨៨]។ បណ្តឹងទាស់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរនៅការិយាល័យក្រឡាបញ្ជីសាលាដំបូងដែលបានប្រកាសសាលក្រម ឬនៅចំពោះមុខព្រះរាជអាជ្ញា អង្គភាពនគរបាលយុត្តិធម៌ ឬនៅចំពោះមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។

មេធាវីអាចតំណាងឲ្យពិរុទ្ធជនក្នុងការធ្វើបណ្តឹងទាស់ដោយមានលិខិតប្រគល់សិទ្ធិឲ្យធ្វើបណ្តឹងទាស់។ ឪពុក-ម្តាយ ឬអាណាព្យាបាលអាចតំណាងឲ្យពិរុទ្ធជនជាអនីតិជនក្នុងការធ្វើបណ្តឹងទាស់ដោយពុំចាំបាច់មានលិខិតប្រគល់សិទ្ធិឡើយ។

នៅពេលដែលព្រះរាជអាជ្ញា អង្គភាពនគរបាលយុត្តិធម៌ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនទទួលបានពាក្យបណ្តឹងទាស់ហើយត្រូវបញ្ជូនបណ្តឹងទាស់ទៅក្រឡាបញ្ជីនៃសាលាដំបូងដែលបានប្រកាសសាលក្រមភ្លាម។

[៨៨]មាត្រា៣៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

កាលណាអ្នកប្តឹងទាស់មិនចេះចុះហត្ថលេខាទេ អ្នកប្តឹងទាស់អាចផ្តិតមេដៃ[៥៩]។

បណ្តឹងទាស់អាចធ្វើឡើងក្នុងរយៈពេល១៥ថ្ងៃ គិតចាប់ពី ៖

- ថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់ឲ្យពិរុទ្ធជនផ្ទាល់ដៃ
- ថ្ងៃដែលពិរុទ្ធជនបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមមិនបានប្រគល់ដល់ពិរុទ្ធជនផ្ទាល់ដៃ[៦០]។

ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះក៏អាចធ្វើបណ្តឹងទាស់នឹងសាលក្រមកំបាំងមុខខ្លួនបានដែរ។ បណ្តឹងទាស់នេះកំណត់តែទៅលើផ្នែកសេចក្តីសម្រេចរដ្ឋប្បវេណីនៃសាលក្រមប៉ុណ្ណោះ។ បណ្តឹងទាស់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរនៅការិយាល័យក្រឡាបញ្ជីនៃសាលាដំបូងដែលបានប្រកាសសាលក្រម។ មេធាវី សហព័ន្ធ ឬញាតិលោហិតផ្ទាល់អាចតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ ក្នុងការធ្វើបណ្តឹងទាស់ដោយមានលិខិតប្រគល់សិទ្ធិឲ្យធ្វើបណ្តឹងទាស់។

បណ្តឹងទាស់អាចធ្វើឡើងក្នុងរយៈពេល១៥ថ្ងៃគិតចាប់ពី៖

- ថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះផ្ទាល់ដៃ
- ថ្ងៃដែលដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រមកាលណាសាលក្រមមិនបានប្រគល់ដល់ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ ផ្ទាល់ដៃ[៦១]។

បន្ទាប់ពីសាលាដំបូងទទួលបានបណ្តឹងទាស់នឹងការប្រកាសសាលក្រម តុលាការពិនិត្យលើភាពអាចទទួលយកបាននៃបណ្តឹងទាស់នេះ រួចសម្រេចអង្គសេចក្តីជាថ្មី។ ប្រធានតុលាការធ្វើការកំណត់កាលបរិច្ឆេទសវនាការ ដោយចាត់ចៅក្រមជំនុំជម្រះផ្សេងទៀតមកទទួលបន្ទុក ហើយព្រះរាជអាជ្ញាចេញដីកាកោះហៅភាគីឲ្យចូលបង្ហាញខ្លួន។ ប្រសិនបើដល់ថ្ងៃបើកសវនាការអ្នកប្តឹងទាស់មិនចូលបង្ហាញខ្លួនទេ តុលាការប្រកាសថាបណ្តឹងទាស់ជាឯកសារឥតបានការ សាលក្រមដែលគេប្តឹងទាស់គ្មានការប្រែប្រួល និងនៅតែមានអនុភាពលើភាគីទាំងអស់។

បណ្តឹងទាស់ដែលធ្វើឡើងប្រឆាំងនឹងសាលក្រមទាំងមូលនាំឲ្យសាលក្រមត្រូវចាត់ទុកជាអសារបង់ ហើយការអនុវត្តសាលក្រមត្រូវព្យួរ[៦២]។

### ២. បណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ នៅពេលដែលផុតអាជ្ញាយុការនៃការប្តឹងទាស់ចំពោះសាលក្រមចំពោះមុខ និងសាលក្រមចាត់ទុកថាចំពោះមុខ។

ការប្តឹងឧទ្ធរណ៍ចំពោះសាលក្រមចំពោះមុខគិតចាប់ពីថ្ងៃប្រកាសសាលក្រម។ចំណែកឯការប្តឹងឧទ្ធរណ៍ចំពោះសាលក្រមចាត់ទុកថាចំពោះមុខគិតចាប់ពីថ្ងៃទទួលដំណឹងសាលក្រម។

[៥៩] មាត្រា៣៦៦ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៦០] មាត្រា៣៦៨ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៦១] មាត្រា៣៧២ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

[៦២] មាត្រា៣៧០ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

មេធាវីអាចតំណាងឲ្យពិរុទ្ធជនក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ ដោយមានលិខិតប្រគល់សិទ្ធិឲ្យធ្វើបណ្តឹងឧទ្ធរណ៍។ ឪពុក-ម្តាយ ឬអាណាព្យាបាលអាចតំណាងឲ្យពិរុទ្ធជនជាអនីតិជនក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ដោយពុំចាំបាច់មានលិខិតប្រគល់សិទ្ធិឡើយ។

មេធាវី សហព័ន្ធ ឬញាតិលោហិតផ្ទាល់អាចតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ ដោយមានលិខិតប្រគល់សិទ្ធិឲ្យធ្វើបណ្តឹងឧទ្ធរណ៍។

បណ្តឹងរបស់ព្រះរាជអាជ្ញា ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះធ្វើឡើងជាលាយលក្ខណ៍អក្សរនៅការិយាល័យក្រឡាបញ្ជីនៃសាលាដំបូង និងត្រូវធ្វើក្នុងរយៈពេល១ខែគិតចាប់ពីថ្ងៃប្រកាសសាលក្រម។ ចំពោះករណីមានការឃុំខ្លួន បណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយព្រះរាជអាជ្ញាក្នុងរយៈពេល៤៨ម៉ោង និងដោយពិរុទ្ធជនក្នុងរយៈពេល៥ថ្ងៃ ដោយរយៈពេលនេះគិតចាប់ពីថ្ងៃដែលតុលាការសម្រេចឃុំខ្លួន។

បណ្តឹងឧទ្ធរណ៍មានអានុភាពក្នុងការបង្អាក់ការអនុវត្តសាលក្រមរបស់សាលាដំបូងហើយសាលាដំបូងត្រូវបញ្ជូនសំណុំរឿងទាំងអស់ជូនសាលាឧទ្ធរណ៍ដើម្បីត្រួតពិនិត្យ និងចាត់ការបន្តតាមនីតិវិធីច្បាប់ជាធរមាន។ចំពោះជនជាប់ចោទដែលជាប់ឃុំខ្លួនត្រូវនៅក្នុងពន្ធនាគាររហូតដល់សាលាឧទ្ធរណ៍សម្រេចសេចក្តីចំពោះបណ្តឹងឧទ្ធរណ៍នេះ។ ប្រសិនបើជនជាប់ចោទត្រូវបានសាលាដំបូងបានសម្រេចឲ្យរួចខ្លួន ឬក៏ផ្តន្ទាទោសដាក់ពន្ធនាគារមានរយៈពេលតិចជាង ឬស្មើនឹងរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ព្រះរាជអាជ្ញាអាចយល់ព្រមដោះលែងជនជាប់ចោទឲ្យមានសេរីភាពមុនពេលកំណត់នៃរយៈពេលបណ្តឹងឧទ្ធរណ៍។

ក្រឡាបញ្ជីចុះបណ្តឹងឧទ្ធរណ៍នៅលើបញ្ជីពិសេសដែលរក្សាទុកនៅក្នុងបញ្ជីនៃតុលាការ។ លិខិតប្តឹងឧទ្ធរណ៍ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងអ្នកប្តឹងឧទ្ធរណ៍ ឬអ្នកតំណាង។ លិខិតប្រគល់សិទ្ធិត្រូវភ្ជាប់នឹងលិខិតប្តឹងឧទ្ធរណ៍[៣៣]។

ក្រោយពីបានចុះបញ្ជីបណ្តឹង និងចុះហត្ថលេខារួចមកក្រឡាបញ្ជីនៃសាលាដំបូងរៀបចំសំណុំរឿងបញ្ជូនទៅការិយាល័យក្រឡាបញ្ជីសាលាឧទ្ធរណ៍ក្នុងរយៈពេលដ៏ខ្លីបំផុតនូវៈ[33]

- សំណុំរឿងនៃនីតិវិធី
- សេចក្តីចម្លងនៃលិខិតប្តឹងឧទ្ធរណ៍នីមួយៗដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម
- សេចក្តីចម្លងនៃសាលក្រមដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម[៣៤]។

បណ្តឹងឧទ្ធរណ៍អាចធ្វើឡើងដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ក្នុងរយៈពេល៣ខែគិតចាប់ពីថ្ងៃប្រកាសសាលក្រមនៅសាលាដំបូង។ បណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាធ្វើជាលាយលក្ខណ៍អក្សរនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍។ ក្រឡាបញ្ជីចុះបណ្តឹងឧទ្ធរណ៍នៅលើបញ្ជីពិសេសដែលរក្សាទុកនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍។
លិខិតប្តឹងឧទ្ធរណ៍ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងអគ្គព្រះរាជអាជ្ញា[៣៥]។

[៣៣]មាត្រា៣៧៦ វាក្យខ័ណ្ឌទី៥ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧
[៣៤]មាត្រា៣៨៦ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧
[៣៥]មាត្រា៣៧៩ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការបកស្រាយយ៉ាងលម្អិត តាមរយៈការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី "**នីតិវិធីជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូង**" រួចមកធ្វើឲ្យយើងយល់កាន់តែច្បាស់ថា នីតិវិធីជំនុំជម្រះ គឺជានីតិវិធីដ៏សំខាន់របស់ស្ថាប័នតុលាការ ក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ នៅពេលដែលមានអំពើបំពារបំពានដល់សិទ្ធិ សេរីភាព សុវត្ថិភាព និងសេចក្តីថ្លៃថ្នូររបស់បុគ្គលគ្រប់ៗរូបដែលរស់នៅក្នុងសង្គម។ នីតិវិធីដែលតុលាការបានអនុវត្តក្នុងការជំនុំជម្រះសព្វថ្ងៃ មានលក្ខណៈឆាប់រហ័សជាងមុនដើម្បីសម្រួលការកកស្ទះរឿងក្តី។ ឆ្លងតាមរយៈការបកស្រាយលើប្រធានបទនេះ វាបានឆ្លុះបញ្ចាំងឲ្យយើងឃើញថានីតិវិធីនៃការជំនុំជម្រះមានពីរដំណាក់កាល គឺដំណាក់កាលមុនពេលសវនាការ និងដំណាក់កាលក្នុងពេលសវនាការ។ សម្រាប់ដំណាក់កាលមុនពេលសវនាការដែលគិតចាប់ពីតុលាការទទួលបានដីកាបញ្ជូនមកជំនុំជម្រះរហូតដល់ការបញ្ជូនដីកាកោះហៅដល់ ជនល្មើស ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីជាការផ្តល់ដំណឹងដល់ភាគីទាំងអស់ឲ្យបានដឹងថាខ្លួនត្រូវបានតុលាការកោះហៅឲ្យចូលមកសវនាការក្នុងការដោះស្រាយវិវាទនៃបណ្តឹងអ្វី។ ជាពិសេសដើម្បីឲ្យប្រាកដថាភាគីទាំងអស់បានទទួលដំណឹងពីការកោះហៅឲ្យចូលសវនាការ តុលាការអនុវត្តតាមនីតិវិធីនៃការបញ្ជូនដីកាកោះតាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ការបញ្ជូនដីកាកោះហៅដែលយើងសង្កេតឃើញសព្វថ្ងៃ គឺតាមរយៈប្រៃសនីយ៍ច្រើនជាងការបញ្ជូនតាមរយៈមន្ត្រីរដ្ឋបាល អាជ្ញាសាលា ព្រះរាជអាជ្ញា និងអាជ្ញាធរដែនដី។ បន្ទាប់ពីនីតិវិធីខាងលើបានបំពេញចប់សព្វគ្រប់ហើយ តុលាការចាប់ផ្តើមនីតិវិធីនៃការជំនុំជម្រះស្វែងរកភាពយុត្តិធម៌តាមរយៈការសួរចម្លើយ និងការស្តាប់ចម្លើយរបស់ ជនជាប់ចោទ ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ជាពិសេសការជំនុំជម្រះក៏ស្ថិតសមត្ថភាពវិនិច្ឆ័យយ៉ាងល្អិតល្អន់របស់តុលាការផងដែរ ដើម្បីឲ្យមានភាពសុក្រឹត្យ យុត្តិធម៌ និងតម្លាភាព។ ក្រោយពីការបញ្ចប់ការជំនុំជម្រះតុលាការនឹងធ្វើការប្រកាសសាលក្រមភ្លាមៗ តែប្រសិនបើក្នុងករណីដែលរឿងក្តីមានភាពស្មុគស្មាញតុលាការអាចពន្យារពេលប្រកាសសាលក្រមដោយកំណត់ពេលសវនាការម្តងទៀត។ ចំពោះការចេញសាលក្រមលើអង្គសេចក្តី ចៅក្រមរៀបចំតាក់តែងនូវខ្លឹមសារនៃសាលក្រមត្រូវសរសេរឲ្យមានផ្នែកសំអាងហេតុ និងផ្នែកសេចក្តីសម្រេច ដែលបញ្ជាក់ពីការមានពិរុទ្ធដើម្បីផ្តន្ទាទោស ឬបើគ្មានពិរុទ្ធភាពត្រូវប្រកាសឲ្យរួចខ្លួន។ នៅក្នុងការប្រកាសសាលក្រមអាចប្រកាសចំពោះមុខគូភាគី ឬកំបាំងមុខ និងចាត់ថាចំពោះមុខប្រសិនបើមានបញ្ជាក់ហេតុផលត្រឹមត្រូវ ហើយក្នុងសាលក្រមទុកសិទ្ធឲ្យប្តឹងទាស់ និងឧទ្ធរណ៍ចំពោះសាលក្រម។ ការប្តឹងទាស់នឹងសេចក្តីសម្រេចរបស់តុលាការរបស់តុលាការ

មានរយៈពេល១៥ថ្ងៃ និងប្តឹងឧទ្ធរណ៍ រយៈ១ខែគិតចាប់ពីថ្ងៃប្រកាសសាលក្រម បើផុតរយៈពេលកំណត់ខាងលើគ្មានការប្តឹងទាស់ ឬប្តឹងឧទ្ធរណ៍សាលក្រមនឹងចូលជាស្ថាពរ។ ក្រោយប្រកាសសាលក្រម ក៏មាននីតិវិធីនៃការជូនដំណឹងអំពីសាលក្រមដល់ភាគីដែលអវត្តមានពេលប្រកាសដែរ។

ទន្ទឹមនឹងភាពវិជ្ជមាននៅក្នុងនីតិវិធីនៃការជំនុំជម្រះដែលអនុវត្តយ៉ាងខ្ជាប់ខ្ជួនតាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏យើងឃើញថាមានភាពអវិជ្ជមានមួយចំនួនកើតមានឡើងក្នុងនីតិវិធីនៃការជំនុំជម្រះរបស់ស្ថាប័នតុលាការដែលអនុវត្តយ៉ាងខ្ជាប់ខ្ជួនតាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ឬក៏អាចមានការបង្រួមនីតិវិធីមួយចំនួនតូចដើម្បីឲ្យការជំនុំជម្រះអាចរលូនទៅបានដោយភាពឆាប់រហ័ស។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏យើងកត់សម្គាល់ឃើញថាសំណុំរឿងនៅក្នុងតុលាការនៅតែមានអត្រាខ្ពស់ដដែលហើយចំណែកឯបទល្មើសវិញកើតមានឡើងរាល់ថ្ងៃមិនថាជា បទលហុ បទមជ្ឈិម និងបទឧក្រិដ្ឋ ព្រោះតែកម្រិតនៃការដាក់ទោសទណ្ឌសម្រាប់បទល្មើសតូចតាចនៅមានកម្រិត ទើបបណ្តាលឲ្យជនដែលប្រព្រឹត្តបទល្មើសមិនមានខ្លាចញញើតនឹងការផ្តន្ទាទោសរបស់តុលាការ។ ចំពោះការស្វែងរកភាពយុត្តិធម៌ជូនប្រជាពលរដ្ឋក៏នៅមានកម្រិតដែរ ព្រោះយើងឃើញប្រសិនបើប្រជាពលរដ្ឋគាត់ទទួលបានភាពយុត្តិធម៌សមស្របនឹងព្យសនកម្មដែលបានទទួលរងនោះ ក៏ពុំមានការបន្តបណ្តឹងរហូតដល់សាលាឧទ្ធរណ៍និងតុលាការកំពូលដែរ។

សរុបសេចក្តីមកនីតិវិធីនៃការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូងសព្វថ្ងៃមានទាំងភាពវិជ្ជមាន និងភាពអវិជ្ជមានមួយចំនួននៅលាយឡំគ្នា។ ប៉ុន្តែបើទោះបីជាមានភាពអវិជ្ជមានមួយចំនួនបានលេចឡើងក៏ដោយ ក៏យើងឃើញថាតុលាការមិនមានភាពរុញរារនៅតែបន្តការខិតខំប្រឹងប្រែងយ៉ាងមុតមាំក្នុងការស្វែងរកភាពយុត្តិធម៌ជូនប្រជាពលរដ្ឋបានយ៉ាងច្រើនដែរ។

# អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវលើប្រធានបទនេះ នាងខ្ញុំបានមើលឃើញពីចំណុចខ្វះខាតមួយចំនួននៅក្នុងការបញ្ជូនដីកាកោះហៅ និងដីកាឲ្យដំណឹងពីសេចក្ដីសម្រេចដែលតុលាការសព្វថ្ងៃធ្វើការបញ្ជូនតាមរយៈប្រៃសនីយ៍ ប្រសិនបើការបញ្ជូននោះបានទៅដល់អាស័យដ្ឋានរបស់ជនល្មើស ជនរងគ្រោះក៏ពិតមែនតែបើគាត់ពុំបានទទួលផ្ទាល់ពីអ្នកផ្ញើរតាមប្រៃសនីយ៍នូវដីកាដែលផ្ញើរចេញពីតុលាការ ឬអ្នកផ្ញើរគ្រាន់ដាក់ក្នុងប្រអប់សំបុត្រមុខផ្ទះចោលដោយមិនបានផ្ដល់ដំណឹងឲ្យជនល្មើស ជនរងគ្រោះបានដឹងនោះ តើតុលាការនឹងធ្វើការជំនុំជម្រះដោយកំបាំងមុខជនល្មើស ជនរងគ្រោះ ឬយ៉ាងណា? ហេតុដូច្នោះសូមឲ្យស្ថាប័នតុលាការមេត្តាយកចិត្តទុកដាក់លើការបញ្ជូនដីកានេះផង។

ម្យ៉ាងវិញទៀតក្នុងនាមខ្ញុំជានិស្សិតផ្នែកច្បាប់ សូមស្នើសុំឲ្យក្រសួងយុត្តិធម៌បំពេញបន្ថែមនូវចំណុចខ្វះខាតមួយចំនួនតូចនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងគោលបំណងដើម្បីឲ្យក្រមនីតិវិធីព្រហ្មទណ្ឌចែងបញ្ញត្តិនៃមាត្រាមួយចំនួនឲ្យកាន់តែមានភាពសុក្រឹត្យច្បាស់លាស់ ពិសេសនោះគឺនិយមន័យនៃដីកាបញ្ជូនទៅជំនុំជម្រះដោយចៅក្រមស៊ើបសួរ ព្រមទាំងឲ្យនិយមន័យនៃសាលក្រមនីមួយឲ្យបានក្បោះក្បាយ។ជាពិសេសសូមឲ្យក្រសួងយុត្តិធម៌បន្ថែមស្លាមទម្ងន់ទោសនៃបទល្មើសឲ្យកាន់តែធ្ងន់ដើម្បីឲ្យបុគ្គលគ្រប់រូបមានភាពភ័យខ្លាច រៀងចាលក្នុងការប្រព្រឹត្តបទល្មើសដែលបង្កជាអសន្តិសុខ អសណ្ដាប់ធ្នាប់ក្នុងសង្គម ហើយក៏សូមស្នើដល់ក្រសួងមហាផ្ទៃជួយរក្សាសន្តិសុខ សណ្ដាប់ធ្នាប់នៅក្នុងសង្គម ជាពិសេសនៅតាមមូលដ្ឋានដែលប្រជាពលរដ្ឋរស់នៅឲ្យមានស្ថេរភាពដើម្បីកាត់បន្ថយនូវអត្រាបទល្មើសពីកម្រិតច្រើនឲ្យមកនៅសល់កម្រិតទាប។ ការចូលរួមរបស់សមត្ថកិច្ចតាមមូលដ្ឋានក្នុងការបង្ការបទល្មើស វាជាផ្នែកមួយក្នុងការសម្រួលដល់ស្ថាប័នតុលាការឲ្យមានសក្ដានុពល ក្នុងការពន្លឿននីតិវិធីនៃជំនុំជម្រះរកស្វែងភាពយុត្តិធម៌ដល់ប្រជាពលរដ្ឋ ក្នុងរឿងក្ដីដែលបន្សល់ទុកជាច្រើនឆ្នាំកន្លងមកឲ្យបានឆាប់រហ័ស និងសុក្រឹត្យភាព។

មួយវិញទៀតយើងឃើញថាការអនុវត្តនីតិវិធីព្រហ្មទណ្ឌនៅកម្ពុជានូវមានកម្រិត ហើយមន្ត្រីអ្នកអនុវត្តច្បាប់មួយចំនួន មិនបានយល់ដឹងឲ្យស៊ីជម្រៅអំពីស្មារតីរបស់ក្រមនីតិវិធីព្រហ្មទណ្ឌនៅឡើយ។ អាស្រ័យហេតុនេះ សូមស្នើឲ្យក្រសួងយុត្តិធម៌មេត្តាធ្វើយ៉ាងណា ផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលដល់មន្ត្រីអនុវត្តច្បាប់បន្ថែមឲ្យបានច្រើន ជាពិសេសជំរុញការផ្សព្វផ្សាយជាសាធារណៈដល់ប្រជាពលរដ្ឋឲ្យបានយល់ដឹងអំពីក្រមនីតិវិធីព្រហ្មទណ្ឌ។

# ឯកសារពិគ្រោះ

## ១. លិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១០
- ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញាឆ្នាំ ២០១៤
- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការឆ្នាំ ២០១៤
- ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ ២០១៦
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦

## ២. កម្រងឯកសារផ្សេងៗ

- សៀវភៅទ្រឹស្តីនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោកសាស្ត្រាចារ្យ អៀង សំណាង បោះពុម្ពឆ្នាំ២០១៥
- សៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង លោកស្រីសាស្ត្រចារ្យ ចាំង ស៊ីណាត
- សៀវភៅសំណួរ-ចម្លើយអំពីនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោកសាស្ត្រាចារ្យ អៀង សំណាង បោះពុម្ពឆ្នាំ២០១៦
- សៀវភៅក្រឡាបញ្ជីតុលាការ និងអយ្យការក្នុងរឿងព្រហ្មទណ្ឌ និពន្ធដោយលោក ហ៊ីង ធីឫទ្ធិ បោះពុម្ពឆ្នាំ២០០៤
- សៀវភៅប្រព័ន្ធតុលាការ និពន្ធដោយលោក Wilhelm Treiber ជាចៅក្រមជនជាតិអាល្លឺម៉ង់ និងអ្នកស្រី Andrea Behm ជាមេធាវីជនជាតិអាល្លឺម៉ង់ បកប្រែ និងកែសម្រួលដោយកញ្ញា ហួត សុធាវី បោះពុម្ពផ្សាយលើកទី១ខែកក្កដា ឆ្នាំ២០០២នៅទីក្រុងភ្នំពេញ
- សន្ទានុក្រមពាក្យច្បាប់ ឆ្នាំ១៩៩៤ ដល់ ឆ្នាំ២០១២ រៀបរៀងដោយៈ លោកឆយ អូន លោក ឥន យឿន លោកងួន យ៉ាណា អ្នកស្រី អ៊ិត មល្លិកា និងលោកសៀង វិសាល បោះពុម្ពលើកទី១ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២ នៅរោងពុម្ព ISB ( International standard books)

# ឧបសម្ព័ន្ធ

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ដីកាកោះឲ្យចូលរួមសវនាការ

យើង........................................... តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។ ក្រោយពីបានពិនិត្យសំណុំរឿងព្រហ្មទណ្ឌលេខ.......... ចុះថ្ងៃទី....... ខែ............ ឆ្នាំ..................។

ឈ្មោះ......................................ភេទ.........អាយុ..........ឆ្នាំ សញ្ជាតិ.............................. ជាប់ចោទពីបទ.........................................................ប្រព្រឹត្ត.....................................ផ្លូវ........... ភូមិ............... សង្កាត់........................ ខណ្ឌ.................... រាជធានីភ្នំពេញ កាលពីថ្ងៃទី........... ខែ ................ឆ្នាំ................ ដែលត្រូវផ្តន្ទាទោសតាមមាត្រា.............. នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

-បង្គាប់ឲ្យឈ្មោះ.................................ភេទ..........អាយុ..........ឆ្នាំសញ្ជាតិ..................... មាន ទីលំនៅ..................................................ភូមិ.....................ឃុំ/សង្កាត់.................................ស្រុក/ ខណ្ឌ.......................ខេត្ត/ក្រុង.........................ប្រពន្ធឈ្មោះ...................................“រ/ស” មានកូន ចំនួន.........នាក់។ឪពុកឈ្មោះ.....................................“រ/ស”ម្តាយឈ្មោះ.......................“រ/ស” ឲ្យចូល ទៅកាន់សាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី........ខែ...........ឆ្នាំ........... វេលាម៉ោង .......................... សាលទី.....ជាន់ទី......ជាកំហិតដើម្បីឆ្លើយដោះសារពីការចោទប្រកាន់លើខ្លួន។

## សមាសភាពជំនុំជម្រះ

លោក.......................................ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

លោក.......................................ជាតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

លោក.......................................ជាក្រឡាបញ្ជីសវនាការសាលាដំបូងរាជធានីភ្នំពេញ

សិទ្ធិរបស់ជនជាប់ចោទ ៖

-សិទ្ធិទទួលការដឹងលឺពីលិខិតចោទប្រកាន់ទោស និងដីកាកោះឲ្យចូលខ្លួន

-សិទ្ធិបង្ហាញភស្តុតាង សំអាងសាក្សី ឬ សំណូមពរផ្សេងៗ

-សិទ្ធិការពារខ្លួនដោយខ្លួនឯង ឬ សុំឲ្យមេធាវីជួយការពារ ឬ ពឹងអ្នកដទៃណាមួយជួយការពារខ្លួន។

រាជធានីភ្នំពេញថ្ងៃទី.......ខែ...........ឆ្នាំ............

**តំណាងអយ្យការ**

យើង..........................................បានប្រគល់ដីកាកោះនេះឲ្យឈ្មោះ....................................
មានទីលំនៅភូមិ...................ឃុំ/សង្កាត់.......................ស្រុក/ខណ្ឌ...................................ខេត្ត/រាជធានី
.................................នៅថ្ងៃទី...........ខែ...........ឆ្នាំ...........រួចហើយបានប្រាប់ថាឲ្យប្រគល់ចុងដីកានេះដល់ក្រឡាបញ្ជីនៅពេលចូលទៅដល់សាលាដំបូងរាជធានីភ្នំពេញ ។

ក្នុងករណីសាម៉ីខ្លួនមិនបានចូលទៅបង្ហាញខ្លួនចំពោះមុខសាលាដំបូងតាមកាលកំណត់ដូច ខាងលើ សាលាដំបូងនឹងយកឈ្មោះ....................................នេះមកជំនុំជម្រះកាត់ទោសកំបាំងមុខ។

**អ្នកទទួល** | **អ្នកប្រគល់**

**ស្នាមមេដៃស្តាំ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ..................

ចុះថ្ងៃទី............ ខែ..........ឆ្នាំ...........

# លិខិតអញ្ជើញមេធាវី

យើង.....................................តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។ អញ្ជើញលោក/លោកស្រីមេធាវី..........................................................................ដែលមានអាស័យដ្ឋានភូមិ.......................ឃុំ/សង្កាត់........................ស្រុក/ខណ្ឌ................................ ខេត្ត/ក្រុង............ឲ្យចូលទៅកាន់សាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី.......ខែ............ឆ្នាំ............ វេលាម៉ោង .........................................នៅសាលទី.........ជាន់ទី............ ដើម្បីការពារកូនក្តីនាពេលសវនាការពីដំណើររឿង................................................................. ។

សាមីខ្លួនត្រូវអញ្ជើញមកឲ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងក្នុងរឿងខាងលើមកជាមួយផងប្រសិនបើមាន ។

រាជធានីភ្នំពេញថ្ងៃទី.......ខែ.........ឆ្នាំ............

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ.........

ចុះថ្ងៃទី..... ខែ............. ឆ្នាំ..........

# <u>**ដីកាកោះ**</u>

យើង..................................តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

អញ្ជើញឈ្មោះ......................ភេទ......អាយុ.....ឆ្នាំ ជាសាក្សីដែលមានអាស័យដ្ឋានផ្ទះលេខ..........

ផ្លូវ........ភូមិ..........ឃុំ/សង្កាត់..........ស្រុក/ខណ្ឌ.....................ខេត្ត/ក្រុង................................

ឲ្យចូលទៅកាន់សាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី......ខែ.......ឆ្នាំ...........វេលាម៉ោង.....................

នៅសាលទី.....ជាន់ទី......ដើម្បីចូលរួមសវនាការពីដំណើររឿង..........................................។

សាម៉ីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឲ្យបានទាន់ពេលវេលានិងយកលិខិតផ្សេងៗដែល

ទាក់ទងក្នុងរឿងខាងលើមកជាមួយផងប្រសិនបើមាន ។

រាជធានីភ្នំពេញថ្ងៃទី.......ខែ........ឆ្នាំ............

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

លេខ:.................................

# លិខិតជូនដំណឹង

យើង..........................................តំណាងអយ្យការអមសាកាដំបូងរាជធានីភ្នំពេញ។ ជម្រាមជូនមកលោក-លោកស្រី...........................................ទីលំនៅបច្ចុប្បន្នផ្ទះលេខ.............. ផ្លូវ............ក្រុម.......ភូមិ......................ឃុំ/សង្កាត់..........................ស្រុក/ខណ្ឌ...................... ខេត្ត/រាជធានី....................................។

ត្បិតពាក្យបណ្ដឹងចុះថ្ងៃទី...............ខែ..........ឆ្នាំ...............របស់លោក-លោកស្រីដែលបាន ប្ដឹង ពីឈ្មោះ..............................................ទីលំនៅបច្ចុប្បន្នផ្ទះលេខ...........ផ្លូវ..........ក្រុម...... ភូមិ...................ឃុំ/សង្កាត់....................ស្រុក/ខណ្ឌ.................ខេត្ត/រាជធានី....................... ពីបទ............................................ប្រព្រឹត្តនៅ.........................................ភូមិ.................... ឃុំ/សង្កាត់....................ស្រុក/ខណ្ឌ.................ខេត្ត/រាជធានី.......................កាលពីថ្ងៃទី........ ខែ...........ឆ្នាំ............តាមមាត្រា..................នៃច្បាប់.................................................... នោះយើងបានសម្រេច............................................................................................................ តាមដីកាសម្រេចលេខ..............................ថ្ងៃទី.......ខែ.........ឆ្នាំ.............រួចហើយ។

រាជធានីភ្នំពេញថ្ងៃទី.......ខែ.........ឆ្នាំ............

**តំណាងអយ្យការ**

---

( ១ )- ជូនដំណឹងដោយមាត្រា ៦ និង មាត្រា ៤១ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ.........
ចុះថ្ងៃទី.... ខែ........ ឆ្នាំ...........
លេខ:..................................

## <u>កំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម</u>

ឆ្នាំពីរពាន់...............ខែ...........ថ្ងៃទី..........វេលាម៉ោង......................នៅអយ្យការសាលាដំបូងរាជធានីភ្នំពេញ។

យើង.......................................................តំណាងអយ្យការសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញរបាយការណ៍សំយោគលេខៈ.............ចុះថ្ងៃទី........ខែ.........ឆ្នាំ..............របស់ស្នងការនគរបាលរាជធានីភ្នំពេញ។

-បានឃើញមាត្រា៤៧មាត្រា៤៨និងមាត្រា៣០៤នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម ០៨០៧/ចុះថ្ងៃទី១០ខែសីហាឆ្នាំ២០០៧។

**បុគ្គលដែលនៅចំពោះមុខយើងបានផ្តល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោមៈ**

១-ឈ្មោះ...........................ភេទ.........អាយុ...........ឆ្នាំ សញ្ជាតិ.............មុខរបរ..........
ទីកន្លែងកំណើតភូមិ...................ឃុំ............ស្រុក.............ខេត្ត.........................ទីលំនៅបច្ចុប្បន្ន
ភូមិ............ឃុំ/សង្កាត់......................ស្រុក/ខណ្ឌ.................ខេត្ត/រាជធានី.............................
ឪពុកឈ្មោះ............................................(រ/ស) ម្តាយឈ្មោះ....................................... (រ/ស)
ប្រពន្ធឈ្មោះ...........................(រ/ស) មានកូនចំនួន.....នាក់ទោសពីមុន................................។

២-ឈ្មោះ............................ភេទ.........អាយុ...........ឆ្នាំ សញ្ជាតិ.............មុខរបរ.........
ទីកន្លែងកំណើតភូមិ..............ឃុំ/សង្កាត់............ស្រុក/ខណ្ឌ.............ខេត្ត/រាជធានី...................
ទីលំនៅបច្ចុប្បន្នភូមិ............ឃុំ/សង្កាត់..................ស្រុក/ខណ្ឌ.................ខេត្ត/រាជធានី...........
ឪពុកឈ្មោះ...........................................(រ/ស) ម្តាយឈ្មោះ....................................... (រ/ស)
ប្រពន្ធឈ្មោះ...........................(រ/ស) មានកូនចំនួន......នាក់ទោសពីមុន...............................។

**យើងប្រាប់ដល់បុគ្គលនេះនូវអង្គហេតុដែលខ្លួនត្រូវបានចោទប្រកាន់មានដូចតទៅ:**

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

**យើងបានប្រាប់ដល់ជននេះថា**ខ្លួនមានសិទ្ធិសុំពឹងមេធាវីតាមការជ្រើសរើសរបស់ខ្លួនឬស្នើសុំឲ្យមានការចាត់តាំងមេធាវីដោយអនុលោមតាមបញ្ញត្តិច្បាប់។

**ជននេះបានឆ្លើយថា**

☐ ខ្ញុំជ្រើសរើស-លោក/លោកស្រីមេធាវី...............................................................។

☐ ខ្ញុំសូមស្នើសុំឲ្យមានការចាត់តាំងមេធាវីស្រមតាមបញ្ញត្តិច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

☐ ខ្ញុំមិនត្រូវការមេធាវីទេក្នុងពេលនេះ។

**យើងបានបញ្ជាក់ថា**

☐ លោក/លោកស្រីមេធាវីអាចពិនិត្យសំណុំរឿងនិងទាក់ទងជាមួយជនជាប់ចោទ។

☐ យោងលើសំណើសុំឲ្យមានការចាត់តាំងមេធាវីស្របតាមបញ្ញត្តិច្បាប់ស្តីពីលក្ខន្តិកៈមេធាវីតំណាងគណៈមេធាវីត្រូវបានជូនដំណឹងភ្លាម។

☐ លោក/លោកស្រីមេធាវី.................................មានវត្តមាន។

**សម្រេច**

**-បញ្ជូនជនជាប់ចោទ**

១-ឈ្មោះ..................................ភេទ............អាយុ...............ឆ្នាំ សញ្ជាតិ..............។

២-ឈ្មោះ..................................ភេទ............អាយុ...............ឆ្នាំ សញ្ជាតិ..............។

ទៅតុលាការដើម្បីធ្វើការជំនុំជម្រះតាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាមចំពោះអង្គហេតុនិងបទល្មើសដូចខាងលើ។ ក្រោយពីបានអានជនជាប់ចោទបានផ្តិតស្នាមម្រាមដៃជាមួយយើង។

**ជនជាប់ចោទ** **ព្រះរាជអាជ្ញា**

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ..........
ចុះថ្ងៃទី.... ខែ........ ឆ្នាំ............

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# <u>ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់</u>

យើង..............................តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខៈ..............ចុះថ្ងៃទី.........ខែ.........ឆ្នាំ................... របស់អយ្យការសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ មាត្រា៤៣ មាត្រា៤៦ និងមាត្រា៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម ០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

**<u>ក្រោយពីបានពិនិត្យសំណុំរឿងសព្វគ្រប់</u>**

**ឃើញថា**

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

........ ..............................................................................................................................

**បានឃើញ**

.......................................................................................................................................

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

....... ........................................................................................................................................

**យល់ឃើញថា**

...............................................................................................................................................

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

**ហេតុដូច្នេះសម្រេច**

១-ឈ្មោះ..............................ភេទ........អាយុ......ឆ្នាំសញ្ជាតិ.............មុខរបរ.........
ទីកន្លែងកំណើតភូមិ.........ឃុំ/សង្កាត់............ស្រុក/ខណ្ឌ...............ខេត្ត/រាជធានី......................
ទីលំនៅបច្ចុប្បន្នភូមិ.............ឃុំ........ស្រុក.................ខេត្ត............ឪពុកឈ្មោះ
..........................(រ/ស)ម្តាយឈ្មោះ................................(រ/ស)ប្រពន្ធឈ្មោះ................(រ/ស)
មានកូនចំនួន...........នាក់ទោសពីមុន...........................................................................។
ពីបទ:...................................ប្រព្រឹត្តនៅភូមិ.......សង្កាត់..........ក្រុម......ខេត្ត/រាជធានី................
កាលពីថ្ងៃទី........ខែ......ឆ្នាំ...........តាមបញ្ញត្តិមាត្រា.............នៃច្បាប់..................................។

២-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ:.............ចុះថ្ងៃទី.........ខែ........ឆ្នាំ.........និងវត្ថុតាង ព្រមទាំងបញ្ជីរាយនាមជនដែលជាប់ទាក់ទិនក្នុងរឿងក្តីនេះទៅប្រធានសាលាដំបូងរាជធានីភ្នំពេញ ដើម្បីបញ្ជូនសំណុំទៅជំនុំជម្រះតាមច្បាប់។

រាជធានីភ្នំពេញថ្ងៃទី...........ខែ..........ឆ្នាំ..........

**ជ.ព្រះរាជអាជ្ញា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ:..................................

# ដីកាចាត់តាំងចៅក្រមជំនុំជម្រះ

យើង......................................................ប្រធានសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញបទបញ្ញត្តិមាត្រា២៩៨ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ:............ចុះថ្ងៃទី.........ខែ...........ឆ្នាំ.................... របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាដំណោះស្រាយបញ្ជូនសំណុំរឿងឲ្យជំនុំជម្រះលេខ:...........ចុះថ្ងៃទី............ ខែ................ឆ្នាំ.................របស់ចៅក្រមស៊ើបសួរ។

**សម្រេច**

ប្រការ១/ ចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះដូចខាងក្រោម៖

លោក...........................................................ដែលបានចាត់តាំងជាចៅក្រមជំនុំជម្រះ រួចហើយតាមដីកាចាត់តាំងដូចខាងលើ ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

ប្រការ២/ ចាត់តាំងបន្ថែមដើម្បីបង្គ្រប់៖

លោក.....................................................................ជាចៅក្រមប្រឹក្សា។

លោក.....................................................................ជាចៅក្រមប្រឹក្សា។

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌខាងលើដែលសវនាការប្រព្រឹត្តនៅថ្ងៃទី........ខែ..........ឆ្នាំ ...................

ប្រការ៣/ អស់លោកចៅក្រមដែលមានឈ្មោះដុចក្នុងប្រការ១និង២ ខាងលើនេះមានភារកិច្ច អនុវត្តនៅគ្រប់នីតិវិធីមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និងបទបញ្ញត្តិច្បាប់ជាធរមាន។

រាជធានីភ្នំពេញថ្ងៃទី........ខែ.........ឆ្នាំ..........

**ប្រធានសាលាដំបូង**

# បទបញ្ជាផ្ទៃក្នុងបន្ទប់ជំនុំជម្រះ
# "ព្រហ្មទណ្ឌ"

ក្នុងបន្ទប់ជំនុំជម្រះ  ជនទាំងឡាយត្រូវអនុវត្តជាដាច់ខាតនូវការណែនាំរបស់ប្រធានសាលាដំបូងគឺ៖

១. ត្រូវរក្សាអាកប្បកិរិយាអោយបានសមរម្យ មិនបើកទូរស័ព្ទ ហាមថតរូប ថតវីឌីអូ ឬថតសម្លេងដោយគ្មានការអនុញ្ញាត មិនជក់បារី មិនពាក់មួក មិនជជែកគ្នា មិនទះដៃ មិនស្រែកជ័យយោ មិនដើររហេតរហូត ដែលជាមូលហេតុនាំឲ្យខូចសណ្ដាប់ធ្នាប់។

២. ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី សាក្សី និង សាធារណជនដែលត្រូវចូលរួមក្នុងឱកាសជំនុំជម្រះត្រូវបង្ហាញនូវដីកាកោះ ឬលិខិតផ្សេងៗ ដល់ក្រឡាបញ្ជីតុលាការ ហើយអង្គុយចំកន្លែងតាមការណែនាំរបស់អ្នកថែរក្សាសណ្ដាប់ធ្នាប់ ឬក្រឡាបញ្ជីនៅទីនោះ។

៣. ហាមផ្ដាច់មិនឲ្យក្មេងអាយុតិចជាង ១៦ឆ្នាំ ចូលក្នុងបន្ទប់ជំនុំជម្រះ លើកលែងតែក្មេងណាដែលចូលមកបំពេញភារកិច្ចជាសាក្សី-ជនរងគ្រោះ-ជនជាប់ចោទ-ពិរុទ្ធជន។

៤. ហាមផ្ដាច់មិនឲ្យយកអាវុធចូលក្នុងបន្ទប់ជំនុំជម្រះ បើសិនជាមានអាវុធ ត្រូវផ្ញើអាវុធទាំងនោះទុកនៅប៉ុស្ដិ៍យាមប្រចាំការនគរបាលការពារសាលាដំបូង  និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ លើកលែងតែភ្នាក់ងារក្រសួងមានសមត្ថកិច្ចទើបមានសិទ្ធយកអាវុធចូលបាន។

៥. គ្រួសាររបស់ជនជាប់ចោទ មិនឲ្យជួបប្រាស្រ័យទាក់ទង ឬ ប្រគល់អំណោយអ្វីមួយដល់ជនជាប់ចោទនៅក្នុងបន្ទប់ជំនុំជម្រះ។

៦. ជនម្នាក់ៗ ត្រូវមានស្មារតីភ្ញាក់រលឹក ប្រតិបត្តិឲ្យបានត្រឹមត្រូវនូវបទបញ្ជាផ្ទៃក្នុងដូចមានចែងខាងលើនេះ។

៧. ជនប្រព្រឹត្តិល្មើសនឹងបទបញ្ជាត្រូវអ្នករក្សាសណ្ដាប់ធ្នាប់បង្ខំឲ្យចេញពីបន្ទប់ជំនុំជម្រះជាបន្ទាន់។ ប្រសិនបើអំពើល្មើសនោះបណ្ដាលឲ្យខូចនូវរបៀបរៀបរយសាធារណ និងត្រូវផ្ដន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រធានសាលាដំបូងរាជធានីភ្នំពេញ**

## នីតិវិធីក្នុងការធ្វើសម្បថ

ការធ្វើសច្ចាប្រណិធាន ត្រូវដឹកនាំដោយក្រឡាបញ្ជីមួយរូប ហើយត្រូវធ្វើនៅចំពោះមុខវត្ថុសក្តិសិទ្ធ នៅទីកន្លែងនៃតុលាការនីមួយៗ។

មុនចាប់ផ្តើមធ្វើសម្បថ អ្នកស្បថត្រូវអុជទៀន ធូប បូជាចំពោះវត្ថុសក្តិសិទ្ធដែលខ្លួនត្រូវស្បថនោះ។ បន្ទាប់មកក្រឡាបញ្ជីអានប្រារព្ធវាទខ្លាំងៗ ច្បាស់ៗ ឲ្យអ្នកស្បថស្តាប់ រួចអាន **ពាក្យសច្ចាប្រណិធាន** ឲ្យអ្នកស្បថថាតាម។

ក្រោយពីធ្វើសម្បថរួច ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុដែលបានឲ្យស្បថនោះ បញ្ជាក់ថាបានធ្វើត្រឹមត្រូវហើយ សេចក្តីបានចេញវាចាឲ្យស្បថយ៉ាងណា ត្រូវកត់ក្នុងកំណត់ហេតុយ៉ាងនោះផង។

## ប្រារព្ធវាទ

បពិត្រអស់ទេព្រក្ស អារុក្ខអារក្សអ្នកតា និងបារមីស័ក្តិសិទ្ធ មានព្រះអង្គដងកើរ ព្រះអង្គក្រពុំឈូក ព្រះអង្គស្វេតឆ្ឆត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតាក្រហមក លោកតាដំបងដែក លោកតាដំបងក្រញូង លោកយាយទេព ព្រះអង្គវិហារសួគ៌ ព្រះអង្គព្រះជីវ៍បាវាយណ៍ ព្រះអង្គវត្តភ្នំខ្លែង ជាដើម សូមយាងអញ្ជើញមកធ្វើជាអធិបតី ក្នុងពិធីសម្បថនេះ ត្បិតគូក្តីនេះបានឈ្លោះទាស់ទែងគ្នា ហើយអះអាងលើសាក្សីជាអ្នកបានដឹង បានឃើញ បានឮ និងបានចាំដោយផ្ទាល់ ហើយច្បាប់តម្រូវឲ្យយកអ្នកទាំងពីរនេះមកធ្វើជាសាក្សី ឲ្យឆ្លើយឲ្យបានទៀងត្រង់តាមការពិត។

បើអ្នកណាឆ្លើយមិនពិត តាមដែលខ្លួនបានដឹង បានឃើញ បានឮ និងបានចាំទេ សូមអស់ទេព្រក្ស អារុក្ខអារក្សអ្នកតា យាយទេព និងបារមីស័ក្តិសិទ្ធ ចំផ្លាញឲ្យស្លាប់តែហោងយ៉ាងវេទនា ដោយគ្រាប់កាំភ្លើង ខ្សែភ្លើងឆក់ រន្ទះបាញ់ ខ្លាខាំ ពស់ចឹក លុះអនាគតជាតិឲ្យព្រាត់ប្រាស់ឪពុកម្តាយ បងប្អូន កូនចៅ ឲ្យក្ររហេមរហាម ខ្សត់ទ្រព្យ រងទុកវេទនា អស់ប្រាំរយជាតិ។

បើនរណាឆ្លើយការណ៍ដោយពិតត្រង់ មិនវៀចវេរ មិនភូតកុហក មិនលំអៀង ព្រោះជាញាតិសាលោហិត មិនសមគំនិត ព្រោះខ្លាច ព្រោះស្អប់ ព្រោះលាភសក្ការៈ ព្រោះស៊ីសំណូកទេ សូមអស់ទេព្រក្ស អារុក្ខអារក្សអ្នកតា យាយទេព និងបារមីសក្តិសិទ្ធក្នុងលោកជួយឲ្យគេមានអាយុយឺនយូរ មានសុខភាពល្អ មានទ្រព្យសម្បត្តិសម្បូរហូរហៀរ មានញាតិផៅគោរពស្រឡាញ់ រាប់អាន លុះអនាគតជាតិបានជួបតែសេចក្តីល្អ ចម្រុងចម្រើន ថ្កុមថ្កើន រុងរឿង សមដូចសេចក្តីបំណងប៉ងប្រាថ្នាកុំបីអាក់ខានឡើយ។

## ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមឆ្លើយតែការពិត ដែលខ្ញុំបានឃើញ បានឮ បានដឹង និងបានចាំផ្ទាល់។

បើខ្ញុំឆ្លើយមិនពិត ដោយប្រការណាមួយ សូមអស់ទេព្រក្ស អារក្សអ្នកតា និងបារមីសក្តិសិទ្ធទាំងអស់ បរាមុខខ្ញុំឲ្យវិនាសអន្តរាយទ្រព្យសម្បត្តិ និងស្លាប់តែហោងយ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួយឲ្យខ្ញុំមានទ្រព្យសម្បត្តិសម្បូរហូរហៀរ និងរស់នៅប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ជួបជុំបងប្អូន ញាតិផៅសន្តាន ជារៀងរហូតកុំបីអាក់ខានឡើយ។